# ៤. លោកមូសូលីនី និង របបផ្តាច់ការ

## ជីវប្រវត្តិសង្ខេបរបស់មូសូលីនី



*លោកមូសូលីនី (១៨៨៣-១៩៤៥)*

ឪពុករបស់លោក មូសូលីនី ជាជាងដែកផង ហើយ ជាអ្នកលក់កាដៃផង ។ មុនដំបូងលោកធ្វើជាគ្រូបង្រៀន តែក្រោយមក ត្រូវគេបណ្តេញចោល ដោយគំនិតបដិវត្តរបស់លោក ហើយក៏បានរស់នៅដោយត្រដាបត្រដួស ឯប្រទេសស្វ៊ីស ។ មូសូលីនី ចាកចោលប្រទេសស្វ៊ីស ចូលមកកាន់មាតុប្រទេសវិញ ហើយបានធ្វើជាចាងហ្វាងកាសែតមួយ ឈ្មោះ «*អាវ៉ង់ទី*» ដែលជាកាសែតមាន *និន្នាការសង្គមនិយម* ។ ចំបាំងលោកឆ្នាំ១៩១៤ បានធ្វើឲ្យលោកមូសូលីនីប្រែទៅជាបុគ្គលមួយផ្សេងទៀត ។ ក្រោយចំបាំង ក្រោយពីបានឃើញយ៉ាងជាក់ច្បាស់នូវបះរបោរនៃពួកកម្មករនិងកសិករ លោកក៏បានផ្តាច់ទំនាក់ទំនងពីគណបក្សសង្គមនិយម ហើយលោកក៏ចាប់ផ្តើមបង្កបង្កើតគណបក្សមួយថ្មីហៅថា «*គណបក្សផាស៊ីស*» ។ មូសូលីនីជាអ្នកពេញចិត្តនឹងខ្លួនឯង មានអំនួត ហើយមានវោហារក្បោះក្បាយ អាចធ្វើឲ្យគេទាំងអស់គ្នាមានការរំភើបញាប់ញ័រ ក្នុងពេលដែលលោកនិយាយម្តងៗ ។ គេអាចចាត់លោកជា *ជនកាលនិយម* ដ៏ពិតប្រាកដ ។ លុះលោកមូសូលីនី បានប្រមូលអំណាចទាំងអស់មកកាន់កាប់ ក្រោយពីបានធ្វើរដ្ឋប្រហារប្រកបដោយជោគជ័យ លោកក៏ចាប់ស្ថាបនារបបផាស៊ីសមួយពេញផ្ទៃប្រទេសអ៊ីតាលី ។ ចាប់តាំងពីឆ្នាំ១៩២៥ សេរីភាពទាំងប៉ុន្មានត្រូវបាត់បង់អស់ កាសែត ភាពយន្ត វិទ្យុ ត្រូវច្បាប់ផាស៊ីសថ្មីត្រួតពិនិត្យទាំងអស់ ។ នៅក្នុងឆ្នាំ១៩២៦ គំណាងរាស្ត្រខាងគណបក្សជំទាស់ទាំងប៉ុន្មានត្រូវបណ្តេញចោល ។

ក្រសួងរដ្ឋបាល កងទ័ព ក្រសួងសិក្សាធិការ ត្រូវបានចំរាញ់ទុកឲ្យនៅតែអ្នកណាដែលមានសមានចិត្តអនុគ្រោះដល់ផាស៊ិសនិយម ឯបក្សជំទាស់ត្រូវវិនាសសាបសូន្យ ៗ លោក




លើផ្ទាំងអគារដែលចារពាក្យ «បាទ! បាទ!» មានរូបមុខមូសូលីនី

មូសូលីនី បំបិទសិទ្ធិសេរីភាព ចាប់ចងឃុំឃាំង ឬក៏និរទេស ជនទាំងឡាយណា ដែលមានគំនិត មានយោបល់មិនស្រប ៗ លោកមូសូលីនី បានបង្កើតប៉ូលិសនយោបាយមួយ ដែលរមែងដើរសាបព្រោះសេចក្តីភិតភ័យ សេចក្តីតក់ស្លុត ក្នុងបណ្តាប្រជារាស្ត្រស្លូតត្រង់ ៗ ដូចនេះ គេអាចសន្និដ្ឋានបានថា អំណាចរដ្ឋទាំងអស់ បានត្រូវប្រមូលមកក្នុងកណ្តាប់ដៃនៃជនម្នាក់ ដែលជានាយក ជាអ្នកដឹកនាំ ជាអ្នកគ្រប់គ្រងរដ្ឋទាំងមូល ៗ

ចំពោះបញ្ហាក្រៅប្រទេស ប្រទេសអ៊ីតាលីសម័យផាស៊ិសបានប្រកាន់យកនយោបាយវាតទីតាំងទឹកដី និងដណ្តើមយកដីធ្លីរបស់ប្រទេសដទៃទៀត ៗ ដើម្បីសំរេចគោលបំណងខាងលើ មូសូលីនីបានរៀបចំទ័ព ទាំងខាងជើងគោក ទាំងខាងជើងទឹក ៗ នៅឆ្នាំ ១៩២៤ លោកមូសូលីនីបានដណ្តើមយកក្រុងយូគោស្លាវីមួយឈ្មោះ ព្យូម (Fiume) និងបានភ្ជាប់ប្រទេសអាល់បានីមកនឹងប្រទេសរបស់ខ្លួន ក្នុងឆ្នាំ១៩៣៩ ៗ

ក្នុងទ្វីបអាហ្វ្រិច ប្រទេសអ៊ីតាលីបានវាយយកប្រទេសអេត្យូពី (១៩៣៥-៣៦) ហើយ

នៅមុនចំបាំងលោកលើកទី ២ ប្រទេសអ៊ីតាលីពុំបានលាក់បំបាំងគំនិតលុកលុយយកប្រទេសក្រិចឡើយ ។

នៅឆ្នាំ ១៩៣៧ លោកមូសូលីនីបានចងស្ពានមេត្រីជាមួយ នឹងប្រទេសអាឡឺម៉ង់ ដោយបង្កើត *អ័ក្សរ៉ូម-បែរឡាំង* ។ ប្រទេសជប៉ុនបានចូលរួមក្នុងបក្សសម្ព័ន្ធនេះដែរ ជាហេតុបង្កើតឲ្យមានបក្សមួយឈ្មោះ *កតិកាសញ្ញារ៉ូម-បែរឡាំង-តូក្យូ* ហើយដែលបានផ្ដើមគំនិតវាយលុកយ៉ាងសំបើមក្នុងចំបាំងលោកលើកទី២ ។




*កុមារទាំងអស់នេះបានឆកសណ្ឋានជាទាហានកាន់អាវុធ*

## ខ. ប្រទេសអាឡឺម៉ង់

ប្រវត្តិសាស្ត្រនយោបាយប្រទេសអាឡឺម៉ង់ក្រោយសង្គ្រាមលោកលើកទី ១ ទៅទល់នឹងដើមសង្គ្រាមលោកលើកទី ២ បានពេបប្រទះនឹងវិបត្តិជាច្រើន ដែលជាបច្ច័យនៃសង្គ្រាមលោកលើកទី ១ ហើយដែលជាហេតុបណ្ដាលឲ្យគេស្ថាបនារបបផ្ដាច់ការលើប្រទេសអាឡឺម៉ង់ ។ គេអាចនិយាយបានថា របបផ្ដាច់ការនេះជាប្រតិកម្មរបស់នាយទុននិយម និងកងទ័ព ប្រឆាំងនឹងអនាធិបតេយ្យ ដែលប្រទេសអាឡឺម៉ង់បានស្គាល់ ក្រោយចំបាំងលោកលើកទី១ ។ វិបត្តិទាំងឡាយដែលប្រទេសអាឡឺម៉ង់បានឆ្លងកាត់ មានវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ វិបត្តិខាងសង្គម និងវិបត្តិនយោបាយ ។

## ១. វិបត្តិសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រទេសអាឡឺម៉ង់បានទទួលការខូចខាតជាច្រើនក្នុងពេលចំបាំង ។ ក្រៅពីរោងចក្រឧស្សាហកម្មជាច្រើន ដែលបានត្រូវអន្តរាយ ប្រទេសអាឡឺម៉ង់ត្រូវប្តូរឧស្សាហកម្មសឹករបស់ខ្លួនមកជាឧស្សាហកម្មស៊ីវិលវិញ ។ ក្នុងដំណោះស្រាយបញ្ហានេះ ឧបសគ្គមានជាច្រើន ដែលមានទិដ្ឋភាពស្មុគស្មាញមិនអាចដោះស្រាយបានភ្លាមៗឡើយ ។

ម្យ៉ាងទៀត ប្រទេសអាឡឺម៉ង់ត្រូវសងដល់ប្រទេសខាងប័ក្សសម្ព័ន្ធនូវប្រាក់កាសជាច្រើនកោដិព្រមទាំងប្រគល់ឲ្យពួកឈ្នះនូវមជ្ឈមណ្ឌលរ៉ែសំខាន់ៗទាំងឡាយ ដែលជាដង្ហើមនៃសេដ្ឋកិច្ចរបស់ខ្លួន ដូចជា អណ្តូងរ៉ែនៅតំបន់រួ ( Ruhr ) ជាដើម ។

ក្នុងមហាវិបត្តិសេដ្ឋកិច្ចពិភពលោក ឆ្នាំ ១៩២៩ ដែលបានផ្ទុះដំបូងនៅសហរដ្ឋអាមេរិច ប្រទេសអាឡឺម៉ង់ក៏បានស្គាល់ជាមួយគេដែរ ។ យ៉ាងណាមិញ ប្រទេសទាំងឡាយ ដូចជាចក្រភពអង់គ្លេសនិងសហរដ្ឋអាមេរិច ដែលធ្លាប់ឲ្យឥណទានដល់ប្រទេសអាឡឺម៉ង់ខ្ចីក៏បញ្ឈប់ត្រឹមពេលនោះមក ដោយប្រទេសខ្លួនកំពុងធ្លងកាត់វិបត្តិឆ្នាំ ១៩២៩ នោះដែរ ។ មិនតែប៉ុណ្ណោះ ប្រទេសទាំងពីរខាងលើបង្ខំអាឡឺម៉ង់ឲ្យសងប្រាក់ ដែលខ្លួនខ្ចីមុនកំណត់ពេលទៀតផង ។ វិធានការទាំងនេះធ្វើឲ្យប្រទេសអាឡឺម៉ង់ខ្វះឥណទាន មិនអាចនាំទំនិញទៅបរទេសបាន ជាហេតុនាំឲ្យខ្វះរូបិយប័ណ្ណ ដើម្បីទិញវត្ថុធាតុដើមទាំងឡាយជាចាំបាច់សំរាប់ឧស្សាហកម្មរបស់ខ្លួន ។ វិបត្តិសេដ្ឋកិច្ចខាងលើបង្កើតឲ្យមានវិបត្តិហិរញ្ញវត្ថុយ៉ាងខ្លាំងក្លាថែមទៀត ។ ដើម្បីទប់ទល់នឹងការត្រូវការរបស់រដ្ឋ គេបានបោះក្រដាសប្រាក់ជាច្រើនឥតគណនា ជាហេតុនាំឲ្យប្រាក់អាឡឺម៉ង់បាត់បង់តំលៃអស់ គ្មានប្រទេសណាទទួលស្គាល់ឡើយ ។

*ឧទាហរណ៍* : ១ម៉ាក់ (mark) ជាមាសមានតំលៃស្មើនឹង ៤ ២៨០ ម៉ាក់ក្រដាសក្នុងខែមករា ១៩២៣ ៨៤ ០០០ ម៉ាក់ក្រដាស ក្នុងខែកក្កដា ១ ១០០ ០០០ ម៉ាក់ក្រដាស ក្នុងខែសីហា ២៣ ០០០ ០០០ ក្នុងខែកញ្ញា និង ១០០ លានម៉ាក់ក្រដាស ក្នុងខែ ធ្នូ ១៩២៣ ។ សំបុត្រមួយដែលក្នុងពេលធម្មតាគេបិទតែមត្រឹម ១/១០ នៃប្រាក់ម៉ាក់ គេត្រូវបង់ដល់ ២ ឬ ៣ លានម៉ាក់ ។

បៀវត្សកម្មករ ឬភ្នាក់ងាររដ្ឋការត្រូវប្រែប្រួលមួយថ្ងៃ ២ ឬ ៣ ដង ឬក្នុងមួយម៉ោងម្ដង ៗ ចាប់តាំងពីឆ្នាំ ១៩២៩ ផលិតផលឧស្សាហកម្មអាឡឺម៉ង់ត្រូវបានចុះថយជាលំដាប់ ៗ ក្នុងឆ្នាំ ១៩៣២ ផលិតផលនេះបានចុះថយជាងពាក់កណ្ដាល បើប្រៀបធៀបទៅនឹងផលិតផលឆ្នាំ ១៩២៩ ។ ស្ថានភាពសេដ្ឋកិច្ចក្នុងឆ្នាំ ១៩៣១ បានធ្លាក់ចុះមួយកំរិតទៀត ដែលគួរឲ្យបារម្ភក្រៃលែង ។ វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុខាងលើ បានបង្កើតឲ្យមានវិបត្តិខាងសង្គម ។

## ២. វិបត្តិខាងសង្គម

ប្រាក់ចុះថ្លៃដូចជាក្រដាសកាសែត ទំនិញឡើងថ្លៃ សហគ្រាសឧស្សាហកម្មត្រូវបិទទ្វារ ផលិតផលកសិកម្មលក់មិនចេញ ទាំងនេះជាហេតុឲ្យកើតវិបត្តិខាងសង្គមមួយយ៉ាងធ្ងន់ក្រៃលែង ។ សហគ្រាសតូចតាចឬធំមធ្យមត្រូវដួលរលំក្នុងពេលវិបត្តិឆ្នាំ ១៩២៩ ។ សហគ្រាសធំនៅមានជំហររឹងប៉ឹង ហើយបាន «ទិញថោក» នូវសហគ្រាសឧស្សាហកម្មតូចៗឬមធ្យមទាំងនោះ មកជាសម្បត្តិរបស់ខ្លួន ជាហេតុបណ្ដាលឲ្យនាយទុនធំៗប្រមូលមកកាន់កាប់ក្នុងកណ្ដាប់ដៃរបស់ខ្លួននូវសេដ្ឋកិច្ចរដ្ឋទាំងមូល ។

ឯកម្មករគ្មានការធ្វើមានចំនួនចេះតែកើនឡើងជាលំដាប់ ៗ កម្មករចំនួន ១ ៥០០ ០០០ នាក់ គ្មានការធ្វើក្នុងឆ្នាំ ១៩២៩ ។ ចំនួននេះបានឡើងដល់ ៣ ០០០ ០០០ ក្នុងឆ្នាំ ១៩៣០ និង ៧ ០០០ ០០០ នាក់ ក្នុងឆ្នាំ ១៩៣១ ។ ក្រុងទាំងឡាយប្រែក្លាយទៅជាក្រុង « ងាប់ » មានទិដ្ឋភាពក្រលំបាកតោកយ៉ាក ។ ចលាចល អសន្តិសុខ របះបោរ មានពាសពេញលើផ្ទៃប្រទេស ។ ក្នុងតំបន់ខ្លះ ការអត់ឃ្លានបណ្ដាលឲ្យស្លាប់មនុស្សរាប់ពាន់នាក់ ។ ចំពោះស្ថានភាពប្រកបដោយគ្រោះថ្នាក់នេះ រដ្ឋាភិបាលពុំបានចាត់វិធានការធ្វើឲ្យច្បាស់លាស់ឡើយ ជាហេតុបណ្ដាលឲ្យមានវិបត្តិនយោបាយថែមទៀត ។

## ៣. វិបត្តិនយោបាយ

ខាងវិស័យនយោបាយ គេអាចចែកជាពីរសម័យ ។ សម័យទី១ គឺរបបគ្រប់គ្រងដែលមានលក្ខណៈជាសេរីភាព ប្រជាធិបតេយ្យ ។ សម័យទី២ គឺរបបគ្រប់គ្រង ដែលមានលក្ខណៈផ្ដាច់ការ ។

ក. សម័យទី ១

ក្រោយចំបាំង ប្រទេសអាឡឺម៉ង់បានរៀបចំបោះឆ្នោតជាសកល ។ គណបក្សសេរីភាពដែលមានលោក *អេប៊ែ* (Ebert) ជាអ្នកដឹកនាំ បានទទួលជោគជ័យលើគណបក្សដទៃទៀត ។

នៅថ្ងៃទី ៩ វិច្ឆិកា ១៩១៨ សាធារណរដ្ឋអាឡឺម៉ង់ត្រូវបានប្រកាសនាក្រុងប៊ែឡាំង ហើយលោក អេប៊ែត្រូវបានជ្រើសតាំងជាប្រធានាធិបតី ។

នៅថ្ងៃទី ១១ សីហា ១៩១៩ រដ្ឋធម្មនុញ្ញមួយត្រូវបានប្រកាសឲ្យប្រើ ហើយដែលមានឈ្មោះថា «*រដ្ឋធម្មនុញ្ញវៃម៉ា*» (Weimar) ព្រោះគេរៀបរដ្ឋធម្មនុញ្ញនេះនៅក្រុងវៃម៉ា ។ រដ្ឋធម្មនុញ្ញបានសង្កត់លើអធិបតេយ្យនៃប្រជាជន ហើយបានចែងឲ្យមានសភាពីរ គឺសភាតំណាងរាស្ត្រឬ *រ៉ៃតាក* (Reichstag) និងសភាតំណាងរដ្ឋ ឬ *រ៉ៃស្រាត* (Reischsrat) ។ រដ្ឋធម្មនុញ្ញបានបើកសិទ្ធិបោះឆ្នោតដល់ពលរដ្ឋទាំងពីរភេទ ចាប់ពីអាយុ ២០ ឆ្នាំឡើងទៅ ហើយបានគ្រោងទុកក្នុងកម្មវិធីរបស់ខ្លួននូវកំណែទំរង់ខ្លះ ខាងវិស័យសង្គមកិច្ច ។ ក្នុងឆ្នាំ ១៩២៥ លោកអេប៊ែបានទទួលអនិច្ចកម្ម ។ លោកហិនដិនប៊ួ (Hindenburg) ដែលជាឧត្តមសេនីយចាស់ម្នាក់ ត្រូវបានជ្រើសតាំងជាប្រធានាធិបតី ។ សម័យនេះជាសម័យប្រកបដោយលក្ខណៈប្រជាធិបតេយ្យ និងសេរីភាព តែបញ្ហាសំខាន់ៗដែលបានចោទយ៉ាងខ្លាំង ពុំបានដោះស្រាយឡើយ ។ ផ្ទុយទៅវិញ វិបត្តិសេដ្ឋកិច្ច សង្គម និងនយោបាយមានសភាពរឹតតែខ្លាំងឡើងៗជាលំដាប់ ។

ខ. សម័យទី ២

គឺជាសម័យនៃរបបផ្តាច់ការរបស់លោកអ៊ីទ្លែ ឬណាស៊ីសនិយម :

* *ជីវប្រវត្តិសង្ខេបរបស់លោកអ៊ីទ្លែ*

[illegible] អ៊ីទ្លែ [illegible] ជនសាមញ្ញម្នាក់ មានរបររកស៊ីជាជាងកំបោរ រស់នៅដោយលំបាក [illegible] (Munich) ។ សង្គ្រាមលោកលើកទី១បានផ្ទុះភ្លាម [illegible] ត្រូវបានរដ្ឋការហៅឲ្យបំរើក្នុងកងទ័ព ។ លុះ [illegible] ដោយមានឋានន្តរស័ក្តិជាពលបាលឯក ។ លោក

ជាវាគ្មិនម្នាក់ ៗ ដោយគុណសម្បត្តិនេះ លោកបានត្រូវគេចាត់ឱ្យទៅឃោសនា ក្នុងកងទ័ព ដើម្បីអូសទាញពួកនេះឱ្យចេញពីសង្គមនិយមបុលសេវិច (bolchevisme) ដែលកាន់តែរីកលូតលាស់យ៉ាងឆាប់រហ័ស ក្នុងចំណោមពលទាហាន ៗ ក្រោយមក លោកបានបង្កើតគណបក្សនយោបាយមួយមានឈ្មោះ « *សង្គមជាតិនិយម* » (National socialiste) ក្នុងប្រទេសអាឡឺម៉ង់ ៗ ស្ថានភាពនយោបាយបានធ្លាក់ចុះក្នុងអនាធិបតេយ្យពេញទី ៗ រដ្ឋមន្ត្រីម្នាក់បាននិយាយថា ប្រទេសអាឡឺម៉ង់ដូចជាផ្ទះមួយដែលនៅក្នុងនោះមានសុទ្ធតែមនុស្សឆ្កួត ៗ ចលាចលខាងនយោបាយបានផ្ទុះពេញលើផ្ទៃប្រទេស ៗ ពួកប្រតិកិរិយាទាំងឡាយបានរួបរួមនឹងកងទ័ព ហើយប្រឆាំងនឹងគំរោងកែទំរង់របស់រដ្ឋាភិបាលប្រឆាំងនឹងរដ្ឋធម្មនុញ្ញ បានប្រើគ្រប់មធ្យោបាយដើម្បីកុំឱ្យរដ្ឋាភិបាលធ្វើការកើត ព្រមទាំងបានរៀបចំការប៉ុនប៉ងធ្វើឃាតឥស្សរជនទាំងឡាយណា ដែលមាននិន្នាការប្រជាធិបតេយ្យសេរីភាព ៗលៗ គុណភាពខាងនយោបាយដែលលោកប្រធានាធិបតី *ហ៊ិនដិនប៊ួ* បានខំថែរក្សាតាំងពីដើមមកនោះ ក៏ត្រូវរលំប្រេះឆាក្នុងពេលដែលលោកអនិច្ចកម្មទៅ ៗ



*លោកអ៊ីទ្លែ (១៨៨៩-១៩៤៥)*

គណបក្សសង្គមជាតិនិយម ដែលមានលោកអ៊ីទ្លែជាអ្នកដឹកនាំ បានឡើងកាន់កាប់កិច្ចការរដ្ឋតាំងពីពេលនោះមក ៗ ជានាយករដ្ឋមន្ត្រីក្នុងឆ្នាំ ១៩៣៣ លោកអ៊ីទ្លែ បានឈានដល់កំពូលរដ្ឋតែម្តងចាប់ពីឆ្នាំ ១៩៣៤ (ជានាយករដ្ឋមន្ត្រីផង ជាប្រធានាធិបតីផង)ៗ

* *កម្មវិធីនយោបាយរបស់គណបក្សសង្គមជាតិនិយម ឬ ណាស៊ី* (Nazi)

លុះបានឡើងកាន់កាប់អំណាចជាម្ចាស់រដ្ឋអាឡឺម៉ង់ទាំងមូលពេញលក្ខណៈហើយ

លោកអ៊ីត្លែរនិងគណបក្សរបស់លោកបានបញ្ចេញកម្មវិធីនយោបាយមួយ ដែលមានចំណុចសំខាន់ៗដូចតទៅ :

— ធ្វើឲ្យសាសន៍ជាតិអាល្លឺម៉ង់មានឈាមបរិសុទ្ធ ហើយខ្លាំងពូកែ

— បណ្តុះមនោសញ្ចេតនាស្នេហាសន្តមនិងប្រពៃណីរបស់ជនជាតិអាល្លឺម៉ង់

— ប្រមូលផ្តុំជនជាតិអាល្លឺម៉ង់ទាំងអស់ ឲ្យនៅជុំវិញតែអ្នកដឹកនាំម្នាក់មានឋានៈជានាយកដែលគេឲ្យឈ្មោះថា ភុយរ័រ (Führer) *(១)*

— *ហែកសន្ធិសញ្ញាក្រុងវែរសៃ* (Versailles) ដើម្បីសំរេចនយោបាយ ត្រួតត្រាពិភពលោកទាំងមូល ។

ការសំរេចកម្មវិធីនយោបាយខាងលើ ពិសេសត្រង់ចំណុចចុងក្រោយបង្អស់បណ្តាលឲ្យមានហេតុផលជាច្រើន ចំពោះសន្តិភាពពិភពលោកៗ



*ក្បួនហែរក្បាលតាមលោកអ៊ីត្លែរ*

**របបផ្តាច់ការរបស់អ៊ីត្លែរ*

លុះបានឡើងកាន់អំណាចភ្លាម អ៊ីត្លែរ បានប្រើរបបផ្តាច់ការ ហើយសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ បានប្រែឈ្មោះជារ៉ៃទី ៣ (3ᵉ Reich) ។ គ្រប់អង្គការធំៗនៃរដ្ឋ ត្រូវលោកអ៊ីត្លែរលុបចោលទាំងអស់ ដូចជាសភាតំណាង

*(១) ពាក្យភុយរ័រជាពាក្យអាល្លឺម៉ង់មានន័យថា « មេ » តែគេចុកពាក្យនេះជាគោរមងាររបស់អ៊ីត្លែរ ដូចជាពាក្យថា « ឌូស » (duce) ប្រើជាគោរមងាររបស់លោកមូសូលីនី ។*

រាស្ត្រ សភាតំណាងរាស្ត្រ ។ គ្រប់គណបក្សនយោបាយត្រូវបិទទាំងអស់ លើកលែងតែគណបក្ស សង្គមជាតិនិយមរបស់លោកមួយប៉ុណ្ណោះ ។ ពោលដោយសង្ខេប របបផ្តាច់ការរបស់លោកអ៊ីទ្លែ មានធាតុភាពដូចតទៅ :

— លោកអ៊ីទ្លែជាអ្នកកាន់គ្រប់អំណាចរដ្ឋទាំងអស់តែម្នាក់ឯង

— គ្រប់គណបក្សដទៃទាស់ទាំងប៉ុន្មានត្រូវវិនាសសាបសូន្យ

— សិទ្ធិសេរីភាពទាំងប៉ុន្មានត្រូវលុបចោលទាំងអស់

— ចំពោះជនជាតិជ្វីប លោកអ៊ីទ្លែទុកជាជនជាតិក្រោយប្អាប់ ហើយអាឡឺម៉ង់បានសំលាប់ទាំងអស់នូវពូជពង្សជាតិនេះ ។

ដូចនេះ ខាងផ្ទៃក្នុងប្រទេស គឺជានយោបាយផ្តាច់ការមួយ ដែលមានធាតុភាពនៅគ្រប់វិស័យទាំងអស់ ហើយដែលបានដើរសាបព្រោះតាមរយៈប៉ូលិសនយោបាយ គឺក្រុម«គេស្តាប៉ូ» (Gestapo) នូវការភ័យភិតទូទាំងប្រទេស បានចាប់បញ្ចូលក្នុងពន្ធនាគារនូវគូសត្រូវនយោបាយទាំងឡាយ ហើយបានប្រើច្បាប់ព្រៃក្នុងផ្ទៃរដ្ឋអាឡឺម៉ង់ទាំងមូល ។

ចំពោះនយោបាយក្រៅប្រទេសវិញ លោកអ៊ីទ្លែដែលមានចិត្តលោភលន់ឥតឧបមានោះបានរិះរកគ្រប់មធ្យោបាយដើម្បីហែកសន្ធិសញ្ញាក្រុងវែរសៃចោល ពីព្រោះសន្ធិសញ្ញានេះជាឧបសគ្គដល់សេចក្តីប៉ុនប៉ងរបស់លោកអ៊ីទ្លែ ដែលចង់ត្រួតត្រាពិភពលោកទាំងមូល ។

ដើម្បីសំរេចនូវគោលបំណងខាងលើ លោកអ៊ីទ្លែបានស្ថាបនាឧស្សាហកម្មសឹកមួយយ៉ាងឆាប់រហ័ស បានរៀបចំកងទ័ពមួយយ៉ាងខ្លាំងពូកែ ប្រកបដោយគ្រឿងសស្ត្រាវុធយុទ្ធភណ្ឌយ៉ាងទំនើប ។ នាយទុនទាំងឡាយនៅសហរដ្ឋអាមេរិច ចក្រភពអង់គ្លេស និងប្រទេសបារាំងបានជួយលោកអ៊ីទ្លែយ៉ាងច្រើន ក្នុងការស្រោចស្រង់ស្ថាបនាសេដ្ឋកិច្ចប្រទេសអាឡឺម៉ង់ ដោយគេទាំងអស់គ្នាសង្ឃឹមថានឹងយកលោកអ៊ីទ្លែធ្វើជាឧបករណ៍នយោបាយមួយសំរាប់ទប់ទល់នឹងសហភាពសង្គមនិយមសូវៀត ។ ចំពោះលោកអ៊ីទ្លែ លោកបានអែបអបជិតស្និទ្ធនឹងបស្ចិមប្រទេស ដើម្បីជាកលល្បិចមួយសំរាប់បំរើនយោបាយរបស់ប្រទេសលោកផ្ទាល់ទៅវិញ ពោលគឺនយោបាយត្រួតត្រាពិភពលោកទាំងមូល មិនថាសហភាពសូវៀត ឬបស្ចិមប្រទេសឡើយ ។ តាមយោបល់របស់លោកអ៊ីទ្លែ ដើម្បីសំរេចនយោបាយ

ខាងលើ សហភាពសូវៀតត្រូវទុកជាបច្ចាមិត្រលេខមួយ ។

លុះរដ្ឋអ៊ីទ្លែមានកំលាំងពលំ គេក៏ប្រើនយោបាយឈ្លានពាន នយោបាយអាណានិគមតាំងពីពេលនោះមក ។ យ៉ាងណាមិញ ក្នុងខែ កុម្ភៈ ១៩៣៨ លោកអ៊ីទ្លែបានយកប្រទេសអូទ្រិសមកភ្ជាប់នឹងរដ្ឋរបស់ខ្លួន ។ នយោបាយវាតទឹកដីនេះ គេឲ្យឈ្មោះថា *អង់ស្លុស* ( Anschluss ) ។ ប៉ុន្មានខែក្រោយមក លោកអ៊ីទ្លែបានបែរទៅរកប្រទេសឆេកូស្លូវ៉ាគី (Tchécoslovaquie) ម្តងវិញ ។ ប្រទេសឆេកូស្លូវ៉ាគីបានចងសម្ព័ន្ធមិត្រជាមួយនឹងសហភាពសូវៀតនិងប្រទេសបារាំង ។ ការរំលោភលើប្រទេសនេះនឹងបង្កើតនូវវិបត្តិមិនខានៗ ការប៉ះទង្គិចមុខតែនឹងកើតមានឡើងដែរ ។ តែក្នុងសន្និសីទមួយនាក្រុងមុយនិច ( ២៩-៣០ កញ្ញា ១៩៣៨ ) មហាអំណាចខាងលិច ( អ៊ីតាលី បារាំង អង់គ្លេស ) បានសំរេចយកតំបន់ *ស៊ុយដែត* (Sudètes) នៃប្រទេសឆេកូស្លូវ៉ាគីទៅឲ្យលោកអ៊ីទ្លែ ដោយពុំបានសួររដ្ឋាភិបាលសហភាពសូវៀត និងយោបល់របស់ប្រជារាស្ត្រឆេកូស្លូវ៉ាគីផងទៀត ។

លោក *បេនេស* ( Benes ) ដែលជានាយករដ្ឋមន្ត្រីឆេកូស្លូវ៉ាគី ត្រូវបានអញ្ជើញទៅដែរ តែគេឲ្យលោកអង្គុយរង់ចាំសន្និសីទនេះ ក្នុងបន្ទប់មួយតែម្នាក់ឯង ដើម្បីចាំទទួលយកលទ្ធផលនៃការពិភាក្សា ។

កិច្ចព្រមព្រៀងនៅក្រុងមុយនិច គឺជាកិច្ចក្បត់មួយរបស់មហាអំណាចចក្រភពអង់គ្លេស អ៊ីតាលី ពិសេសរបស់បារាំង ដែលបានលក់ផលប្រយោជន៍ប្រជាជនឆេកូស្លូវ៉ាគីទៅឲ្យលោកអ៊ីទ្លែ ។ ការសមគំនិតនៃមហាអំណាចខាងលើ ដើម្បីបំពេញចិត្តលោកអ៊ីទ្លែ គឺមានគោលបំណងតែមួយ ពោលគឺ សុំអង្វរលោកអ៊ីទ្លែកុំឲ្យវាយលុកចូលក្នុងប្រទេសរបស់ខ្លួន ហើយឲ្យលោកអ៊ីទ្លែបង្វែរមុខព្រួញរបស់ខ្លួនទៅរកសហភាពសូវៀតវិញ ។

ជាចុងក្រោយបង្អស់ នៅថ្ងៃទី ១ កញ្ញា ១៩៣៩ លុះដឹងភាពទន់ខ្សោយរបស់មហាអំណាចខាងលិច គឺបារាំងនិងអង់គ្លេស លោកអ៊ីទ្លែបានបញ្ជាកងទ័ពឲ្យវាយលុកចូលប្រទេស *ប៉ូឡូញ* ដែលជាដើមហេតុនៃសង្គ្រាមលោកលើកទី ២ ។

# សំណួរ

១. វិបត្តិសេដ្ឋកិច្ចនៃប្រទេសអ៊ីតាលី ។

២. របបផ្តាច់ការរបស់លោកមូសូលីនី ។

៣. នយោបាយក្រៅប្រទេសនៃអ៊ីតាលី ។

៤. ស្ថានភាពទូទៅនៃប្រទេសអាឡឺម៉ង់ក្រោយសង្គ្រាមលោកលើកទី ១ ។

៥. និយាយអំពីការឡើងកាន់អំណាចនៃលោកអ៊ីត្លែរនិងរបបផ្តាច់ការរបស់លោក ។

៦. ចំណុចសំខាន់ៗនៃកម្មវិធីនយោបាយរបស់គណបក្សណាស៊ី ។

៧. អ្នកយល់និយមន័យនៃកិច្ចព្រមព្រៀងនាក្រុងមុយនិចដូចម្ដេចដែរ ?

# ១៧. ប្រទេសចិន និង ជប៉ុន
# ពីឆ្នាំ ១៩១៩ ដល់ ១៩៣៩

## ក. ប្រទេសចិន

គេដឹងហើយថា មកទល់នឹងដើមសតវត្សទី២០ ប្រទេសចិនពុំមានបំរែបំរួលអ្វីជាសំខាន់ឡើយ ។ របបគ្រប់គ្រង របបសង្គម និងរបបសេដ្ឋកិច្ច មានលក្ខណៈដូចជានៅក្នុងមជ្ឈិមសម័យនៅឡើយ គឺរបបសក្តិភូមិនិយមសុទ្ធសាធ ។ ប្រជាជនចិនត្រូវទទួលការជិះជាន់ពីវណ្ណៈគហបតីជាតិ ពីយោធានិយមជាតិ ហើយចាប់ពីឆ្នាំ ១៨២២ មក ពីចក្រពត្តិនិយមអន្តរជាតិទៀតផង មានជប៉ុន អង់គ្លេស បារាំង អាមេរិកាំង អាឡឺម៉ង់ៗលៗ ទំងន់នៃការជិះជាន់ខាងលើបានធ្វើឲ្យប្រជាជនចិនភ្ញាក់រលឹកក្រោកឡើងតស៊ូ ដើម្បីរំដោះខ្លួនពីនឹមដែកអាណានិគម ។ បដិវត្តន៍មួយបានផ្ទុះនៅឆ្នាំ ១៩១១ ក្រោមការដឹកនាំនៃលោក ស៊ុន យ៉ាត សេន ហើយសាធារណរដ្ឋនិយមត្រូវបានប្រកាសជារបបគ្រប់គ្រងថ្មីជំនួសអំណាចផ្តាច់ការនៃព្រះចៅអធិរាជ ។

ក្រោយមហាសង្គ្រាមលោកលើកទី ១ ចលនាស្នេហាជាតិប្រឆាំងនឹងចក្រពត្តិនិយមបានរីកលូតលាស់ពេញផ្ទៃប្រទេសចិនទាំងមូល ។ ព្រឹត្តិការណ៍សំខាន់ៗដែលប្រទេសចិនបានស្គាល់ពីឆ្នាំ ១៩១៩ ដល់ ១៩៣៩ មានជាលំដាប់ដូចតទៅ :

### ១. ពីឆ្នាំ ១៩១៩ ដល់ ១៩២៥

ក្នុងសម័យនេះ ស្ថានភាពនយោបាយនៃប្រទេសមានសភាពស្មុគស្មាញច្របូកច្របល់ មានការប្រយុទ្ធដណ្តើមអំណាចរវាងគណបក្ស រវាងក្រុមដែលចក្រពត្តិនិយមបរទេសគាំទ្រ នៅពីក្រោយខ្នងទៀតផង ពិសេស គឺសហរដ្ឋអាមេរិច ចក្រភពអង់គ្លេសនិងជប៉ុន ។

លទ្ធផលនៃការប្រកួតប្រណាំងឰដ៏ផ្ទៃក្នុងប្រទេសរវាងក្រុមយោធានិយម និងខាងក្រៅប្រទេសរវាងមហាអំណាចចក្រពត្តិនិយម បានធ្វើឲ្យស្ថានភាពសេដ្ឋកិច្ចប្រទេសចិនធ្លាក់ចុះដុនដាប បានធ្វើឲ្យប្រជាពលរដ្ឋចិនប្រទះការលំបាកវេទនាយ៉ាងខ្លាំងខ្លីត ។

គេដឹងថា ក្នុងសម័យជាមួយគ្នាខាងលើនេះ គណបក្សកុំមុយនិសចិនបានចាប់កំណើតដែរ នៅថ្ងៃ ២១ កក្កដា ១៩២១ ។ នេះជាកត្តាថ្មីមួយដ៏សំខាន់នៃជីវភាពនយោបាយចិន ។ គេដឹងបានទៀតថា ចាប់ពីពេលបដិសន្ធិភ្លាម គណបក្សកុំមុយនិសចិនបានប្រកាសយ៉ាងច្បាស់នូវគោលការណ៍នយោបាយរបស់ខ្លួនគឺ

— ការរំងាប់ការប្រយុទ្ធឰដ៏ផ្ទៃក្នុងរវាងប្រជាជនចិន

— ការរំលំក្រុមយោធានិយម ដែលជាស្តេចត្រាញ់នៅលើទឹកដី

— ការស្ថាបនាសន្តិភាពក្នុងប្រទេស

— ការបំបាត់អំពើជិះជាន់នៃចក្រពត្តិនិយមអន្តរជាតិ

— ការប្រយុទ្ធដណ្តើមយកឯករាជ្យជូនមាតុប្រទេស



លោក ចាង ខាយ ចេក

— ការស្ថាបនាឯកភាពប្រទេសឡើងវិញ ហើយស្ថាបនារបបសាធារណរដ្ឋនិយមប្រកបដោយលក្ខណៈប្រជាធិបតេយ្យ ។ល។ ដើម្បីសំរេចនូវគោលការណ៍ខាងលើ ។

គណបក្សកុំមុយនិស ដែលមានលោក ម៉ៅ សេ ទុង ជាប្រធាន បានធ្វើសហប្រតិបត្តិការយ៉ាងសកម្មជាមួយនឹងគណបក្សកួមីងតាងរបស់លោក ស៊ុន យ៉ាត សេន ។

## ២. ពីឆ្នាំ ១៩២៥ ដល់ ១៩៣៧

នៅឆ្នាំ ១៩២៥ លោក ស៊ុន យ៉ាត សេន បានទទួលមរណភាព ហើយដំណឹកនាំ

គណបក្សកួមីងតាងត្រូវបានផ្លាស់ទៅនៅក្នុងកណ្ដាប់ដៃលោក ចាង ខាយ ចេក (Tchang Kaï Chek) ដែលត្រូវជាប្អូនថ្លៃរបស់លោក ស៊ុន យ៉ាត សេន ។ ក្រោយពីបានបណ្ដេញចេញពីគណបក្សកួមីងតាងនូវសមាជិក ដែលមាននិន្នាការខាងឆ្វេង លោក ចាង ខាយ ចេក ដែលជាតំណាងវណ្ណៈគហបតីជាតិស្នេហ៍ស្និទ្ធនឹងចក្រពត្តិនិយមបរទេស បានផ្ដាច់ការទាក់ទងរបស់ខ្លួនជាមួយនឹងគណបក្សកុម្មុយនិស ជាហេតុបណ្ដាលឲ្យមានចំបាំងក្នុងស្រុកពីរលើក ពីឆ្នាំ ១៩២៦ ដល់ ១៩៣៧ ។

ក្នុងពេលជាមួយគ្នា ប្រទេសចិនបានប្រទះគ្រោះថ្នាក់មួយយ៉ាងធំ បណ្ដាលមកពីចក្រពត្តិនិយមជប៉ុន ។ ក្នុងឆ្នាំ ១៩៣១ ចក្រពត្តិនិយមជប៉ុនបានវាយប្រហារតំបន់ ម៉ាន់ជូរី (Mandchourie) ហើយត្រួតត្រាលើតំបន់នេះមួយភាគធំ ។ គណបក្សកួមីងតាងដែលជាម្ចាស់ស្រុកក្នុងសម័យនោះ ពុំបានវាយប្រហារទប់ទល់នឹងកងទ័ពជប៉ុនឡើយ ។

ផ្ទុយទៅវិញ លោក ចាង ខាយ ចេក សមគំនិតឃុបឃិតនឹងកងយោធានិយមជប៉ុន ហើយបែរមកប្រឆាំងវាយលុកទៅលើអាណាខេត្ត ដែលគណបក្សកុម្មុយនិសចិនកាន់កាប់ទៅវិញ ។ នៅខែមិថុនា ១៩៣២ កងទ័ពចាងខាយចេក ចំនួន ៥០០ ០០០ នាក់ បានទៅហ៊ុមព័ទ្ធមូលដ្ឋានបដិវត្តន៍នៃគណបក្សកុម្មុយនិស តែពុំបានសំរេចផលអ្វីឡើយ ។

## ៣. ចំបាំងទប់ទល់នឹងជប៉ុន (កក្កដា ១៩៣៧-កញ្ញា ១៩៤៥)

យើងដឹងហើយថា មូលធននិយមពិភពលោកបានធ្លងកាត់មហាវិបត្តិមួយយ៉ាងសាហាវនៅឆ្នាំ ១៩២៩ ហើយមហាវិបត្តិនេះបានជះឥទ្ធិពលអាក្រក់របស់ខ្លួន លើបណ្ដាប្រទេសមូលធននិយមពិភពលោករហូតដល់ឆ្នាំ ១៩៣៧ ជាហេតុធ្វើឲ្យប្រទេសជាស៊ិសទាំងឡាយ មានអាឡឺម៉ង់ ជប៉ុន អ៊ីតាលី បង្កសង្គ្រាមឈ្លានពានពង្រីកទឹកដី ដើម្បីដោះស្រាយវិបត្តិដែលខ្លួនកំពុងធ្លងកាត់នៅចុងបូព៌ា ។

ចក្រពត្តិជប៉ុនបានវាយលុកចូលប្រទេសចិន នៅថ្ងៃទី ៧ កក្កដា ១៩៣៧ នៅភូមិភាគខាងជើង ហើយបានប្លន់តំបន់ម៉ាន់ជូរី ដែលប្រែទៅជាអាណានិគមជប៉ុនដ៏សុខសាធ មានឈ្មោះហៅថា ម៉ាន់ជូកួ ។

ឈមមុខនឹងគ្រោះថ្នាក់នេះ គណបក្សកួមីងតាង ដោយមានការបង្ខិតពីប្រជាជនគ្រប់

ផាន់ថ្នាក់ បានព្រមព្រៀងបង្កើតរណសិរ្សរួមមួយ ជាមួយនឹងគណបក្សកុំមុយនិស ដើម្បីទប់ទល់នឹងការរាតត្បាតនៃចក្រពត្តិនិយមជប៉ុន ។ តែគេបានដឹងថា តាំងពីខែធ្នូឆ្នាំ ១៩៣៨ អ្នកដឹកនាំសំខាន់ៗនៃគណបក្សក្មីងតាង បានរត់ទៅចុះចូលជាមួយនឹងជប៉ុន ដោយសំអាងថា នេះជាមធ្យោបាយលាក់កំបាំងមួយសំរាប់ការពារប្រទេសជាតិ ។

ថ្ងៃទី ១ កញ្ញា ១៩៣៩ អ៊ីត្លែបានវាយប្រហារប្រទេសប៉ូឡូញ ។ ប្រទេសអង់គ្លេស និងប្រទេសបារាំងបានប្រកាសសង្គ្រាមនឹងប្រទេសអាឡឺម៉ង់ ។ មហាសង្គ្រាមលោកលើកទី ២ ក៏បានផ្ទុះឡើងនៅពេលនោះដែរ ។

នៅចុងបូព៌ា ប្រទេសចិនបានបន្តការតស៊ូប្រឆាំងនឹងចក្រពត្តិនិយម រហូតដល់ឆ្នាំ ១៩៤៩ ក្រោយពីបរាជ័យរបស់ជប៉ុនក្នុងមហាសង្គ្រាមលោកលើកទី ២ ។

## ខ. ប្រទេសជប៉ុន

ប្រទេសជប៉ុនបានទទួលការរីកចំរើនផុះផាលចាប់តាំងពី« *សម័យម៉ិអ៊ិយិ* » (១៨៦៨) ដោយបានផ្លាស់ប្តូររបបនយោបាយសេដ្ឋកិច្ច និងសង្គមកិច្ច ។

ម្យ៉ាងទៀត ក្នុងសង្គ្រាមលោកលើកទី ១ នៅពេលដែលប្រទេសជាគូសត្រូវកំពុងជាប់ដៃនៅអឺរ៉ុប ជប៉ុនបានឆ្លៀតយកឱកាសដ៏ប្រសើរនោះ ពង្រីកដំហររបស់ខ្លួននៅចុងបូព៌ា ប្រទេសព្រមទាំងបានពង្រីកសកម្មភាពសេដ្ឋកិច្ចរបស់ខ្លួនជាអតិបរមា ពិសេសគឺសកម្មភាពខាងសំណង់នាវា ក៏ប៉ាល់ចំបាំងដែលបានទទួលឋានៈជាលេខ ១ ក្នុងលោក ។ មុនសង្គ្រាមលោកលើកទី ២ ប្រទេសជប៉ុនជាមហាអំណាចមួយខ្លាំងពូកែបំផុតនៅចុងបូព៌ាក៏ពិតមែនហើយ តែការខ្លាំងពូកែនេះពុំអាចបិទបាំងការប្រេះឆានិងការពិបាកផ្ទៃក្នុងបានឡើយ ។ ដូចជាប្រទេសមូលធននិយមនានាក្នុងសម័យនោះដែរ ប្រទេសជប៉ុនបានពើបប្រទះវិបត្តិជាច្រើន ពិសេសគឺវិបត្តិនយោបាយ សេដ្ឋកិច្ចនិងសង្គម ដែលមានសភាពរឹតតែធ្ងន់ជាលំដាប់ ។

### ១. វិបត្តិនយោបាយ

មកទល់នឹងដើមសតវត្សទី ២០ នេះហើយក៏ដោយ លក្ខណៈនយោបាយនៃប្រទេស

ជប៉ុនក៏ពុំមានប្រែប្រួលផ្លាស់ប្តូរអ្វីឡើយ ពោលគឺមានរបបគ្រប់គ្រងជាសក្តិភូមិនៅឡើយ ។ វិធីបោះឆ្នោតជាសកល ( suffrage universel ) ត្រូវបានបញ្ចូលតាំងពីឆ្នាំ ១៩២៥ ម្ល៉េះ ក៏ប៉ុន្តែ ជីវភាពនយោបាយត្រូវបិតនៅក្នុងសភាពចង្អៀតចង្អល់ដដែល ដោយម្យ៉ាងមកពីការព្រងើយកន្តើយរបស់ប្រជាពលរដ្ឋ ដែលពុំសូវអើពើនឹងនយោបាយ ហើយដោយម្យ៉ាងទៀត មកពីមានការពុករលួយនៅពេលបោះឆ្នោតម្តងៗ ដែលត្រូវក្រុមហ៊ុនធំៗបានជះឥទ្ធិពលរបស់ខ្លួនទៅលើគណបក្សទាំងឡាយ ដូចជា មិតស៊ុយ ប៊ិតស៊ី ( Mitsu Bitshi ) មិតស៊ុ ( Mitsui ) ជាដើម ។ ស្របនឹងសកម្មភាពយ៉ាងមមាញឹកនៃក្រុមសៃបាត់ស៊ុ ( Zaibatsu ) ទាំងនោះដែលបានប្រើគ្រប់មធ្យោបាយ ដើម្បីដឹកនាំនយោបាយរដ្ឋឱ្យស្របទៅតាមផលប្រយោជន៍របស់ខ្លួន ។ អំណាចរបស់ព្រះចៅអធិរាជក៏មានសភាពចេះតែអន់ថយ ធ្លាក់ចុះបន្តិចម្តងៗរៀងរាបដែរ ។ គេអាចសន្និដ្ឋានបានថា គ្រប់រដ្ឋាភិបាលនៃប្រទេសជប៉ុនក្នុងសម័យនោះ បានបាត់បង់អំណាចរបស់ខ្លួនរកធ្វើអ្វីពុំកើតឡើយ ហើយមានតែក្រុមហ៊ុនមូលធនធំៗទេ ដែលជាអ្នកត្រួតត្រាលើសកម្មភាព និងជីវភាពនយោបាយរបស់រដ្ឋទាំងមូល ។

## ២. វិបត្តិសេដ្ឋកិច្ចនិងវិបត្តិសង្គម

ប្រទេសជប៉ុនបានប្រែក្លាយទៅជាមហាអំណាចសេដ្ឋកិច្ចមួយយ៉ាងធំ ដែលបានឆ្លៀតពេលសង្គ្រាមលោកលើកទី១ ពង្រឹងស្ថានភាពនយោបាយនិងសេដ្ឋកិច្ចរបស់ខ្លួន នៅចុងបូព៌ា ។ តែប្រទេសជប៉ុនក៏ពុំអាចចៀសវាងវិបត្តិសេដ្ឋកិច្ចនិងវិបត្តិសង្គមដែលប្រទេសនានាបានជួបប្រទះរួចមកហើយ ដូចជាចក្រភពអង់គ្លេស ប្រទេសអាល្លឺម៉ង់ សហរដ្ឋអាមេរិចជាដើម ។ ចាប់តាំងពីឆ្នាំ ១៩២០ សេដ្ឋកិច្ចប្រទេសជប៉ុនបានធ្លាក់ចុះយ៉ាងទាប ហើយវិបត្តិនេះបានបន្តរហូតដល់ឆ្នាំ ១៩៣៤ ។

រោងចក្រជាច្រើនត្រូវបិទទ្វារ ក្រុមហ៊ុនធំៗត្រូវអស់មូលធន ពីព្រោះផលិតផលខាងឧស្សាហកម្មលក់មិនចេញ មកពីប្រទេសជប៉ុនត្រូវបាត់បង់ផ្សាររបស់ខ្លួនខ្លះ ចាប់ពីឆ្នាំ ១៩២០ កម ។ ក្នុងពេលចំបាំង ចក្រភពអង់គ្លេសក្តី សហរដ្ឋអាមេរិចក្តី ប្រទេសបារាំងក្តី ពុំបានជំទាស់នឹងការរាតត្បាតយកទឹកដីរបស់ចិន ដែលជប៉ុនបានប្រព្រឹត្តនោះឡើយ ។ តែចាប់ពីឆ្នាំ ១៩២០ មក ចក្រពត្តិទាំងបីខាងលើបានប្រែប្រួលអាកប្បកិរិយារបស់ខ្លួនពីបញ្ហានេះ ហើយ

បានទាំងបង្ខំជប៉ុនឲ្យដកខ្លួនចេញពីដៃ កាវ ចូវ (Kiao Tchéou) និងពីជ្រោយសានទុង (Chan Toung) ព្រមទាំងបដិសេធការលោភលន់របស់ជប៉ុន លើតំបន់ម៉ាន់ជូរី (Mandchourie) ទៀតផង (សន្និសីទអន្តរជាតិនៅក្រុងវ៉ាស៊ិងតុន ឆ្នាំ ១៩២២) ។ ម្យ៉ាងទៀត ក្នុងពេលជាមួយគ្នានោះ ទំនិញមកពីសហរដ្ឋអាមេរិច និងពីអឺរ៉ុប បានជ្រៀតចូលមកហូរហៀរលើផ្សារនៅអាស៊ី និងបណ្ដាប្រទេសនៅចុងបូព៌ា ជាហេតុបណ្ដាលឲ្យមានការប្រណាំងប្រជែងយ៉ាងឃោរឃៅនៅលើផ្សារដែលមានជប៉ុនជាម្ចាស់ ។ មិនតែប៉ុណ្ណោះ ផ្សារនៅសហរដ្ឋអាមេរិចក្ដី នៅអឺរ៉ុបក្ដី ពុំអនុញ្ញាតឲ្យទំនិញជប៉ុនចូលបានឡើយ ។ នយោបាយទាល់ច្រក សេដ្ឋកិច្ចដុនដាប ធ្វើឲ្យការរស់នៅមានសភាពចង្អៀតចង្អល់ពេកពន់ប្រមាណ ស្ទើរតែទ្រាំពុំបាន ។ ពន្ធដារថ្លៃ បៀវត្សរ៍ស្ដួចស្ដើង កម្មកររាប់លាននាក់គ្មានការធ្វើ ទាំងនេះបង្កើតឲ្យមានចលាចលក្នុងសង្គមជាញឹកញយ ។ បាតុកម្មជាច្រើនបានផ្ទុះលើផ្ទៃប្រទេស ។ គំនិតថ្មីៗបានផ្ដួចផ្ដើមចាប់កំណើតឡើង ពិសេសគឺគំនិតសង្គមនិយមដែលរដ្ឋាភិបាលបានចាត់វិធានការបង្ក្រាបយ៉ាងម៉ឺងម៉ាត់ ។

ការវេទនាតោកយ៉ាករបស់ប្រជាជន ដែលមានចំនួនកើនច្រើនលើសលុប ហើយឆាប់រហ័សផងទៀតនោះ មានសភាពរឹតតែធ្ងន់ថែមទៀត ដោយគេទាំងអស់គ្នាពុំមានលទ្ធភាពនឹងចាកចេញទៅរកស៊ីនៅប្រទេសក្រៅ ។ ប្រជាជនជប៉ុនមានចំនួនសរុប ៥៦ លាននាក់ក្នុងឆ្នាំ ១៩២០ ៦៦ លាន ក្នុងឆ្នាំ ១៩៣២ ។ នៅឱកាសដែលស្ថានភាពប្រទេសកំពុងតែច្របូកច្របល់យ៉ាងនេះ កងទ័ពដែលមានឧត្ដមសេនីយ *តូចូ* (Tojo) ជាអ្នកដឹកនាំ *បានធ្វើរដ្ឋប្រហារ* ដណ្ដើមយកអំណាច រំលំរដ្ឋាភិបាលស្របច្បាប់ ដែលគ្មានឥទ្ធិពលអ្វីបន្តិចបន្តួចសោះ ហើយបានបង្កើតរដ្ឋាភិបាលទាហានមួយ ដែលបានកាន់កាប់គ្រប់កិច្ចការរដ្ឋទាំងអស់ ហើយដឹកនាំប្រទេសជប៉ុនឲ្យចុះក្នុងការផ្សងព្រេងមួយយ៉ាងសាហាវ ពោលគឺសង្គ្រាមលោកលើកទី ២ ។

## ៣. ចក្រពត្តិនិយមជប៉ុន

លុះប្រមូលបានគ្រប់អំណាចរដ្ឋមកក្នុងកណ្ដាប់ដៃរបស់ខ្លួនហើយ រដ្ឋាភិបាលតូចូបានប្រកាន់យកនយោបាយពង្រីកទឹកដី ។ ចក្រពត្តិនិយមជប៉ុនមានបំណងនឹងវាយយក

ប្រទេសដទៃមកធ្វើជាអាណានិគម សំរាប់ជញ្ជូនប្រជាពលរដ្ឋរបស់ខ្លួនឲ្យទៅរស់នៅទីនោះ ឬធ្វើជាផ្សារ សំរាប់ប្រមូលយកវត្ថុធាតុដើមផង និងសំរាប់លក់ទំនិញចេញពីរោងចក្ររបស់ខ្លួនផង ។ ក្នុងឆ្នាំ ១៩៣២ ប្រទេសជប៉ុនបានតាំងអាណាព្យាបាលរបស់ខ្លួនលើអាណាខេត្តម៉ាន់ជូរី ដែលគេឲ្យឈ្មោះថាម៉ាន់ជូគួ ហើយដែលជាតំបន់មួយសំបូរទៅដោយដីមានជីជាតិនិងអណ្តូងរ៉ែផ្សេងៗជាច្រើន ។ ក្រោយមក កងទ័ពជប៉ុនបានវាយប្រហាររដ្ឋម៉ុងគោលខាងក្នុង (Mongolie intérieure) ។ ចាប់តាំងពីឆ្នាំ ១៩៣៧ មក ប្រទេសជប៉ុនបានឈ្លានពានត្រួតត្រាលើទឹកដីនៃប្រទេសចិនភាគខាងជើងមួយភាគធំ បណ្តាលឲ្យមាន *សង្គ្រាមចិន-ជប៉ុន* រហូតដល់ឆ្នាំ ១៩៤៥ ។ ចក្រពត្តិនិយមជប៉ុនបានធ្វើឲ្យមហាអំណាចសហរដ្ឋអាមេរិចនិងអឺរ៉ុបព្រួយបារម្ភជាច្រើន ហើយបានធ្វើឲ្យស្ថានភាពនៅចុងបូព៌ាមានសភាពធ្ងន់ធ្ងរហូតដល់សង្គ្រាមលោកលើកទី ២ ។

## សំណួរ

១. ស្ថានភាពនៃប្រទេសចិនមុនការដឹកនាំរបស់លោកវេជ្ជបណ្ឌិត ស៊ុន យ៉ាត សេន មានលក្ខណៈដូចម្តេច ?

២. ចំណុចសំខាន់ៗនៃកម្មវិធីនយោបាយរបស់បក្សក្លូមីងតាំងនាសម័យនោះ ។

៣. អធិប្បាយដោយសង្ខេបអំពីចំបាំងទប់ទល់នឹងជប៉ុននៃប្រជាជនចិន ។

៤. ស្ថានភាពប្រទេសជប៉ុនមុនសង្គ្រាមលោកលើកទី ២ ។

៥. ជីវភាពនយោបាយនៃប្រទេសជប៉ុន ។

៦. វិបត្តិសេដ្ឋកិច្ចនិងសង្គមមុនមហាសង្គ្រាមលោកលើកទី ២ ។

៧. ចក្រពត្តិនិយមជប៉ុននៅចុងបូព៌ា ។

# ១៨. បញ្ហាសំខាន់ៗ
# នៅមុនសង្គ្រាមលោកលើកទី ២

គេដឹងហើយថា សន្ធិសញ្ញាក្រុងវែរសៃដែលបានបញ្ចប់សង្គ្រាមលោកលើកទី ១ ពុំបានដោះស្រាយឲ្យបានជ្រះស្រលះនូវគ្រប់បញ្ហា ដែលចោទឡើងក្រោយពីបរាជ័យនៃជាសិសនិយមអាឡឺម៉ង់ឡើយ ។ ឯសកម្មភាពនយោបាយអន្តរជាតិក្រោយមហាសង្គ្រាមគឺបិតនៅត្រង់ការរិះរកមធ្យោបាយដើម្បីដោះស្រាយបញ្ហាទាំងនោះ ។ តែការបណ្តែតបណ្តោយនៃមហាអំណាចខ្លះ ការសមគំនិតឃុបឃិតរបស់មហាអំណាចដទៃទៀត ការអាក់អន់មិនទុកចិត្តគ្នាទៅវិញទៅមករវាងមហាអំណាចទាំងឡាយ បានធ្វើឲ្យស្ថានភាពតានតឹង ហើយចាប់ពីឆ្នាំ ១៩៣៦ មក គ្រោះថ្នាក់មួយយ៉ាងធំបានកំហែងគំរាមលោកយើងជាថ្មីម្តងទៀត ។

ឯបញ្ហាធំៗមាន :

## ១. បញ្ហាអាឡឺម៉ង់

បញ្ហានេះមានពីរប្រភេទ :

— បញ្ហាសំណងដែលអាឡឺម៉ង់ត្រូវសង ក្រោយដែលខ្លួនទទួលបរាជ័យ

— បញ្ហាកំណត់លក្ខន្តិកៈថ្មីមួយសំរាប់ប្រទេសអាឡឺម៉ង់ ក្រោយសង្គ្រាម ។

ចំពោះបញ្ហាទី ១ ពួកបក្សសម្ព័ន្ធតំរូវប្រទេសអាឡឺម៉ង់ឲ្យសងប្រាក់ចំនួនសរុបទាំងអស់ ១៣៨ ពាន់លានម៉ាក់ជាមាស ។ ក្រោយបន្តិចមក ដោយយល់ឃើញថា ប្រទេសអាឡឺម៉ង់ពើបប្រទះនឹងការពិបាកខាងហិរញ្ញវត្ថុ គណៈកម្មាធិការពិសេសផែនការរបស់លោក *ដាវ* ( Dawes ) បានបញ្ចុះពី ១៣៨ មក ៣៨ ពាន់លានម៉ាក់ជាមាស ។ ក្រោយមកទៀត ក្នុងឆ្នាំ ១៩៣២ គេបញ្ចុះពី ៣៨ មកត្រឹម ៣ ពាន់លានម៉ាក់ប៉ុណ្ណោះ ។ *ផែនការយ៉ង់* ( Young )

ពោលគឺចាប់ពីពេលនោះមក អាឡឺម៉ង់ឈប់សងតែម្តង ។

បញ្ហានេះទាក់ទងទៅនឹងសហរដ្ឋអាមេរិចដែរ ។ យ៉ាងណាមិញ ក្នុងពេលចំបាំង បារាំង អង់គ្លេស បែលស៊ិច បានខ្ចីប្រាក់ពីសហរដ្ឋអាមេរិចជាច្រើន ។ មហាអំណាចទាំងនេះសង្ឃឹមថានឹងបានសំណងពីអាឡឺម៉ង់ យកទៅសងសហរដ្ឋអាមេរិចវិញ ។ ដោយការផ្តើមគំនិតពីអាមេរិកាំងបញ្ឈប់លែងឲ្យអាឡឺម៉ង់សង បារាំង អង់គ្លេសក៏ឈប់សងសហរដ្ឋអាមេរិចដែរ ។ សហរដ្ឋអាមេរិចមិនសប្បាយចិត្តយ៉ាងខ្លាំង ។ ក្នុងបញ្ហានេះ មានអាថ៌កំបាំងមួយគឺសហរដ្ឋអាមេរិចសមគំនិតឃុបឃិតនឹងអ៊ីទ្លែ ដើម្បីយកអ៊ីទ្លែធ្វើជាឧបករណ៍របស់គេ សំរាប់បំរើនយោបាយថ្មីគឺទប់ទល់នឹងរបបសង្គមនិយម ដែលទើបតែនឹងចាប់កំណើតដំបូងនៅប្រទេសរូស៊ី ។ ឯអ្នកដឹកនាំប្រទេសបារាំង អង់គ្លេស ដោយភ្លេចផលប្រយោជន៍របស់ប្រទេសខ្លួន ក៏បានរួមដៃជាមួយនឹងសហរដ្ឋអាមេរិចដែរ ។ មិនតែប៉ុណ្ណោះ បារាំងក្តី អង់គ្លេសក្តី បានទាំងធ្វើអន្តរាគមន៍យ៉ាងចំហ ដើម្បីជួយក្រុមប្រឆាំងនឹងបដិវត្តន៍នៅសហភាពសូវៀត ពួកម្ចាស់ដីធំៗដែលគេហៅថា *គូឡាក់* (Koulak) ប្រយោជន៍សំលាប់របបគ្រប់គ្រងថ្មីនេះ ។

បញ្ហាទី២ គឺការកំណត់លក្ខន្តិកៈថ្មីមួយចំពោះប្រទេសអាឡឺម៉ង់ ក្នុងឋានៈខ្លួនជាអ្នកចាញ់ ។ តែអាកប្បកិរិយាមហាអំណាចបស្ចិមប្រទេសបានប្រែប្រួលស្រលះក្នុងរឿងនេះ ។ ក្នុងឆ្នាំ ១៩២៥ គេបានព្រមព្រៀងគ្នាចុះហត្ថលេខាលើសន្ធិសញ្ញាមួយឈ្មោះ*សន្ធិសញ្ញាឡូកាណូ* (Locarno) ដើម្បីលើកប្រទេសអាឡឺម៉ង់ឲ្យមានឋានៈស្មើមុខនឹងគេវិញ ។ ក្នុងករណីនេះ ប្រទេសបារាំងត្រូវដកទ័ពរបស់ខ្លួនពីតំបន់រូ (Ruhr) ដែលខ្លួនបានបញ្ជូនឲ្យទៅកាន់កាប់ ក្រោយពីអាឡឺម៉ង់ផ្អាកសំណងរបស់គេក្នុងឆ្នាំ ១៩២៣-២៤ ហើយដែលជាតំបន់មួយប្រកបដោយធនធាន ជាអាយុជីវិតនៃប្រទេសអាឡឺម៉ង់ទៀតផង ។ ឯប្រទេសដទៃទៀតក៏ត្រូវដកកងទ័ពរបស់ខ្លួនចេញពីតំបន់កូឡូញ (Cologne) ដែរ ហើយប្រទេសអាឡឺម៉ង់ ត្រូវអនុញ្ញាតឲ្យចូលជាសមាជិកពេញលក្ខណៈនៃសង្គមប្រជាជាតិក្នុងឆ្នាំ ១៩២៦ ។

បំលាស់ប្តូរអាកប្បកិរិយានៃមហាអំណាចបស្ចិមទិស ពីសទៅខ្មៅដូចនេះ មានគោលបំណងតែមួយ គឺលួងលោមជាស៊ិសុអាឡឺម៉ង់ឲ្យបំពេញបេសកកម្មពិសេសមួយ ពោលគឺ

ទប់ទល់នឹងរបបសង្គមនិយមនៅសហភាពសូវៀត ។

## ២. បញ្ហានៅភូមិភាគកណ្ដាលនៃទ្វីបអឺរ៉ុបនិងបញ្ហានៅបាល់កង់

ក្រោយចំបាំង ចក្រភព*អូទ្រិស-ហុងគ្រី*ត្រូវដួលរលំ ហើយរដ្ឋថ្មីៗជាច្រើនបានចាប់កំណើតនៅតំបន់នោះ ដូចជារដ្ឋ*ឆេកូស្លូវ៉ាគី រដ្ឋរូម៉ានី រដ្ឋយូគោស្លាវី*ជាដើម ។ រីឯអាណាចក្រអូទ្រិស-ហុងគ្រីត្រូវបែកចេញជារដ្ឋពីរ គឺរដ្ឋ*អូទ្រិស*មួយ និងរដ្ឋ*ហុងគ្រី*មួយទៀត ។ ប្រទេសទាំងពីរខាងក្រោយដែលជាអ្នកចាញ់ក្នុងមហាសង្គ្រាម ពុំសុខចិត្តគោរពនិងអនុវត្តសន្ធិសញ្ញាអន្តរជាតិ សន្ធិសញ្ញាសាំងសែរម៉ាំង (Saint Germain) ឆ្នាំ ១៩១៩ និងសន្ធិសញ្ញាទ្រីយ៉ាណុង (Trianon) ឆ្នាំ ១៩២០ ហើយទទូចតវ៉ាសុំសើរើសន្ធិសញ្ញាខាងលើវិញ ព្រមទាំងកំហែងគំរាមរដ្ឋដទៃទៀតក្នុងតំបន់នោះ ។ ដោយយល់នូវគ្រោះថ្នាក់នេះ ប្រទេស *ឆេកូស្លូវ៉ាគី រូម៉ានី* និង *យូគោស្លាវី* បានព្រមព្រៀងគ្នាធ្វើអនុសញ្ញាត្រីភាគីមួយ ដែលមានបារាំងជាអ្នកជួយគាំទ្រផង ។ សន្ធិសញ្ញាបារាំង-ឆេកូស្លូវ៉ាគីធ្វើនៅឆ្នាំ ១៩២៥ សន្ធិសញ្ញាបារាំង-រូម៉ានី ឆ្នាំ ១៩២៦ សន្ធិសញ្ញាបារាំង-យូគោស្លាវី ឆ្នាំ ១៩២៧ ។ ក្នុងពេលជាមួយគ្នានោះ ប្រទេសអ៊ីតាលី និងប្រទេសអាឡឺម៉ង់បានគាំទ្រប្រទេសអូទ្រិសនិងប្រទេសហុងគ្រីដែរ ។

ដូចនេះ ភ្នក់ភ្លើងមួយបានផ្ដួចផ្ដើមចាប់កំណើតនៅតំបន់នោះ គឺភ្នក់ភ្លើងប្រកបទៅដោយគ្រោះថ្នាក់ដ៏ធំ ។

## ៣. បញ្ហានៅភូមិភាគមជ្ឈិមបូព៌ា

ក្នុងតំបន់នេះ ការភ្ញាក់រលឹកនៃប្រជាជនដែលត្រូវគេជិះជាន់ ចលនាជាតិនិយម ការប្រយុទ្ធរវាងមហាអំណាចបារាំង-អង់គ្លេស ដើម្បីស្វាបនាឥទ្ធិពលរបស់ខ្លួន បានធ្វើឲ្យស្ថានភាពនយោបាយមានសភាពតានតឹងជាខ្លាំង ។

នៅ*តួគី* លោក*មូស្តាផាកេម៉ាល* (Mustafa Kemal) ដែលគេនិយមហៅកេម៉ាលអាតាតួក (Kemal Atatürk) បានធ្វើរដ្ឋប្រហារ ហើយប្រកាសរបបសាធារណរដ្ឋនិយមនៅតួគី ។ មិនតែប៉ុណ្ណោះ ប្រទេសតួគីបានវាយដណ្ដើមយកមកជូនមាតុប្រទេសវិញនូវតំបន់ទាំងឡាយ ដែល*សន្ធិសញ្ញាស្រ្គែរ* (Sèvres) បានផ្ដល់ឲ្យទៅប្រទេស

ដទៃ ដូចជាក្រុង *ស្មៀន* (Smyrne) តំបន់*អាណាតូលី* (Anatolie) *អង់ទ្រីណូប* (Andrinople) *ត្រាស* (Thrace) ជាដើម ៗ អាកប្បកិរិយាដ៏តឹមត្រូវរបស់ប្រទេសតួគីនេះ បានធ្វើឲ្យមហាអំណាចអាណានិគមនិយមព្រួយបារម្ភយ៉ាងខ្លាំង ៗ

ប្រទេស*លីបង់* និងប្រទេស*ស៊ីរី* ត្រូវធ្លាក់នៅក្រោមកិច្ចត្រួតត្រារបស់ប្រទេសបារាំង (១៩២០) តាមអាណត្តិរបស់សង្គមប្រជាជាតិ ៗ ចំណែកឯប្រទេសអង់គ្លេសវិញ គេដណ្តើមយកបានរដ្ឋ*ប៉ាលេស្ទីន* និង*អ៊ីរ៉ាក់* តាមអាណត្តិរបស់សង្គមប្រជាជាតិដែរ ៗ ក្នុងតំបន់នេះ ការសមគំនិតនៃមហាអំណាចទាំងឡាយ ដើម្បីបង្កើតក្នុងរដ្ឋអារ៉ាប់ ប៉ាលេស្ទីន នូវមជ្ឈមណ្ឌលមួយសំរាប់ជនជាតិជ្វីប បានធ្វើឲ្យស្ថានភាពនយោបាយតានតឹងរហូតមកដល់សព្វថ្ងៃនេះ ៗ

## ៤. បញ្ហានៅចុងបូព៌ា

នៅភូមិភាគនេះ បញ្ហាធំបិតនៅលើការប្រកួតប្រជែងរវាងមហាអំណាចចក្រពត្តិនិយម ដើម្បីបែងចែកទឹកដីចិនជាថ្មី ៗ យ៉ាងណាមិញ ប្រទេសអាល្លឺម៉ង់ចាញ់ ត្រូវបាត់បង់ទឹកដីរបស់ខ្លួននៅប្រទេសចិន ទឹកដីនេះត្រូវតែយកមកចែកគ្នា ៗ ម្យ៉ាងទៀត ក្នុងពេលសង្គ្រាមចក្រពត្តិនិយម ជប៉ុនបានវាយដណ្តើមយកទឹកដីចិនជាច្រើន ជាហេតុបណ្តាលឲ្យអង់គ្លេស បារាំង ពិសេសសហរដ្ឋអាមេរិច ពុំសប្បាយចិត្តឡើយ ៗ *សន្និសីទក្រុងវ៉ាស៊ីងតុន* (១៩២១-១៩២២) ដែលមានសហរដ្ឋអាមេរិចជាអ្នកផ្តើមគំនិត បានតំរូវជប៉ុនឲ្យប្រគល់តំបន់ខ្លះជូនទៅប្រទេសចិនវិញ ដូចជាអាណាខេត្តសានទុង ដែលខ្លួនដណ្តើមយកពីអាល្លឺម៉ង់ក្នុងពេលសង្គ្រាម ៗ សន្និសីទក្រុងវ៉ាស៊ីងតុនខាងលើទុកដូចជាជោគជ័យមួយរបស់ចក្រពត្តិនិយមអាមេរិកាំង ពីព្រោះទ្រឹស្តី « *ទ្វារចំហ* » របស់អាមេរិកាំង ត្រូវមហាអំណាចដទៃទៀតដែលទាក់ទងនឹងបញ្ហាចិននេះ ទទួលស្គាល់ហើយអនុម័ត ៗ នេះជាឱកាសដ៏ប្រសើរមួយបើកឲ្យមូលធននិយមនៃសហរដ្ឋអាមេរិច ស៊ើរូងជ្រៅចូលក្នុងទឹកដីចិនចាប់ពីពេលនោះមក ៗ ទាំងនេះជាបញ្ហាធំៗទាំងឡាយ ដែលមានចោទឡើងទៅតាមតំបន់ក្រោយមហាសង្គ្រាមលោកលើកទី១ ៗ ការប្រឹងប្រែងដើម្បីដោះស្រាយបញ្ហានេះ បានប្រព្រឹត្តរហូតមកដល់ឆ្នាំ ១៩២៩ ៗ ទោះបីដំណោះស្រាយនេះពុំបានស្របទៅតាមផល

ប្រយោជន៍ផ្សេងៗរបស់ខ្លួនក៏ដោយ គេអាចសន្និដ្ឋានបានថា មកទល់នឹងឆ្នាំខាងលើនេះ ស្ថានភាពនយោបាយហាក់ដូចបានប្រទះនូវស្ថិរភាពខ្លះៗដែរ ។ តែចាប់តាំងពីឆ្នាំ ១៩២៩ ទៅដល់ឆ្នាំ១៩៣៩ ការតានតឹងអន្តរជាតិក៏បានមកគ្របដណ្ដប់លោកយើងវិញ ។ សង្គ្រាមលោកលើកទី២ ដែលផ្ទុះក្នុងឆ្នាំ១៩៣៩ គឺជាលទ្ធផលនៃទំនាស់រវាងមហាអំណាចចក្រពត្តិនិយមទាំងឡាយដែលដោះស្រាយពុំបាននូវបញ្ហារបស់ខ្លួន តាមផ្លូវនយោបាយ ។

## ៥. ស្ថានភាពពិភពលោកពីឆ្នាំ ១៩២៩ ដល់ឆ្នាំ ១៩៣៩

— នៅឆ្នាំ១៩៣១ មហាវិបត្តិមួយបានផ្ទុះនៅចុងបូព៌ា ពោលគឺប្រទេសជប៉ុនបានវាយលុកដណ្ដើមយកអាណាខេត្តម៉ាន់ជូរី ។ នៅឆ្នាំ១៩៣៣ ប្រទេសជប៉ុនបានចាកចេញពីសង្គមប្រជាជាតិ ។ កិត្យានុភាពនៃអង្គការអន្តរជាតិនេះក៏ចុះថយមួយកំរិត ដោយគ្មានមធ្យោបាយអ្វីធ្វើឱ្យការសំរេចរបស់ខ្លួនបានទទួលអនុវត្តន៍ដ៏ម៉ត់ចត់ ។

— អាឡឺម៉ង់ ដោយសំអាងទៅលើវិបត្តិសេដ្ឋកិច្ច ឈប់បង់សំណងរបស់ខ្លួន ដល់មេបំណុលទាំងឡាយ (១៩៣១) ។

— សន្និសីទ ដើម្បីរំលាយសព្វាវុធដែលមានប្រជុំនៅ*ហ្សឺណែវ* ឥតបានផលអ្វីសោះ



*ការជួបជុំនៃមេដឹកនាំធំៗនៅក្រុងមុយនិច (២៩ កញ្ញា ១៩៣៨)*

នោះបានធ្វើឲ្យបរិយាកាសអន្តរជាតិរឹតតែកករល្អក់ថែមទៀត ។

— ការឡើងកាន់អំណាចរបស់*ហ៊ីត្លែ* នៅប្រទេសអាល្លឺម៉ង់ បានធ្វើឲ្យស្ថានការណ៍មានសភាពតឹងតែងខ្លាំងថែមទៀត ។ យ៉ាងណាមិញ នៅឆ្នាំ ១៩៣៣ អាល្លឺម៉ង់បានចាកចេញពីសន្និសីទរំលាយសព្វាវុធ ពីសង្គមប្រជាជាតិ ។ នៅឆ្នាំ ១៩៣៥ ហ៊ីត្លែបានស្ថាបនាឡើងវិញនូវកាតព្វកិច្ចខាងទាហាន ក្រោយពីឈប់គោរពកិច្ចព្រមព្រៀងវែរសាយ ដែលមានចែងក្នុងសន្ធិសញ្ញាក្រុងវែរសៃ ។ នៅឆ្នាំ ១៩៣៦ ហ៊ីត្លែបានវាយលុកដណ្ដើមយកតំបន់រេណានី (Rhénanie) ដែលទុកជាតំបន់គ្មានអាវុធ តាមកិច្ចព្រមព្រៀងអន្តរជាតិ ។ នៅឆ្នាំដដែលនោះ ហ៊ីត្លែបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ ជាមួយនឹងជប៉ុន ដើម្បីប្រឆាំងនឹងកុំមុយនិសនិយម ។

ចាប់ពីឆ្នាំ ១៩៣៨ ដល់ឆ្នាំ ១៩៣៩ មានវិបត្តិធំៗបួនកើតឡើង ។ វិបត្តិបីត្រូវចប់នៅលើជោគជ័យរបស់ហ៊ីត្លែ វិបត្តិទី ៤ បានធ្វើឲ្យសង្គ្រាមលោកលើកទី ២ ផ្ទុះតែម្ដង ។

*វិបត្តិនៅអូទ្រីស* (មីនា ១៩៣៨) បណ្ដាលមកពីហ៊ីត្លែ ដែលប្រកាសភ្ជាប់ទឹកដីអូទ្រីស មកជាមួយនឹងប្រទេសអាល្លឺម៉ង់ អង់ស្លុស ។

*វិបត្តិនៅឆេកូស្លូវ៉ាគី* .— ហ៊ីត្លែបានកំណត់រយៈពេល ៨ ថ្ងៃឲ្យរដ្ឋាភិបាលឆេកូស្លូវ៉ាគី ដើម្បីភ្ជាប់តំបន់*ស៊ុយដែត* ដែលមានអាណិកជនជាតិអាល្លឺម៉ង់ មកជាមួយរដ្ឋអាល្លឺម៉ង់ៗ *សន្និសីទក្រុងមុយនិច* (២៩ កញ្ញា ១៩៣៨) បានលក់ប្រទេស*ឆេកូស្លូវ៉ាគី*ឲ្យហ៊ីត្លែ លើខ្នងប្រជារាស្ត្រ ។ យ៉ាងណាមិញ មហាអំណាចទាំងបួនដែលចូលទៅប្រជុំនោះ ពុំបានសាកសួរអ្វីបន្តិចសោះ ដល់នាយករដ្ឋមន្ត្រីឆេកូស្លូវ៉ាគី លោក*បេនេស* (Benes) ដែលគេអញ្ជើញឲ្យមកអង្គុយចាំលទ្ធផលនៃការពិភាក្សា ក្នុងបន្ទប់ខាងក្រៅ តែម្នាក់ឯង ។

យល់នូវចំណុចខ្សោយរបស់អង់គ្លេស (ឆេមប៊ឺលិន — Chamberlain) និងបារាំង (ដាឡាដ្យេ = Daladier) ហ៊ីត្លែពុំរួញរានឹងបញ្ជូនទ័ពរបស់ខ្លួនឲ្យចូលទៅវាយលុកប្រទេស*ប៉ូឡូញ*ឡើយ (១ កញ្ញា ១៩៣៩) ។ សង្គ្រាមលោកលើកទី ២ ក៏បានផ្ទុះឡើងនៅពេលនោះដែរ ។

# សំណួរ

១. សន្ធិសញ្ញាក្រុងវែសៃបង្ខំអាល្លឺម៉ង់ឲ្យធ្វើអ្វីខ្លះ ?

២. និយាយអំពីបញ្ហា នៅភូមិភាគកណ្ដាលនៃអឺរ៉ុប ។

៣. លក្ខណៈសំខាន់នៃបញ្ហានៅមជ្ឈិមបូព៌ា និងចុងបូព៌ា ។

៤. ចាប់ពីឆ្នាំ ១៩៣៨ ដល់ ១៩៣៩ មានវិបត្តិធំៗអ្វីខ្លះ ?

# ១៩. សង្គ្រាមលោកលើក ទី ២
# ឆ្នាំ១៩៣៩ - ១៩៤៥

សង្គ្រាមលោក ឆ្នាំ១៩៣៩-១៩៤៥ ដែលបានធ្វើឲ្យមនុស្សជាតិស្គាល់ការខូចខាតឥតគណនា ស្គាល់សេចក្ដីឈឺចាប់និងមរណសញ្ញាយ៉ាងអាណោចអាធ័ម គឺជាលទ្ធផលនៃនយោបាយត្រួតត្រាពិភពលោកនៃផាស៊ីសអាឡឺម៉ង់ ។ មហាអំណាចបស្ចិមប្រទេស ដែលត្រូវមានភារៈមួយយ៉ាងសំខាន់ ពុំបានប្រកាន់ឥរិយាបថរបស់ខ្លួនឲ្យបានម៉ឺងម៉ាត់ឡើយ ដើម្បីទប់ទល់នឹងនយោបាយឈ្លានពានរបស់អ៊ីទ្លេ ។ ផ្ទុយទៅវិញ មហាអំណាចទាំងនេះ ពិសេសក្នុងពេលសន្និសីទក្រុង*មុយនិច* បានលើកទឹកចិត្តផាស៊ីសអាឡឺម៉ង់ ឲ្យរឹតតែខ្លាំងក្លាថែមទៀត ជាហេតុបណ្ដាលឲ្យសង្គ្រាមលោកលើកទី ២ ផ្ទុះឡើង ។

## ១. បុព្វហេតុ

បុព្វហេតុសំខាន់ៗមានបី :

### ក. បុព្វហេតុខាងសេដ្ឋកិច្ច

ក្រោយពីការលិចលង់នៅចន្លោះឆ្នាំ ១៩២៥-១៩៣០ មក ស្ថានភាពសេដ្ឋកិច្ចអាឡឺម៉ង់បានល្ងូតលាស់រីកចំរើនយ៉ាងឆាប់រហ័ស ហើយនៅមុនសង្គ្រាម ប្រទេសអាឡឺម៉ង់បានឡើងទៅជាមហាអំណាចសេដ្ឋកិច្ចមួយយ៉ាងខ្លាំងពូកែ ក្នុងចំណោមប្រទេសនៅអឺរ៉ុប ។ នយោបាយរកផ្សារនៅគ្រប់ទិសទីក្នុងលោកយើងនេះ សំរាប់ផលិតផលឧស្សាហកម្ម ជាការចាំបាច់ដល់ប្រទេសអាឡឺម៉ង់ ។ ការប៉ុនប៉ងនៃចក្រពត្តិនិយមអាឡឺម៉ង់ ដើម្បីដណ្ដើមយកផ្សារពីមហាអំណាចអាណានិគមចក្រពត្តិនិយមអង់គ្លេស - បារាំង សហរដ្ឋអាមេរិចនៅអាស៊ី និងអាព្រិច បានជួបប្រទះនឹងការទប់ទល់វិញយ៉ាងស្វិតស្វាញពីមហាអំណាចខាងលើ ។

ខ. បុព្វហេតុខាងនយោបាយ

មូលដ្ឋាននៃនយោបាយអាល្លឺម៉ង់ គឺការត្រួតត្រាលើពិភពលោកយើងទាំងមូល ហើយជាបន្ទាន់គឺសំលាប់របបសង្គមនិយមដែលទើបនឹងបានចាប់កំណើត នៅសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត (សូមអាន ប្រទេសអាល្លឺម៉ង់ឡើងវិញ ឆ្នាំ១៩១៩-១៩៣៩ កម្មវិធីនយោបាយរបស់គណបក្សណាស៊ី) ។

គ. បុព្វហេតុខាងយោធា



រថក្រោះអាល្លឺម៉ង់

ដើម្បីសំរេចបំណងជាម្ចាស់ផែនដី និងត្រួតត្រាពិភពលោកទាំងមូល អ៊ីត្លែ ដោយមានការសមគំនិតឃុបឃិតពីមហាអំណាចចក្រពត្តិនិយមបស្ចិមប្រទេសផង បានស្តាប់នាំ*ឧស្សាហកម្មសឹកម្មួយ*យ៉ាងទូលំទូលាយ ។ យោធកម្មនៃសេដ្ឋកិច្ចមានលក្ខណៈប្រកបដោយគ្រោះថ្នាក់ជាទីបំផុត ហើយកងទ័ពអាល្លឺម៉ង់ តែក្នុងរយៈពេលមួយដ៏ខ្លី ប្រែក្លាយទៅជាកងទ័ពមួយយ៉ាងខ្លាំងពូកែ ប្រកបទៅដោយយុទ្ធភណ្ឌសព្វសារពើយ៉ាងទំនើបព្រមទាំងមានការហ្វឹកហ្វឺនវិន័យយ៉ាងតឹងរ៉ឹងជាងកងទ័ពនានាទាំងអស់នៅអឺរ៉ុប ។



11

ឃ. លេស

នៅថ្ងៃទី១ កញ្ញា ១៩៣៩ ដោយបានទទួលបង្គាប់ពីអ៊ីត្លែរ *កងទ័ពអាល្លឺម៉ង់វាយប្រហារលុកក្នុងប្រទេសប៉ូឡូញ*តែម្តង ដោយយកលេសថា កងទ័ពប៉ូឡូញបានរំលោភទន្ទ្រានព្រំដែនប្រទេសអាល្លឺម៉ង់ នៅភូមិភាគខាងលិច ។ ដោយសំអាងទៅលើលេសនេះ ផាស៊ីសនិយមអាល្លឺម៉ង់ប្រកាសសង្គ្រាមតែម្តង ។ អណ្តាតភ្លើងនៃសង្គ្រាមលោកលើកទី២ ក៏ឆេះរាលរាលនៅពេលនោះដែរ ។

## ២. លំដាប់សំខាន់ៗនៃសង្គ្រាមលោកលើកទី ២

ផាស៊ីសនិយមអាល្លឺម៉ង់ដែលជាតំណាងចក្រពត្តិនិយម ប្រកបដោយលក្ខណៈឈ្លានពានយ៉ាងឃោរឃៅបំផុត ហើយដែលមានគោលដៅឆ្ពោះទៅរកត្រួតត្រាពិភពលោកទាំងមូលនោះ បានធ្វើឲ្យសង្គ្រាមផ្ទុះនៅឆ្នាំ១៩៣៩ ។ ឯលំដាប់សំខាន់ៗនៃសង្គ្រាមលោកលើកទី២ មានដូចតទៅ :

ក. ការវាយលុកនៃកងទ័ពអាល្លឺម៉ង់ - អ៊ីតាលី - ជប៉ុន

នៅពេលចំបាំងចាប់ផ្តើម កតិកាសញ្ញាក្រុងរ៉ូម - ប៊ែរឡាំង - តូក្យូ បានផ្តើមការវាយលុកយ៉ាងសំបើម ។

ពីឆ្នាំ១៩៣៩ ដល់ឆ្នាំ១៩៤១ កងទ័ពអាល្លឺម៉ង់វាយយកបានប្រទេសប៉ូឡូញ ប្រទេសដាណឺម៉ាក ប្រទេសបែលស៊ិច ប្រទេសហូឡង់ ប្រទេសណរវែស ប្រទេសបារាំង ប្រទេសយូហ្គោស្លាវី ប្រទេសក្រិច ។ល។

នៅប្រទេសបារាំង សេនាប្រមុខ *ពេតាំង* ( Pétain ) ដែលក្នុងពេលនោះ បានឡើងធ្វើជានាយករដ្ឋមន្ត្រី បានចុះហត្ថលេខាលើយុទ្ធសន្តិភាពជាមួយអ៊ីត្លែរ ប្រគល់ប្រទេសបារាំងឲ្យកងទ័ពផាស៊ីសអាល្លឺម៉ង់ ។ ប៉ុន្តែនៅឡុងដ៍ ធានីនៃប្រទេសអង់គ្លេស ដែលជាប្រទេសតែមួយគេចផុតពីក្រញាំអាល្លឺម៉ង់ក្នុងពេលនោះ ឧត្តមសេនីយ៍ដឺហ្គោល ( De Gaulle) បានប្រកាសឲ្យប្រជាជនបារាំងបន្តការតស៊ូទប់ទល់នឹងកងទ័ពអាល្លឺម៉ង់តទៅទៀត ។

នៅរណសិរ្សខាងកើត ប្រទេសរុស្ស៊ីត្រូវកងទ័ពអាល្លឺម៉ង់វាយប្រហារក្នុងឆ្នាំ ១៩៤១ ដោយឥតមានការប្រកាសសង្គ្រាមជាមុនផង ។

នៅមហាសមុទ្រប៉ាស៊ីភិច កងទ័ពជប៉ុនដោយឥតមានការប្រកាសសង្គ្រាមដែរ បានទំលាក់គ្រាប់បែកទៅលើកងនាវាចំបាំងអាមេរិកាំង នៅ*ពែលហាប៊ី* ( pearl Harbour ) នៃរដ្ឋហាវ៉ៃ បណ្តាលឲ្យខូចខាតយ៉ាងធំណាំ ។ ការឈ្លបលួចទំលាក់គ្រាប់បែកខាងលើបាន



ធ្វើឲ្យសហរដ្ឋអាមេរិច ចូលក្នុងភ្លក់ភ្លើងសង្គ្រាម ប៉ុន្តែ ការឈ្លបទំលាក់ខាងលើ អាចឲ្យកងទ័ពជប៉ុនវាយដណ្តើម យកបានតែក្នុងរយៈពេលពីរបីខែប៉ុណ្ណោះនូវហុងកុង ភីលីពីន ឥណ្ឌូចិន សិង្ហបុរី ម៉ាឡាយូ ភូមា... ។

*មូលដ្ឋាននាវាចំបាំងនៃសហរដ្ឋអាមេរិចនៅពើលហាប៊ី ត្រូវកប៉ាល់ហោះជប៉ុនលួចបំផ្លាញ ( ធ្នូ ១៩៤១ )*

### គ. លំដាប់នៃភាពស្មើកំលាំងគ្នា

ក្រោយពីវាយប្រយុទ្ធយ៉ាងសំបើម ហើយយ៉ាងយោរយៅមក កងទ័ពរុស្ស៊ីបានវាយដណ្តើមយកក្រុង*ស្តាលីនក្រាត* ( កុម្ភៈ ១៩៤៣ ) វិញ ហើយចាប់ពីពេលនោះមក កងទ័ពបានវាយសំរុកលើកងទ័ពផាស៊ីសអាឡឺម៉ង់ បង្ខំកងទ័ពនេះឲ្យដកថយពីគ្រប់សមរភូមិទាំងអស់ ។

កងទ័ពអង់គ្លេសបានវាយច្រានកងទ័ពអ៊ីតាលីនិងអាឡឺម៉ង់ ពីប្រទេសអេស៊ីប រហូតដល់ប្រទេសទុយនីស៊ី ។ ហើយចាប់ពីទីនោះមក ដោយសារជំនួយពីកងទ័ពបារាំងនៅអាព្រិច និងកងទ័ពអាមេរិកាំង ដែលទើបត្រូវបញ្ជូនឡើងគោកនៅម៉ារ៉ុក និងនៅអាល់សេរី ទ័ពសម្ព័ន្ធមិត្តបានដេញកងទ័ពផាស៊ីសអាឡឺម៉ង់ និងអ៊ីតាលី រហូតដល់កោះស៊ីស៊ីល ( Sicile ) និងប្រទេសអ៊ីតាលីតែម្តង ។ មហាក្សត្រអ៊ីតាលី ឈមមុខនឹងស្ថានភាពនេះ



*ទ័ពរុស្ស៊ីប្រយុទ្ធនៅក្រុងស្តាលីនក្រាត ( សិសិររដូវ ១៩៤២-១៩៤៣ )*

បានផ្តាច់ចំណងពីមូសូលីនី ហើយសព្វព្រះទ័យចុះព្រះហស្តលេខាលើយុទ្ធសន្តិភាពជាមួយនឹងអង់គ្លេស និងអាមេរិកាំង ជាការបញ្ចប់សង្គ្រាមនៅអ៊ីតាលី ។

កងទ័ពជើងអាកាសរបស់អង់គ្លេសនិងអាមេរិកាំង បានបន្តការទំលាក់គ្រាប់បែកពុំឈប់ឈរទៅលើគ្រប់តំបន់ឧស្សាហកម្ម ដែលឋិតក្រោមការកាន់កាប់របស់ប្រទេសអាឡឺម៉ង់ ។ នៅពេលជាមួយគ្នានោះ ក្នុងបណ្តាប្រទេសទាំងឡាយដែលធ្លាក់ចូលក្នុងក្រញាំអ៊ីទ្លែ មានចលនាស្នេហាជាតិក្រោកឡើងកាន់អាវុធ ប្រឆាំងយ៉ាងក្លាហាននឹងកងទ័ពត្រួតត្រាអាឡឺម៉ង់ ។ ក្នុងមហាសមុទ្រប៉ាស៊ីភិច កងទ័ពជប៉ុនបានរាយថយ ដកខ្លួនចេញបន្តិចម្តងៗពីមូលដ្ឋាន ដែលខ្លួនដណ្តើមយកបាននៅពេលដើមសង្គ្រាម ។

រួមសេចក្តីមក កងទ័ពផាស៊ីសអាឡឺម៉ង់ - អ៊ីតាលី - ជប៉ុន បានរាយថយនៅគ្រប់សមរភូមិនៃរណសិរ្សទាំងអស់ ។

### គ. ការវាយលុកនៃកងទ័ពបក្សសម្ព័ន្ធ ( ១៩៤៤ )

កងទ័ពអង់គ្លេសនិងកងទ័ពអាមេរិកាំង ដែលបានប្រមូលផ្តុំនៅប្រទេសអង់គ្លេស បានឡើងគោកក្នុងឆ្នាំ ១៩៤៤ នៅតំបន់ណរម៉ង់ឌី ( Normandie ) ក្រោមបញ្ជាការនៃឧត្តម

សេនីយអាមេរិកាំងឈ្មោះ *អៃស៊ិនហោវ៉ឺ* ( Eisenhower ) ។ កងទ័ពបក្សសម្ព័ន្ធខាងលើបានវាយច្រានកងទ័ពអាល្លឺម៉ង់ដល់ក្រុងប៉ារីស ដែលត្រូវបានរំដោះក្នុងខែសីហា ១៩៤៤ ហើយរុញកងទ័ពបច្ចាមិត្រដល់ទន្លេរ៉ាំង ( Rhin ) ។ ក្នុងពេលជាមួយគ្នានោះ កងទ័ពបារាំង និងកងទ័ពអាមេរិកាំង ដែលបានឡើងគោកនៅភូមិភាគប្រូវ៉ង់ ( Provence ) បានវាយផ្ចប់កងទ័ពអាល្លឺម៉ង់តាមទន្លេរ៉ូន ( Rhône ) ។



*ទ័ពសម្ព័ន្ធមិត្តឡើងគោកនៅណរម៉ង់ឌី ( ប្រទេសបារាំង មិថុនា ១៩៤៤ )*

## ឃ. ការទំលាក់អាវុធនៃកងទ័ពផាស៊ីសអាល្លឺម៉ង់និងជប៉ុន

កងទ័ពសហរដ្ឋអាមេរិច និងកងទ័ពរុស្ស៊ីបានទៅជួបគ្នានៅទីក្រុងប៊ែរឡាំង នាថ្ងៃទី ២៥ មេសា ១៩៤៥ ។ នៅថ្ងៃទី ៣០ មេសា ហ៊ីត្លែរបានសំលាប់ខ្លួនឯងក្នុងឋានី ដែលកំពុងត្រូវភ្លើងឆេះទ្រលោម ។ នៅថ្ងៃទី ៧ ឧសភានៃឆ្នាំដដែល ប្រទេសអាល្លឺម៉ង់ត្រូវទំលាក់អាវុធចុះចាញ់ដោយឥតមានល័ក្ខខ័ណ្ឌអ្វីឡើយ ។ ប្រទេសទាំងអំបាលម៉ានដែលធ្លាក់ចូលក្នុងក្រញាំហ៊ីត្លែរ តាំងពីឆ្នាំ ១៩៣៣ និងឆ្នាំ ១៩៣៩ បានរំដោះខ្លួនរួចទាំងអស់ ហើយបានប្រកាសឯករាជ្យរៀងៗខ្លួន ។

នៅខែកញ្ញា ១៩៥៤ ប្រទេសជប៉ុនត្រូវទំលាក់អាវុធ ក្រោយពីគ្រាប់បែកបរមាណូ



*ទ័ពអាមេរិកាំងទៅពីខាងលិចនិងទ័ពរូស៊ីមកពីខាងកើត*
*ជួបគ្នានៅត្រង់ទន្លេអែល ( ប្រទេសអាល្លឺម៉ង់ )*

គឺគ្រាប់ត្រូវបានធ្លាក់ទៅលើក្រុង *ហ៊ីរ៉ូស៊ីម៉ា* ( Hiroshima ) និង *ណាហ្គាសាគី* ( Nagasaki) ។ ដូចអាល្លឺម៉ង់ ប្រទេសជប៉ុនត្រូវបាត់បង់អស់នូវទឹកដីទាំងប៉ុន្មាន ដែលខ្លួនបានដណ្តើមយកតាំងពីឆ្នាំ ១៨៩៤ ។

សង្គ្រាមលោកលើកទី ២ ក៏ត្រូវផុតរលត់ត្រឹមនេះ ។

## ៣. វិបាកនៃសង្គ្រាមលោកលើកទី ២

សង្គ្រាមលោកលើកទី២បានធ្វើឲ្យខូចខាតយ៉ាងច្រើនមហិមា ទាំងជីវិតមនុស្សទាំងសំភារៈ ។ ឯវិបាកខាងនយោបាយក៏មានសភាពមិនតិចដែរ ។

### ក. វិបាកខាងមនុស្ស

ចំបាំងឆ្នាំ ១៩៣៩ - ១៩៤៥ បានធ្វើឲ្យបាត់បង់ជីវិតមនុស្សប្រមាណ ៥៥ លាននាក់ ។ ការបាត់បង់ដ៏ច្រើននេះបណ្តាលមកពីឥទ្ធិពលនៃការទំលាក់គ្រាប់បែក បណ្តាលមកពីនយោបាយបំបាត់ពូជសាសន៍ ដែលអ៊ីត្លែរបានអនុវត្តទៅលើជនជាតិជ្វីប ព្រមទាំងមានការបាញ់សំលាប់ឬក៏ស្លាប់ដោយអាការផ្សេងៗទៀត ក្នុងពេលដែលកងទ័ពផាស៊ីសអាល្លឺម៉ង់បានវាយលុកចូលក្នុងប្រទេសរូស៊ី ។

## ខ. វិបាកខាងសំភារៈ

ការខូចខាតខាងសំភារៈគួរឲ្យស្លុតស្លន់ស្លោណាស់ដែរ ។ ការទំលាក់គ្រាប់បែក ការបាញ់រះពីលើយន្តហោះ បានធ្វើឲ្យក្រុងទាំងឡាយក្លាយទៅជាផេះ ដូចជាក្រុងហាំបួ ( Hambourg ) រ៉ូទែដាំ (Rotterdam) វ៉ាសូវី ( Varsovie ) ហើយស្ទើរតែគ្រប់ក្រុងធំៗទាំងអស់ នៃប្រទេសជប៉ុន ។

ចំពោះប្រទេសដែលធ្លាក់ចូលក្នុងក្រញាំអាល្លឺម៉ង់ក្នុងពេលចំបាំង គោលទ្រព្យទាំងអំបាលម៉ានត្រូវមហាអំណាចនេះជិះជាន់រឹបអូសមួយភាគយ៉ាងធំ ( គោលទ្រព្យខាងកសិកម្មនិងគោលទ្រព្យខាងឧស្សាហកម្ម ) ។ ក្រោយមកប្រទេសអាល្លឺម៉ង់ដែលត្រូវទទួលបរាជ័យ ហើយដែលបានបាត់បង់ទឹកដីរបស់ខ្លួនទាំងអស់ក្នុងភូមិភាគខាងកើត ដោយគេតំរូវយកភូមិភាគនោះប្រគល់ឲ្យប្រទេសប៉ូឡូញវិញ ត្រូវមហាអំណាចខាងឈ្នះរឹបអូសយកសំភារៈខាងរោងចក្ររបស់ខ្លួនវិញយ៉ាងច្រើនដែរ ។

ដោយសង្ខេប វិបាកជាបន្ទាន់ គឺការធ្លាក់ចុះដុនដាបនៃបណ្ដាប្រទេសនៅអឺរ៉ុប ។ ផ្ទុយទៅវិញ សហរដ្ឋអាមេរិចប្រែក្លាយទៅជាមហាអំណាចសេដ្ឋកិច្ចមួយយ៉ាងឆាប់រហ័ស ហើយយ៉ាងខ្លាំងពូកែទៀតផង ។

## គ. វិបាកខាងនយោបាយនិងការបាត់បង់ទឹកដី

ដោយទទួលបរាជ័យក្នុងមហាសង្គ្រាម ប្រទេសអាល្លឺម៉ង់ ប្រទេសអ៊ីតាលី និងប្រទេសជប៉ុនត្រូវបាត់បង់ទឹកដីដែលខ្លួនដណ្ដើមបានទាំងប៉ុន្មានអស់ទៅវិញ ដូចជាប្រទេសអូទ្រីស ប្រទេសឆេកូស្លូវ៉ាគី ( ភូមិភាគខាងលិច ) ប្រទេសអាល់បានី អាណាខេត្តម៉ាន់ជូរី ប្រទេសកូរេ ។ល។ ប្រទេសអាល្លឺម៉ង់ត្រូវបែងចែកជាបួនតំបន់ គឺតំបន់នៅក្រោមការត្រួតត្រាអង់គ្លេស សហរដ្ឋអាមេរិច បារាំងនិងសហភាពសូវៀត ។ ឯក្រុងប៊ែរឡាំងក៏ត្រូវបែងចែកជាបួន ដូចប្រទេសទាំងមូលដូចនោះដែរ ។

វិបាកខាងនយោបាយដ៏សំខាន់គឺ ការចាប់កំណើតនៃប្រទេសដែលកាន់របបសង្គមនិយមមួយចំនួនច្រើនទៀត គឺមានអាល្លឺម៉ង់ខាងកើត ប៉ូឡូញ ឆេកូស្លូវ៉ាគី យូហ្គោស្លាវី



*លោក ស្តាលីន លោក រូសេវ៉ែល លោក ឆឺឈីល នៅសន្និសីទក្នុងក្រុង តេហេរ៉ង់ ( វិច្ឆិកា ១៩៤៣ )*

អាល់បានី ប៊ុលការី ម៉ុងគោលក្រៅ កូរេខាងជើង ៈចិនប្រជាមានិត ។

បើនិយាយដោយសង្ខេប ចំពុំងឆ្នាំ ១៩៣៩ - ១៩៤៥ បានធ្វើឲ្យរណសិរ្សមូលធននិយមរឹតតែរៀវតូចទៅថែមទៀត នៅសល់តែ ២/៣ នៃពិភពលោក ហើយបានធ្វើឲ្យកើតនូវរបបសង្គមនិយមពិភពលោកមួយ ដែលមានកំលាំងខ្លាំងឡើងរៀងរាល់ថ្ងៃ ជាហេតុធ្វើឲ្យរបបមូលធនប្រទះវិបត្តិពុំមានឈប់ឈរឡើយ ។

## ៤. ដំណោះស្រាយនៅពេលក្រោយសង្គ្រាម

មហាអំណាចទាំងបី គឺមានសហរដ្ឋអាមេរិច សហភាពសូវៀត និងចក្រភពអង់គ្លេស ក្រោយពីបានធ្វើសន្និសីទជាច្រើនដង ចាប់តាំងពីឆ្នាំ ១៩៤៣ ដល់ឆ្នាំ ១៩៥៥ នៅក្រុងតេហេរ៉ង់ (Téhéran) យ៉ាល់តា ( Yalta) ប៉ូតស្តាំ ( Potsdam ) បានសំរេចដូចតទៅ :

ក. សហភាពសូវៀត ត្រូវបានរដ្ឋទាំងប៉ុន្មានរបស់ខ្លួន ដែលអ៊ីទ្លែដរណ្តឹមយកក្នុងពេលចំបាំង ។

ខ. គ្រប់ប្រទេសទាំងឡាយ ដែលត្រូវបាត់បង់រលាយឈ្មោះ ចាប់តាំងពីឆ្នាំ ១៩៣៨ មកដោយការភ្ជាប់ប្រទេសទាំងនោះ ចូលទៅក្នុងអាណាចក្រអាឡឺម៉ង់ ត្រូវបានទទួលស្គាល់

ឡើងវិញក្នុងក្របខ័ណ្ឌព្រំដែនចាស់របស់ខ្លួន ដូចជាប្រទេសឆេកូស្លូវ៉ាគី និងប្រទេសអូទ្រីស ជាដើម ៗ

គ. ប្រទេសអាល្លឺម៉ង់ ត្រូវបែងចែកជាបួនតំបន់ ៗ តំបន់ទាំងនោះ ត្រូវនៅក្រោមការ



*តំណាងមហាអំណាចបី នៅសន្និសីទក្រុងយ៉ាល់តា*

ត្រួតត្រានៃមហាអំណាចទាំងបួន គឺសហរដ្ឋអាមេរិច សហភាពសូវៀត ចក្រភពអង់គ្លេស និងសាធារណរដ្ឋបារាំង ៗ ក្រុងប៊ែកឡាំង ថ្វីបើឋិតនៅក្នុងតំបន់រុស្ស៊ី ក៏ត្រូវបែងចែកជាប៊ែកឡាំងខាងលិចដែរ ៗ

ឃ. សហរដ្ឋអាមេរិច ត្រូវទទួលសិទ្ធិត្រួតត្រាប្រទេសជប៉ុនតែម្នាក់ឯង ៗ ឯមហាអំណាចអាណានិគមនិយមក៏ត្រូវទទួលសិទ្ធិរឹបអូសយកទឹកដី ដែលជប៉ុនដណ្តើមក្នុងពេលសង្គ្រាមនេះដែរ គោលគឺវិលចូលមកត្រួតត្រាអាណានិគមរបស់ខ្លួនតទៅទៀត ដូចជាចក្រភពអង់គ្លេស បារាំង និង ហូឡង់ជាដើម ៗ

## ៥. ការបង្កើតអង្គការសហប្រជាជាតិ

ក្រោយពីសន្និសីទពីរលើក ធ្វើនៅក្រុងដាំបាតុនអូក (Dumbarton Oaks) ( សីហា



*វិមានអង្គការសហប្រជាជាតិ នៅញូយ៉ក*

១៩៤៤) និងនៅក្រុងសង់ប្រង់ស៊ីស្កូ (មេសា ១៩៤៥) គេបានមូលមតិស្រុះស្រួលបង្កើតអង្គការសហប្រជាជាតិដើម្បីធានាអះអាងសន្តិភាព រិះរកមធ្យោបាយរំលាយសង្គ្រាម និងលើកទឹកចិត្តឲ្យមានសហប្រតិបត្តិការអន្តរជាតិ ក្នុងគ្រប់វិស័យទាំងអស់ ។ ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួនអង្គការសហប្រជាជាតិមាន :

ក. មហាសន្និបាត ប្រចាំឆ្នាំ ដែលមានភារៈសំរាប់ធ្វើការផ្ដែផ្ដាំផ្សេងៗ ដែលទាក់ទងទៅនឹងគ្រប់បញ្ហាទាំងអស់ ដែលជាប្រយោជន៍ទូទៅ ។

ខ. ក្រុមប្រឹក្សាសន្តិសុខ ដែលមានភារៈដោះស្រាយគ្រប់បញ្ហាទាក់ទងទៅនឹងសន្តិសុខអន្តរជាតិ ។ សមាជិកមានពីរប្រភេទ គឺសមាជិកអចិន្ត្រៃយមាន ៥ (សហរដ្ឋអាមេរិច សហភាពសូវៀត ចក្រភពអង់គ្លេស បារាំង និងចិន) និងសមាជិកមិនអចិន្ត្រៃយមួយចំនួនទៀតដែលជ្រើសរើសសំរាប់តំណាងភូមិភាគក្នុងលោកយើងនេះ ។ អគ្គលេខាធិការដ្ឋាននៅក្រុងញូយ៉កមានភារៈអនុវត្តគ្រប់សេចក្ដីសំរេចនៃមហាសន្និបាត ឬក្រុមប្រឹក្សាសន្តិសុខ ឬគ្រប់អង្គការដទៃទៀតរបស់អង្គការសហប្រជាជាតិ ។

# សំណួរ

១. បុព្វហេតុនៃសង្គ្រាមលោកលើកទី ២ ។

២. ការវាយលុកនៃកងទ័ពអាល្លឺម៉ង់ អ៊ីតាលីនិងជប៉ុន ។

៣. ការវាយលុកនៃកងទ័ពបក្សសម្ព័ន្ធ ។

៤. វិបាកខាងសេដ្ឋកិច្ចនិងសំភារៈនៃសង្គ្រាមលោកលើកទី ២ ។

៥. វិបាកខាងនយោបាយ ។

៦. អង្គការសហប្រជាជាតិត្រូវបានបង្កើតនៅឯណា? ក្នុងឆ្នាំណា? មានគោលដៅសំខាន់ៗអ្វីខ្លះ ?

# ២០. មហាអំណាចខាងលិច ក្រោយសង្គ្រាមលោកលើកទី ២

ចាប់តាំងពីឆ្នាំ ១៩៤៥ មក សហរដ្ឋអាមេរិច និងសហភាពសូវៀតជាមហាអំណាចដែលដឹកនាំពិភពលោកទាំងមូល ។ ក្នុងទ្វីបអឺរ៉ុបផ្នែកខាងលិច ប្រទេសទូទៅបានរក្សាលក្ខណៈជាមូលធននិយមដដែល ឯប្រទេសឯទៀតៗនិយមរបបសង្គមនិយមទាំងអស់ ។ នៅក្រោយសង្គ្រាមលោកលើកទី ២នេះ គេសង្កេតឃើញកើតមានប្រទេសចិនថ្មីមួយនិយមលទ្ធិកុម្មុយនិស ដោយមានជំនួយពីសហភាពសូវៀត ។ ដំណើរពិភពលោកពេលនោះចេះតែជួបប្រទះមិនឈប់ឈរ នូវវិបត្តិនិងទំនាស់ផ្សេងៗ ។

## ១. សហរដ្ឋអាមេរិចពីឆ្នាំ ១៩៤៥ ដល់ឆ្នាំ ១៩៦០

ការរីកចំរើនរបស់សហរដ្ឋអាមេរិច ដែលមានតាំងពីក្នុងពេលសង្គ្រាមលោកទី ២ បានបន្តដំណើររបស់ខ្លួនរហូតមកដល់ឆ្នាំ ១៩៤៥ តែចំពោះស្ថានការណ៍ដ៏រីករាយនេះ អ្នកនយោបាយក៏ដូចជាជនសាមញ្ញដែរ តែងនឹកបារម្ភក្រែងរៀងនេះលាក់បង្កប់នូវវិបត្តិសេដ្ឋកិច្ចណាមួយ ដូចជាវិបត្តិសេដ្ឋកិច្ចនៅឆ្នាំ ១៩២០-១៩២១ ឬក៏ដូចជាវិបត្តិដ៏ធំអស្ចារ្យ នៅឆ្នាំ ១៩៣០ ។ ដើម្បីទប់ទល់នឹងបញ្ហានេះ ប្រធានាធិបតីសហរដ្ឋអាមេរិចឈ្មោះ *ទ្រូម៉ាន់*និងសភាក៏សំរេចនៅឆ្នាំ ១៩៤៦ នូវនយោបាយផ្តល់ការងារពេញលេញដល់ប្រជាជនអាមេរិកាំងដែលទុកជាមធ្យោបាយមួយ សំរាប់កំចាត់ការចុះថ្លៃអីវ៉ាន់ ។ ក្រៅពីនេះ នៅមានការរីកចំរើនខាងសង្គមកិច្ច ពិសេសចំពោះជីវភាពនៃកម្មករផ្ទាល់ ។ ម្យ៉ាងទៀត ផែនការ*ម៉ាស្សាល់* ( Marshall ) បានផ្តល់ជំនួយសេដ្ឋកិច្ចដល់អឺរ៉ុបនៅឆ្នាំ ១៩៤៩ ។ បន្ទាប់មកគេមានការព្រួយបារម្ភចំពោះវិបត្តិខ្វះ ដែលកើតមានឡើងដោយសារតែផលិតផលដែលគេធ្វើបាន ហើយអ្នកក្នុងស្រុកលែងត្រូវការ តែការនេះត្រូវរលាយសាបសូន្យទៅវិញ ដោយ

នយោបាយផ្តល់ការងារពេញលេញនៅឆ្នាំ ១៩៤៦ ហើយគាប់ជួនពេលនោះ សហរដ្ឋអាមេរិចត្រូវផ្តើមធ្វើចំបាំងនៅកូរេទៀតផង ។

ក្នុងពេលក្រោយសង្គ្រាមនេះ ប្រធានាធិបតីអាមេរិកាំង *ទ្រូម៉ាន់* និង *អៃស៊ិនហោវ៊ែរ* មានបំណងតែមួយ គឺចង់ឲ្យមានសន្តិភាពនៅក្រៅប្រទេស ធ្វើឲ្យសហរដ្ឋអាមេរិចឋិតនៅជាច្បងគេក្នុងពិភពលោកដូចកាលក្នុងសង្គ្រាម ជាពិសេសទៅទៀត ចង់ឲ្យមានការរីកចំរើនដដែល ៗ ពីឆ្នាំ ១៩៤៥ ដល់ ១៩៦០ ដើម្បីសំរេចគោលបំណងនេះ សហរដ្ឋអាមេរិចចាំប្រឹងបង្កើនកំលាំងកងទ័ពរបស់ខ្លួន និងចំណងមិត្តភាពជាមួយនឹងប្រទេសទាំងឡាយនៃលោកសេរី ។ អាស្រ័យហេតុនេះ នៅឆ្នាំ ១៩៤៩ សហរដ្ឋអាមេរិចបានបង្កើតជាមួយនឹងបណ្តាប្រទេសអឺរ៉ុបប៉ែកខាងលិចនូវបក្សសម្ព័ន្ធមួយឈ្មោះអូតង់ ( OTAN ) ជាអង្គការសន្ធិសញ្ញានៃមហាសមុទ្រអាត្លង់ទិចខាងជើង ។ នៅឆ្នាំ ១៩៥៤ សហរដ្ឋអាមេរិចក៏បានរៀបចំអង្គការមួយថ្មីទៀត សំរាប់ការពារអាស៊ីអាគ្នេយ៍ ហៅ សេអាតូ ( SEATO ) ដែលជាអង្គការសន្ធិសញ្ញានៃអាស៊ីអាគ្នេយ៍ ។



មហាក្សត្រិយានី អេលីសាបែត និងឌុចអេឌីមបួ

## ២. ចក្រភពអង់គ្លេសពីឆ្នាំ ១៩៤៥ ដល់ ឆ្នាំ ១៩៦០.

នៅលើកដំបូង ក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន ចក្រភពអង់គ្លេសបានចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការខូចខាត ដែលកើតមានឡើងក្នុងមហាសង្គ្រាមលោកលើកទី២ (ពីឆ្នាំ ១៩៣៩ ដល់ ១៩៤៥) គឺការខូចខាតខាងមនុស្ស ខាងសំភារៈ និងខាងហិរញ្ញវត្ថុ ។ ដូចនេះ គោលដៅធំបំផុតរបស់គណបក្សការងារនិយម ដែលបានទទួលឆ្នោតចូលមកកាន់កាប់រដ្ឋាភិបាលនៅឆ្នាំ ១៩៤៥ គឺរៀបចំជួសជុលការខូចខាតទាំងនេះ ដើម្បីកសាងប្រទេសឡើងវិញ ។ នយោបាយបន្ទាន់ គឺរៀបចំរោងចក្របង្កើត

ផលសំរាប់ដឹកនាំទៅក្រៅ ដើម្បីទិញត្រលប់មកវិញនូវស្បៀងអាហារនិងវត្ថុធាតុដើមជាចាំបាច់ ៗ ម្យ៉ាងទៀត គណបក្សការងារនិយម ឆ្លៀតឱកាសនេះដើម្បីកែទំរង់សេដ្ឋកិច្ចទៀតផង ៗ លុះមកដល់ឆ្នាំ ១៩៥០ កំណែទំរង់ថ្មីនេះបានផ្តល់លទ្ធផលដ៏ប្រសើរ ៗ យ៉ាងណាមិញ ស្ថានភាពសេដ្ឋកិច្ចមានដំណើរស្រួលឡើងវិញដោយរបបត្បិតត្បៀត ៗ ឯការបញ្ចូលផលិតផលផ្សេងៗ មកក្នុងប្រទេសត្រូវបានហាមឃាត់ក្នុងផ្នែកខ្លះ ៗ ម្យ៉ាងទៀត ការចុះតំលៃប្រាក់លីវ (livre) បានធ្វើឲ្យលំនាំចេញផលិតផលទៅក្រៅមានសកម្មភាពយ៉ាងខ្លាំង ៗ នៅឆ្នាំ ១៩៥១ *គណបក្សការងារនិយម* បានចាកចេញពីតំណែងរដ្ឋាភិបាល ៗ *គណបក្សអភិរក្សនិយម* ដែលមានលោក *វិនស្តុនឆឺឈីល* (Winston Churchill) ជានាយករដ្ឋមន្ត្រី បានកាន់កាប់វាសនាប្រទេស រហូតដល់ឆ្នាំ ១៩៥៥ ៗ អ្នកបន្តតំណែងនាយករដ្ឋមន្ត្រីបន្ទាប់ពីលោកវិនស្តុនមក មានលោក *អេដែន* និង *ម៉ាក់មីឡិន* ៗ ហេតុការណ៍ដែលគួរឲ្យកត់សំគាល់គឺគណបក្សអភិរក្សនិយមនេះ ពុំបានកែទំរង់សេដ្ឋកិច្ចរបស់ពួកការងារនិយមទេ លើកលែងតែក្រុមហ៊ុនជាតិខាងស្ពែក និងដំណឹកនាំតាមថ្នល់ ដែលគេដាក់ឲ្យទៅឯកជនកាន់កាប់វិញ ៗ ជាទូទៅ គណបក្សអភិរក្សនិយមទុកសេរីភាពជាច្រើនក្នុងសេដ្ឋកិច្ច ៗ សរុបសេចក្តីទៅប្រទេសអង់គ្លេស ក្នុងសម័យក្រោយសង្គ្រាមលោកលើកទី ២ អាចទប់ខ្លួនឲ្យនៅនឹងនបាន ហើយថ្វីត្បិតតែមានវិបត្តិខ្លះៗក៏ដោយ ក៏វិបត្តិនោះពុំមានសភាពធ្ងន់ដែរ ៗ

លក្ខណៈមួយទៀត ដែលគួរឲ្យកត់សំគាល់ដែរ គឺចក្រភពអង់គ្លេសបានដោះលែងប្រទេសក្នុងអាណានិគមរបស់ខ្លួន ឲ្យមានឯកភាពឡើងវិញ ដោយពុំបានប្រើកំលាំងទ័ពច្រើនឡើយ ដូចជានៅប្រទេសឥណ្ឌាជាដើម ៗ

## ៣. ប្រទេសបារាំងពីឆ្នាំ ១៩៤៥ ដល់ឆ្នាំ ១៩៦០

នៅពេលក្រោយចំបាំង ប្រទេសបារាំងឋិតនៅក្នុងស្ថានភាពខ្ទេចខ្ទីដ៏មហិមាដោយការទំលាក់គ្រាប់បែក និងការបំផ្លិចបំផ្លាញ ក្នុងពេលដែលសត្រូវចូលលុកលុយ ៗ ផលិតកម្មពុំសូវបានគ្រប់គ្រាន់ លំនាំចូលមានច្រើនសន្ធឹកសន្ធាប់ ទាំងអស់នេះជាហេតុបណ្តាលឲ្យថវិកាជាតិចុះដុនដាបយ៉ាងខ្លាំង ហើយប្រទេសបារាំងរស់ដោយសារតែអំណោយនិងដោយខ្ចីប្រាក់គេ ៗ ការខំប្រឹងប្រែងរៀបចំស្ថានភាពនេះឡើងវិញ នៅចន្លោះឆ្នាំ១៩៤៥ ទៅឆ្នាំ ១៩៤៧ ឋិតនៅលើជាតិកម្ម និងការបង្កើតប្រព័ន្ធផ្សេងៗ សំរាប់សន្តិសុខក្នុងសង្គម ៗ

ដោយមានជំនួយអាមេរិកាំង ក្នុងក្របខ័ណ្ឌផែនការម៉ាសាល់ និងសហការនៃអឺរ៉ុប បារាំងក៏អាចបង្កើនកិរិតផ្នែកឧស្សាហកម្ម និងផលិតផលគ្រប់បែបយ៉ាងចាប់តាំងពីឆ្នាំ ១៩៤៩ ។



*ប្រធានាធិបតីដឺគោលធ្វើទស្សនកិច្ច នៅតាមខេត្ត*

នៅក្រោយឆ្នាំ ១៩៥១ ថ្វីត្បិតតែមានការប្រឹងប្រែងយ៉ាងនេះក៏ដោយ ប្រទេសបារាំងនៅតែប្រទះបញ្ហាធំៗ គឺបញ្ហាផលិតផលកសិកម្មច្រើនលើសលុប (ស្រូវសាលី ស្រាទំពាំងបាយជូរ និងដំឡូង) បញ្ហាខ្វះប្រាក់ដុល្លា ចាប់តាំងពីពេលអស់ជំនួយម៉ាសាល់ និងបញ្ហាឧនភាពនៃថវិកាជាតិ ។ ហេតុដែលបណ្ដាលឱ្យមានដូចនេះ មកពីក្រោយដែលបានរួចពីចំបាំងភ្លាម បារាំងត្រូវចំណាយប្រាក់ជាច្រើនណាស់ សំរាប់បេសកកម្មខាងកងទ័ពនៅឯនាយសមុទ្រ ។ ម្ល៉ោះហើយ អីវ៉ាន់ក៏ចេះតែឡើងថ្លៃឥតឈប់ឈរដែលតំរូវឱ្យដំឡើងប្រាក់ខែ និងប្រាក់បំណាច់នៃគ្រួសារ ជាហេតុនាំឱ្យមានការពិបាកដល់លំនាំអីវ៉ាន់ទៅក្រៅ ។ នៅទីបំផុតស្ថិតិខាងចំណាយត្រូវបានបាត់បង់លំនឹង ។ ក្នុងអំឡុងពេលនោះ ប្រាក់ប្រង់បានចុះតំលៃជាច្រើនលើកច្រើនគ្រា រហូតដល់ឆ្នាំ ១៩៥៦ ទើបស្ថានភាពទូទៅនៃសេដ្ឋកិច្ចបានចាប់ផ្ដើមគ្រាន់បើឡើងវិញ ។

ប្រទេសទាំងបីនេះ ( សហរដ្ឋអាមេរិច អង់គ្លេសនិងបារាំង ) សុទ្ធតែឋិតនៅក្នុងបក្សមូលធននិយមទាំងអស់ ។ នៅក្រោយសង្គ្រាមលោកលើកទី២ ប្រទេសបារាំងនិងអង់គ្លេសបានធ្លាក់ចូលក្នុងស្ថានភាពដុនដាបជាទីបំផុត គ្រប់វិស័យទាំងអស់ ដោយការខូចខាតបណ្ដាលពីសង្គ្រាមហើយជាពិសេសទៅទៀត ប្រទេសទាំងពីរត្រូវរកដើមទុនចាប់ផ្ដើមបង្កើតផលិតផលគ្រប់បែបយ៉ាងឡើងវិញ ។ ក្នុងករណីនេះ គេត្រូវតែទទួលអំណោយខ្លះនិងខ្ចីឥណទានជាច្រើនមកពីបរទេស ។ ម្ល៉ោះហើយ ក្នុងរយៈពេលចាប់តាំងពីឆ្នាំ ១៩៤៥ដល់

ឆ្នាំ ១៩៦០ បារាំង និងអង់គ្លេសសុទ្ធតែបានស្គាល់ហើយនិងដោះស្រាយវិបត្តិដែលកើតមក

ពីសង្គ្រាមលោកលើកទី២នេះ ។ មានតែសហរដ្ឋអាមេរិចមួយទេដែលជាអ្នកផ្តល់អំណោយ

និងឥណទានគ្រប់បែបយ៉ាងដល់ប្រទេសរងគ្រោះទាំងពីរ ។ ដូចនេះ សហរដ្ឋអាមេរិចពុំបាន

ស្គាល់វិបត្តិសេដ្ឋកិច្ច ឬនយោបាយ ផ្ទុយទៅវិញ សហរដ្ឋអាមេរិចរឹតតែបានរីកចំរើនថែម

ទៀត ក្នុងគ្រប់វិស័យទាំងអស់ ជាហេតុអាចឲ្យគេរក្សាឧត្តមភាពលើពិភពលោក រហូតដល់

ឆ្នាំ ១៩៦០ ។

## សំណួរ

១. ប្រទេសអង់គ្លេស និងបារាំង នៅក្រោយសង្គ្រាមលោកលើទី២ បានស្គាល់វិបត្តិអ្វីខ្លះ? គេដោះស្រាយវិបត្តិទាំងនោះដូចម្តេចខ្លះ ?

២. ក្នុងកិច្ចការពារមិត្តភាពរបស់ខ្លួន សហរដ្ឋអាមេរិចបានបង្កើតឲ្យមានសន្ធិសញ្ញាអ្វីខ្លះ ?

៣. សហរដ្ឋអាមេរិចមានករណីយកិច្ចអ្វីខ្លះ ចំពោះប្រទេសបារាំង និងអង់គ្លេស នៅក្រោយសង្គ្រាមលោកលើកទី ២ ?

៤. នៅក្រោយសង្គ្រាមលោកលើកទី ២ សហរដ្ឋអាមេរិចចាត់ចែងយ៉ាងដូចម្តេចខ្លះ ដើម្បីចៀសវាងកុំឲ្យមានវិបត្តិសេដ្ឋកិច្ច ?

# ២១. ប្លុកសង្គមនិយម

ក្រោយសង្គ្រាមលោកលើកទី ២ សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត និងពួករដ្ឋប្រជាធិបតេយ្យប្រជាមានិតទាំងឡាយនៃទ្វីបអឺរ៉ុប បានរួមគ្នាជាប្លុកមួយដែលគេឱ្យឈ្មោះថា *ប្លុកខាងកើត* (ពិភពសង្គមនិយមនៅទ្វីបអឺរ៉ុប) ។ លក្ខណៈសំខាន់នៃពួកប្រទេសទាំងអស់នៃប្លុកខាងកើតគឺប្រទេសទាំងនោះមានគណបក្សនយោបាយតែមួយជាអ្នកដឹកនាំ គឺបក្សកុម្មុយនិស្តតាម *លទ្ធិម៉ាក្សនិយម* ។ រីឯសង្គមរបស់គេជាសង្គមមានវណ្ណៈតែមួយ (វណ្ណៈពលករ) ។ ប្រទេសទាំងនោះមានរបបសេដ្ឋកិច្ចសង្គមនិយម (គ្មានកម្មសិទ្ធិឯកជន) ហើយរដ្ឋកាន់កាប់កិច្ចការទាំងអស់ ដោយប្រតិបត្តិតាមផែនការដែលរៀបចំឡើងដើម្បីប្រយោជន៍រួម និងតំរូវទៅតាមសេចក្តីត្រូវការរបស់ជាតិ ។

## ១. សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត (ស.ស.ស.ស.)

### ក. ការកសាងជាតិជាថ្មី នៃ ស.ស.ស.ស.



នៅឆ្នាំ១៩៤៥ តុល្យការនៃសង្គ្រាមមានដូចតទៅ : មនុស្សជាង ១៧ លាននាក់ត្រូវស្លាប់ មនុស្សរាប់លានត្រូវពិការ មនុស្ស ២៥ លាននាក់ត្រូវគ្មានជំរក ។ ដីដំណាំ ពិសេសនៅតំបន់អ៊ុយក្រែន និងរ៉ុលកា ត្រូវខូចខាតខ្ទេចខ្ទី ហើយបរិក្ខារឧស្សាហកម្មនៃតំបន់ខាងលិចក៏ត្រូវបំផ្លាញអស់ដែរ ។

ចាប់ពីឆ្នាំ១៩៤៦មក មានការចាប់កសាងជាថ្មីនៃ ស.ស.ស.ស. ក្រោមកិច្ចដឹកនាំដ៏តឹងរឹងបំផុតរបស់ស្តាលីន ។ ពីឆ្នាំ១៩៤៦ ដល់ ១៩៥៥ មានផែនការ៥ឆ្នាំពីរលើក ។ ក្នុងវិស័យឧស្សាហកម្ម ផែនការទាំងនោះបានខិតខំធ្វើការឲ្យមានការរីកចំរើន ជាពិសេស ខាងឧស្សាហកម្មធុនធ្ងន់ និងឧស្សាហកម្មជាមូលដ្ឋានដើម្បីការរីកចំរើននៃវិស័យដទៃទៀត ។ ក្នុងវិស័យកសិកម្ម មានកិច្ចការធំៗក្នុងនយោបាយទឹក និងក្នុងការរៀបចំទីដីដំណាំ តែលទ្ធផលទូទៅក្នុងវិស័យនេះហាក់ដូចជាមិនទាន់ជួនល្មមនៅឡើយ ។ ការខិតខំដើម្បីឲ្យមានសេដ្ឋកិច្ចទំនើបនេះបានប្រព្រឹត្តស្របជាមួយនឹងការរីកចំរើនក្នុងវិស័យអប់រំដែរ ។ ចំនួនអ្នកបច្ចេកទេស និងកម្មាភិបាលក៏កាន់តែសំបូរឡើង ។ ឯចំនួនប្រជាជននៅទីក្រុងក៏កាន់តែចំរើនយ៉ាងឆាប់រហ័សដែរ ។



*ផ្សារសហករណ៍កុលខូស*

៦. របបគ្រប់គ្រងក្រោយលោកស្តាលីន

ក្រោយពីលោកស្តាលីនបានទទួលមរណភាពទៅ(១៩៥៣) របបគ្រប់គ្រងនៃស.ស.ស.ស. (ក្រោមការដឹកនាំរបស់*ម៉ាឡង់កូវ* ហើយចាប់ពីឆ្នាំ ១៩៥៥*គ្រូតឆេវ*) បានបន្ធូរបន្ថយ ការតឹងរឹងខ្លះនៅក្នុងប្រទេស ដោយពង្រីកផលិតកម្មនៃ គ្រឿងឧបភោគបរិភោគ ដែលធ្វើឲ្យប្រជា

រាស្ត្រ រស់នៅកាន់តែស្រួលឡើងៗ ។ ស.ស.ស.ស.បានបើកព្រំដែនឲ្យពួកបសិមប្រទេសខ្លះចូលទៅទស្សនាផង ។ ខាងក្រៅប្រទេស ឥរិយាបថស.ស.ស.ស. ក៏មានបន្ធូរបន្ថយដែរ ។

ក្នុងវិស័យសេដ្ឋកិច្ច ការរីកចំរើនចេះតែមានជាលំដាប់ ។ កំរិតនៃវឌ្ឍនភាពខាងបច្ចេកទេស និងវិទ្យាសាស្ត្រក៏កាន់តែខ្ពស់ឡើងដែរ ។ នៅខែតុលា ១៩៥៧ ស.ស.ស.ស. បានបង្ហោះជាលើកដំបូងនូវស្ពុតនិចទី១ របស់ខ្លួន ។ ចាប់ពីនោះមក គេបានស្ថាបនាផែនការធំៗ ដែលមានលក្ខណៈជាទូទៅ ហើយមានរយៈកាលវែង ដើម្បីអាចផ្លាស់ប្តូរទំរង់នៃសេដ្ឋកិច្ចជាតិ ។ ផែនការ ៧ឆ្នាំទី ១ បានត្រូវចាប់ផ្តើមអនុវត្តនៅឆ្នាំ ១៩៥៩ៗ ឯគ្រឿងឧបភោគបរិភោគកាន់តែសំបូរឡើង រីឯការបង្ខិតបង្ខំកាន់តែធូរស្រាលបន្តិចម្តងៗ សមិទ្ធិធំៗក៏ត្រូវបានសំរេចជាច្រើន ជាហេតុធ្វើឲ្យ ស.ស.ស.ស. បានឡើងឋានៈជាមហាអំណាចមួយនៅក្នុងពិភពលោកជាមួយនឹងសហរដ្ឋអាមេរិច ។

## ២. រដ្ឋប្រជាធិបតេយ្យប្រជាមានិត



ពហុយាត្រាពេលបុណ្យជាតិនៅប្រទេសប៉ូឡូញ

សន្និសីទនៅ *តេហេរ៉ង់* (Téhéran) និង *យ៉ាល់តា* (Yalta) បានសំរេចដាក់ទ្វីបអឺរ៉ុបខាងកើត ជាតំបន់ឥទ្ធិពលរបស់ ស.ស.ស.ស. ។ ភាពអន់ខ្សោយខាងសេដ្ឋកិច្ចនៃតំបន់នេះ សង្គ្រាមត្រជាក់ និងអំណាចផ្តាច់ការរបស់ស្តាលីន បានជំរុញប្រទេសនៅអឺរ៉ុបប៉ែកខាងកើតឲ្យប្រកាន់យករបប *សង្គមនិយម* (រដ្ឋប្រជាធិបតេយ្យប្រជាមានិត) ។ ប្រទេសទាំងនោះមានចំនួន៨គឺ *ប៉ូឡូញ អាឡឺម៉ង់ខាងកើត ឆេកូស្លូវ៉ាគី ហុងគ្រី យូគោស្លាវី អាល់បានី ប៊ុលការី និងរូម៉ានី* ។ ក្រោយសង្គ្រាមលោកលើកទី២ រដ្ឋទាំងនោះមានទំនាក់ទំនងទៅប្រហាក់ប្រហែលគ្នា ហើយស្របទៅតាមទំរង់របស់ ស.ស.ស.ស. ។ រដ្ឋប្រជាធិបតេយ្យប្រជាមានិតទាំងអស់អនុវត្តតាមលទ្ធិម៉ាកលេនីន និងដើរតាមមាគ៌ា ស.ស.ស.ស. ។ ចាប់ពីឆ្នាំ១៩៤៧ ដល់ ១៩៥៣ ប្រទេសទាំងនោះបានរៀបចំរបបសង្គមនិយមនៅក្នុងប្រទេសរបស់ខ្លួនក្រោមកិច្ចដឹកនាំនៃបក្សកុំមុយនិស ។ ចាប់តាំងពីឆ្នាំ ១៩៥៥ មកឧស្សាហកម្មទាំងអស់ត្រូវរដ្ឋកាន់កាប់ ។ ផែនការត្រូវរៀបចំឡើងដើម្បីលើកតំកើងកំរិតជីវភាពប្រជារាស្ត្រ ។ ការដកហូតកម្មសិទ្ធិអំពីម្ចាស់ដីមូលធនធំៗក៏ត្រូវបានសំរេចជាស្ថាពរ ។ សាសនាទាំងឡាយបានត្រូវរក្សាទុកដដែល ឲ្យតែសាសនាទាំងនោះមានការស្មោះត្រង់ចំពោះរដ្ឋ ។

រហូតដល់ឆ្នាំ ១៩៥៣ រដ្ឋប្រជាធិបតេយ្យប្រជាមានិតទាំង ៨ បានប្រកាន់ស្របគ្នាតាមលទ្ធិម៉ាកលេនីន ។ ចាប់ពីឆ្នាំនោះមក ក៏មានលេចចេញនូវភាពខុសគ្នាខ្លះ រវាងរដ្ឋទាំងនេះ ម្យ៉ាងដោយរដ្ឋទាំងនេះសុទ្ធតែមានអតីតកាលខុសគ្នា ហើយម្យ៉ាងទៀត ដោយឡែកភាពនៃការស្ថាបនារបបសង្គមនិយមពុំមានកំរិតស្មើគ្នាពីរដ្ឋមួយទៅរដ្ឋមួយឡើយ ។ ហេតុនេះហើយ បានជាប្រទេសយូគោស្លាវីបានបែកចេញពី ស.ស.ស.ស. ។ ថ្មីៗនេះប្រទេសអាល់បានីក៏បានបង្ហាញនិន្នាការបែកចេញពី ស.ស.ស.ស. ដែរ ។ រដ្ឋទាំងឡាយនៃបូកខាងកើតបានរៀបចំឲ្យមានប្រព័ន្ធមួយនៃសហប្រតិបត្តិការខាងនយោបាយ កូមុាំងផម (KOMINFORM) ដែលស្ថាបនាឡើងនៅឆ្នាំ ១៩៤៨ និងប្រព័ន្ធមួយទៀតនៃសហប្រតិបត្តិការខាងសេដ្ឋកិច្ច កូមេកុង (KOMECON) បង្កើតឡើងនៅឆ្នាំ១៩៤៩ ព្រមទាំងប្រព័ន្ធមួយទៀតនៃសហប្រតិបត្តិការខាងយោធា (កតិកាសញ្ញាក្រុងវ៉ាស្សូវី) បង្កើតឡើងនៅឆ្នាំ ១៩៥៥ ។

# សំណួរ

១. ក្រោយសង្គ្រាមលោកលើកទី២ តើ ស.ស.ស.ស. ត្រូវដោះស្រាយបញ្ហាអ្វីខ្លះ ?

២. វិធានការរបស់រដ្ឋាភិបាលស្តាលីនក្នុងវិស័យកសិកម្ម ឧស្សាហកម្ម ។

៣. តើរបបគ្រប់គ្រង ស.ស.ស.ស. ក្រោយស្តាលីនមានលក្ខណៈយ៉ាងណាខ្លះ ?

៤. តើទំរង់ទូទៅនៃរដ្ឋប្រជាធិបតេយ្យប្រជាមានិតមានលក្ខណៈយ៉ាងណាខ្លះ ?
ចាប់ពីឆ្នាំ ១៩៥៣ មក តើវិវត្តន៍របបនីមួយៗមានសភាពយ៉ាងណាដែរ ? ដោយហេតុអ្វី ?

# ២២. ប្រទេសចិន និង ប្រទេសជប៉ុន ក្រោយសង្គ្រាមលោកលើកទី ២

## ក. ប្រទេសចិន

ប្រវត្តិនយោបាយនៃចុងបូព៌ាប្រទេស ចាប់តាំងពីមហាសង្គ្រាមលោកលើកទី ២ ដុតរលត់ទៅ មានលក្ខណៈពិសេសមួយ គឺការឈានចូលក្នុងឆាកអន្តរជាតិនៃប្រទេសចិនប្រជាមានិត ដែលមានប្រជាជនប្រមាណប្រាំពីររយលាននាក់ ដឹកនាំដោយរដ្ឋាភិបាលមួយយ៉ាងទំនើបហើយមានប្រសិទ្ធិភាពផង ។ កត្តាថ្មីនេះនឹងមានទំងន់ទៅលើវាសនានៃពិភពលោកនាសម័យបច្ចុប្បន្ន ។

### ១. បរាជ័យនៃពួកចាងខាយចេក

ក្រោយសង្គ្រាមលោកលើកទី២ ប្រទេសចិនរបស់ *ចាងខាយចេក* ( Tchang Kaï-chek ) និងប្រទេសចិនរបស់ម៉ៅសេទុង ចាប់ប្រឆាំងគ្នាតទៅទៀត ។ ចាងខាយចេកត្រូវបានសហរដ្ឋអាមេរិចជួយទ្រទ្រង់ដោយសុខចិត្តផ្តល់បុព្វសិទ្ធិទាំងឡាយដល់ប្រទេសនេះ ដូចបុព្វសិទ្ធិដែលប្រទេសចិនបានផ្តល់ដល់ពួកបស្ចិមប្រទេសនៅសតវត្សទី ១៩ដែរ ។ ពួកកុំមុយនិសដែលបានពួកអ្នកស្អប់អំពើពុករលួយនិងពួកអ្នកស្អប់ការជិះជាន់បរទេសជួយគាំទ្រផង តែងបានទទួលជោគជ័យជាដរាប ។

*ម៉ៅសេទុង* បានទទួលជោគជ័យដ៏សំខាន់ដំបូងនៅក្រុង *សិនយ៉ង់* នៅថ្ងៃទី ៨ កញ្ញា ១៩៤៨ ។ ចាប់ពីពេលនោះមក ដំណើរទៅមុខរបស់កងទ័ពកុំមុយនិសឥតមានឧបសគ្គសំខាន់អ្វីរារាំងឡើយ ។ នៅថ្ងៃទី ១៥ តុលា ១៩៤៩ ការយកបានក្រុង *គួនទុង* ( Canton ) បានបញ្ចប់សង្គ្រាមនេះ ។ *សាធារណរដ្ឋចិនប្រជាមានិត* ត្រូវបាន

ប្រកាសឡើងនៅក្រុង *ប៉េកាំង* នៅថ្ងៃទី ១ តុលា ១៩៤៩ ។

## ២. ការកសាងប្រទេសចិនជាថ្មី

បញ្ហាធំៗចំពោះរបបគ្រប់គ្រងថ្មី គឺបញ្ហាទំរង់សង្គមនៅក្នុងប្រទេស ។ នៅឆ្នាំ១៩៤៣ ក្នុងចំណោមប្រជាជន ៦០២ លាននាក់ ចំនួនកសិករមានជាង ៥១០ លាននាក់ ប្រកបអាជីវកម្មនៅលើទឹកដីដ៏តូច ដែលខ្លួនត្រូវជួលគេថែមទៀត ។ ចាប់តាំងពីឆ្នាំ ១៩៤៦មក ពួកកុម្មុយនិសចាប់ចែកដីជាថ្មីដល់ប្រជាកសិករ ។ ប៉ុន្តែ បញ្ហាសង្គមនៅតែចោទខ្លាំងឡើងដដែល ម្យ៉ាងដោយចំនួនប្រជាជននៅតែកើនឡើងជាលំដាប់ ( កំណើននេះមានចំនួន ១២ លាននាក់ ក្នុងមួយឆ្នាំ ) ម្យ៉ាងទៀត ដោយសារចំបាំង (ផ្លូវរទេះភ្លើង ផ្លូវថ្នល់ កំពង់ផែ អណ្តូងរ៉ែ) ត្រូវបោះបង់ចោល ត្រូវបំផ្លាញខូចខាតអស់ ។ ជាមួយគ្នានោះ ទំនប់ទឹកទាំងឡាយក៏គ្មានត្រូវបានថែទាំដែរ ។



*ក្រុមហត្ថករចិន*

ក្នុងកិច្ចកសាងជាតិជាថ្មីនេះ ប្រទេសចិនមានសង្ឃឹមតែទៅលើប្រជាជនរបស់ខ្លួន ទៅលើជំនួយពីសហភាពសូវៀត និងពីរដ្ឋប្រជាធិបតេយ្យប្រជាមានិតទាំងឡាយ ។ នៅ

ឆ្នាំ១៩៤៩ *ចាងខាយចៀក* ដែលមានជំនួយពីសហរដ្ឋអាមេរិចផង បានបង្កើតរដ្ឋចិនជាតិនិយមមួយនៅកោះ *ថាយវ៉ាន់* ។ ចាប់ពីពេលនោះមក ពួកបស្ចិមប្រទេសក៏បញ្ឈប់ចរន្តពាណិជ្ជកម្មរបស់គេជាមួយនឹងប្រទេសចិនកុំមុយនិស ។ ពិតមែនតែមានឧបសគ្គយ៉ាងនេះក៏ដោយ ក្នុងរយៈកាលដ៏ខ្លី ប្រទេសនេះបានក្លាយទៅជាមហាអំណាចមួយក្នុងពិភពលោក ។

គណបក្សកុំមុយនិសជាអ្នកកាន់កាប់កិច្ចការរដ្ឋទាំងអស់ ហើយបានបំបាត់ក្នុងពេលយ៉ាងខ្លីនូវវណ្ណៈមូលធន ។ ជាមួយគ្នានេះ កំរិតជីវភាពប្រជាជនក៏កាន់តែឡើងខ្ពស់បន្តិចម្តងៗ តាមផែនការនានា ។ ឯបច្ចេកទេសកសិកម្ម ដំបូងឡើយ មានលំនាំដូចពីដំនាន់ដើមដែរ ប៉ុន្តែគេអាចធ្វើអាជីវកម្មលើដីថ្មីថែមទៀតបាន ព្រមទាំងអ្នកធ្វើការនេះទៀតសោតក៏មានចំនួនច្រើនដែរ ។ ទោះបីមានការប្រឹងប្រែងយ៉ាងនេះក៏ដោយ ផលិតផលកសិកម្មនៅតែពុំគ្រប់គ្រាន់ផ្ទួនល្មមនឹងពលិកម្មដែលគេបានបំពេញឡើយ ។



និស្សិតចិន

ក្នុងវិស័យឧស្សាហកម្ម ប្រទេសចិនបានបង្កើតជាបឋម នូវកម្មាភិបាលបច្ចេកទេសគ្រប់ប្រភេទ ។ រហូតដល់ឆ្នាំ១៩៥២ គ្រោះថ្នាក់ក្នុងកិច្ចការនានាមានចំនួនច្រើនណាស់ តែក្រោយមក ចំនួនគ្រោះថ្នាក់នេះក៏កាន់តែថយចុះជាលំដាប់ ដោយសារការអប់រំ ។ ក្រោយអនុវត្តន៍ផែនការប្រាំឆ្នាំលើកទី ១ (១៩៥២-១៩៥៧) រួចមក អ្នកបច្ចេកទេសសូវៀតដែលបានមកជួយក៏កាន់តែមានចំនួនថយចុះជាលំដាប់ៗតាំងពីឆ្នាំ១៩៤៩ រដ្ឋបានកាន់កាប់ឧស្សាហកម្មជាមូលដ្ឋានអណ្តូងរ៉ែ និងផលិតកម្មថាមពល ។ ឧស្សាហកម្មដទៃទៀតក៏ត្រូវរដ្ឋយកមកកាន់កាប់បន្តបន្ទាប់គ្នាទាំងអស់ក្នុងឆ្នាំ ១៩៥៩ៗ

គេបានបង្កើតជាលំដាប់លំដោយនូវតំបន់ឧស្សាហកម្មថ្មីៗទៀតជាច្រើន ជាហេតុធ្វើឲ្យវិស័យនេះបានរីកចំរើនយ៉ាងរហ័ស ៗ ក្នុងផែនការប្រាំឆ្នាំលើកទី១ ប្រទេសចិនបានពង្រីកមជ្ឈមណ្ឌលចាស់ៗ ហើយក្នុងផែនការប្រាំឆ្នាំលើកទី ២ កិច្ចការថ្មីៗត្រូវបានបង្កើតឡើងច្រើនទៀត ជាហេតុនាំឲ្យមានបំលាស់ប្រជាជនយ៉ាងខ្លាំង ៗ

## ៣. ប្រទេសចិន និងពិភពលោក

នាបច្ចុប្បន្នកាលនេះ ក្នុងផ្លូវមនោគមវិជ្ជា ប្រទេសចិនប្រជាមានិត ជាគូសត្រូវនឹងសហរដ្ឋអាមេរិច ហើយក៏ជាគូប្រឆាំងនឹង សហភាពសូវៀតដែរ ៗ ជាមួយគ្នានេះ សាធារណរដ្ឋប្រជាមានិតចិន ក៏មានទំនាក់ទំនងយ៉ាងច្រើន ជាមួយនឹងរដ្ឋទាំងឡាយនៅអាស៊ី និងអាព្រិច ដោយបានបញ្ជូនបេសកជនយ៉ាងច្រើន ទៅរដ្ឋទាំងនេះ ជាញឹកញាប់ផង ៗ សាធារណរដ្ឋប្រជាមានិតចិនបានទាក់ទងខាងផ្លូវពាណិជ្ជកម្មជាមួយនឹងរដ្ឋដទៃទៀតជាច្រើន ហើយក្នុងចំណោមរដ្ឋទាំងនោះ មានទាំងរដ្ឋនៅទ្វីបអឺរ៉ុបផងដែរ ៗ



បុណ្យជាតិរបស់ចិន

## ខ. ប្រទេសជប៉ុន

ចាប់តាំងពីខែសីហា ១៩៤៥ រហូតដល់ឆ្នាំ ១៩៤៧ ប្រទេសជប៉ុនត្រូវឋិតនៅក្រោមកិច្ចត្រួតត្រារបស់កងទ័ពអាមេរិកាំង ។ រោងចក្រដែលសេសសល់ពីសង្គ្រាម ត្រូវរុះរើមិនឲ្យដើរទៅទៀតឡើយ ។ សហជីពធំៗសែបាត់ស៊ុ ( Zaibatsu ) ក៏ត្រូវបញ្ឈប់សកម្មភាពដែរ ។ រដ្ឋធម្មនុញ្ញមួយ បែបអាមេរិកាំងត្រូវប្រកាសឡើងនៅថ្ងៃទី ៣ កញ្ញា ១៩៤៦ ។ ប្រទេសជប៉ុនជារដ្ឋប្រជាធិបតេយ្យសភាមួយ ឯព្រះចៅអធិរាជគ្រាន់តែជានិមិត្តរូបនៃរដ្ឋ និងឯកភាពជាតិប៉ុណ្ណោះ ។ ក្នុងចំណោមច្បាប់ជាមូលដ្ឋានទាំងឡាយ មានការហាមឃាត់មិនឲ្យធ្វើសង្គ្រាម មិនឲ្យបង្កើតកងយោធពលជាថ្មី មានបង្កើតគោលការណ៍នៃកំណែទំរង់ក្នុងវិស័យកសិកម្ម និងមូលភាពនៃការចែករំលែកកិច្ចការរដ្ឋការ ។



ក្នុងផ្ទះជប៉ុនសព្វថ្ងៃ

ចាប់ពីឆ្នាំ ១៩៤៧ មក ដោយមានព្រឹត្តិការណ៍អន្តរជាតិ ថ្មីកើតឡើង ( ប្រទេសចិនប្រកាន់យករបបកុំមុយនិស សង្គ្រាមត្រជាក់) កាយវិការ របស់អាមេរិកាំងចំពោះ ប្រទេសជប៉ុន ក៏ត្រូវគេប្រែ ដោយបានខិតខំជួយសេដ្ឋកិច្ចជប៉ុនឲ្យរីកចំរើន ។ ក្នុងសង្គ្រាមនៅកូរ៉េ ប្រទេសជប៉ុនទៅជាមូលដ្ឋានផ្គត់ផ្គង់កងយោធពលអាមេរិកាំង ។ ក្រោយសន្ធិសញ្ញាសន្តិភាពនៅសង់ប្រង់ស៊ីស្កូ នាថ្ងៃទី ៨ សីហា ១៩៥១ ប្រទេសជប៉ុនក៏បានទទួលឯករាជ្យ

ពេញលេញ ។ ចាប់ពីពេលនោះមកប្រទេសជប៉ុនក៏មានសកម្មភាពខាងសេដ្ឋកិច្ចយ៉ាងខ្លាំងប្រកបដោយលទ្ធផលជាក់ស្តែង និងឆាប់រហ័ស ។ សហជីពសែបាត់ជុំក៏ចាប់ផ្តើមសកម្មភាពរបស់ខ្លួន ហើយឧស្សាហកម្មជប៉ុនក៏រីកចំរើនយ៉ាងខ្លាំងក្នុងវិស័យឧស្សាហកម្មធុនធ្ងន់ ។

## សំណួរ

១. ក្រោយសង្គ្រាមលោកលើកទី ២ តើមានព្រឹត្តិការណ៍អ្វីខ្លះនៅក្នុងប្រទេសចិន ?

២. បញ្ហាធំៗអ្វីខ្លះ ដែលរដ្ឋាភិបាលកុំមុយនិសត្រូវដោះស្រាយ ក្រោយដែលសាធារណរដ្ឋប្រជាមានិតចិនត្រូវបានប្រកាសរួចហើយ ?

៣. វិធានការរបស់រដ្ឋាភិបាលកុំមុយនិសក្នុងវិស័យសង្គម កសិកម្ម ឧស្សាហកម្ម ។

៤. ទំនាក់ទំនងរវាងសាធារណរដ្ឋប្រជាមានិតចិននិងពិភពលោកក្នុងបច្ចុប្បន្នកាល ។

៥. កាយវិការរបស់សហរដ្ឋអាមេរិច ក្រោយសង្គ្រាមលោកទី ២ ។

៦. ក្រោយឆ្នាំ ១៩៤៧ តើកាយវិការនេះត្រូវកែប្រែដែរឬទេ ? ហេតុអ្វី? តើបានលទ្ធផលយ៉ាងណាខ្លះចំពោះប្រទេសជប៉ុន ?

# ២៣. ការរំដោះនៃប្រជាជនពីនឹមអាណានិគម

ក្រោយមហាសង្គ្រាមលោកលើកទី២ ស្ថានភាពថ្មីមួយបានកើតមានឡើងក្នុងលោកយើងនេះ ។ ស្ថានភាពថ្មីនិងលក្ខណៈថ្មីនេះជាកត្តាមួយដ៏ប្រសើរអនុញ្ញាតប្រជាជនទាំងឡាយនៃទ្វីបអាស៊ី អាព្រិច អាមេរិចឡាទីន ដែលនៅក្រោមនឹមអាណានិយម ឱ្យក្រោកឡើងតស៊ូ ដើម្បីរំដោះខ្លួនពីការជិះជាន់សង្កត់សង្កិនរបស់មហាអំណាចអាណានិគម ចក្រពត្តិនិយមអឺរ៉ុបនិងសហរដ្ឋអាមេរិច ដែលពីមុនសង្គ្រាមបានត្រួតត្រាដាច់មុខលើពិភពលោកយើងទាំងមូល ។

អណ្តាតភ្លើងនៃ*មហាចលនាសេរីភាពជាតិ* បានឆេះឆួលរាលពាសពេញទ្វីបអាស៊ីអាព្រិច អាមេរិចឡាទីន ហើយបានប្រយុទ្ធដោយឥតចុះញ៉មទប់ទល់ប្រឆាំងនឹងការពួតកំលាំងចក្រពត្តិនិយមអន្តរជាតិ ដើម្បីទាមទារឯករាជ្យនិងអធិបតេយ្យភាពជូនជាតិមាតុប្រទេស ។

## ១. ការរំដោះនៃប្រជាជនអាស៊ី

នៅភូមិភាគនេះ ការត្រួតត្រាជិះជាន់នៃមហាអំណាចអាណានិគម ចក្រពត្តិនិយមនៃបណ្តាបស្ចិមប្រទេស ដែលមានសភាពរង្គោះរង្គើជាខ្លាំង តាំងពីមុនឆ្នាំ១៩៣៩ មកស្រាប់នោះ ក៏ពុំអាចរស់រានមានជីវិតទៅទៀតបានឡើយ ។ ក្នុងភូមិភាគអាស៊ីប៉ែកអាគ្នេយ៍ ប្រជាជននៃតំបន់នេះបានក្រោកឡើងកាន់អាវុធ ប្រឆាំងនឹងការវិលត្រលប់មកវិញនៃមហាអំណាចអាណានិគមនិយមចាស់ ក្រោយពីកងទ័ពផាស៊ីសជប៉ុនទំលាក់អាវុធ គឺមានប្រទេសហូឡង់ អង់គ្លេស បារាំងជាដើម ។ គឺដោយសារការតស៊ូស្វិតស្វាញនេះហើយ ទើប*ប្រទេសឥណ្ឌា ប្រទេសភូមា ប្រទេសឥណ្ឌូនេស៊ី* ហើយនិង*បណ្តាប្រទេសក្នុង*

*ឧបទ្វីបឥណ្ឌូចិន* ដណ្ដើមបានយកមកវិញ នូវឯករាជ្យ សេរីភាព និងអធិបតេយ្យភាពរបស់ខ្លួន ៗ

**ក. ការរំដោះនៃប្រទេសឥណ្ឌា**

ប្រទេសឥណ្ឌាបានធ្លាក់ចូលក្នុងក្រញាំអាណានិគមនិយមចក្រភពអង់គ្លេស តាំងពីឆ្នាំ ១៨៥៨មម៉្លេះ ៗ ការជិះជាន់យ៉ាងឃោរឃៅលើប្រទេសឥណ្ឌាដោយអាណានិគមនិយមអង់គ្លេសបានធ្វើឲ្យកើតមហាចលនាជាតិនិយមមួយ ដឹកនាំដោយគណបក្សសមាជ (គណបក្សនេះកើតនៅឆ្នាំ ១៨៨៥ ) ហើយដែលមានលោកមហាត្មគន្ធីជាអគ្គមគ្គុទ្ទេសក៍ ៗ កាលមុនសង្គ្រាមលោកលើកទី ២ ចលនានេះទាមទារតែកំណែទំរង់នៃរបបគ្រប់គ្រងរបស់អាណានិគមនិយមអង់គ្លេសប៉ុណ្ណោះ ពោលគឺគ្រាន់តែសុំឲ្យមានស្វ័យភាព ក្នុងក្របខ័ណ្ឌចក្រភពអង់គ្លេសដដែល ៗ តែនៅពេលក្រោយសង្គ្រាម ចលនាខាងលើប្រែក្លាយទៅជាមហាចលនាប្រជាជនធ្វើការតស៊ូទាមទារឯករាជ្យពេញលក្ខណៈតែម្ដង ៗ

ការតស៊ូប្រយុទ្ធដើម្បីរំដោះជាតិមាតុប្រទេសនៃចលនានេះ បានទទួលការឧបត្ថម្ភពី



*លោកនេរុ ( ឆ្វេង ) លោកមហាត្មគន្ធី ( ស្ដាំ )*

ប្រជាជនគ្រប់ស្រទាប់ជាន់ថ្នាក់ក្នុងប្រទេស និងការគាំទ្រយ៉ាងកក់ក្តៅពីគ្រប់បណ្តាប្រទេសស្នេហាសន្តិភាព យុត្តិធម៌ ពិសេសពីសហភាពសូវៀត និងបណ្តាប្រទេសក្នុងប្លុកសង្គមនិយមទាំងមូល ។ ដោយពុំអាចទប់ទល់បាននឹងមហាចលនាខាងលើ អាណានិគមនិយមអង់គ្លេសត្រូវបង្ខំចិត្តប្រគល់ឯករាជ្យពេញលេញដល់ប្រទេសឥណ្ឌា ក្នុងឆ្នាំ ១៩៤៧ ប៉ុន្តែ ការដណ្តើមឯករាជ្យបានមកវិញនេះ គឺបានសំរេចដោយអាណោចអាធ័ម ។ យ៉ាងណាមិញ ប្រទេសឥណ្ឌាត្រូវបានបែងចែកជារដ្ឋពីរ : ប៉ាគីស្ថាន និងសហភាពឥណ្ឌា ។ មុននឹងចាកចេញពីប្រទេសឥណ្ឌា អាណានិគមនិយមអង់គ្លេសបានទុកអន្ទាក់មួយ ពោលគឺ



លោកសូកាណូ

*«បញ្ហាកាស្មៀ»* ។ យើងពុំបាននិយាយផងទេ នូវការព្រាត់ប្រាស ការកាប់សំលាប់ ការបាត់បង់ជីវិត នៃប្រជាជនរាប់សែននាក់ ដែលជាវិបាកនៃការបែងចែកទឹកដីប្រទេសឥណ្ឌា ហើយដែលអាណានិគមនិយមអង់គ្លេសជាអ្នកទទួលខុសត្រូវទាំងស្រុង ។

**ខ. ការរំដោះនៃប្រជាជនឥណ្ឌូនេស៊ី**

ប្រទេសឥណ្ឌូនេស៊ីបានធ្លាក់ខ្លួនក្រោមការត្រួតត្រា នៃអាណានិគមនិយមហូឡង់ តាំងពីឆ្នាំ១៦០២ ។ ការជិះជាន់យ៉ាងឃោរឃៅ ទៅលើប្រទេសឥណ្ឌូនេស៊ីជាទំព័រមួយដ៏ខ្មៅងងឹតនៃអាណានិគមនិយម ហូឡង់ ។ ការជិះជាន់ខាងលើដោយភ្ជាប់នឹងនយោបាយ រើសអើងពណ៌

សំបុរ ដែលអាណានិគមនិយមហូឡង់បានប្រកាន់នោះ បានធ្វើឲ្យជនជាតិឥណ្ឌូនេស៊ីរងទុក្ខវេទនាជុនដាបលំបាកវេតាកយ៉ាកយ៉ាងក្រៃលែង ។ ដោយអត់ទ្រាំពុំបាននឹងអំពើព្រៃផ្សៃអមនុស្សធម៌ ប្រជាជនឥណ្ឌូនេស៊ីក្រោកឡើងតស៊ូយ៉ាងក្លាហានប្រឆាំងនឹងអំណាចត្រួតត្រា ។ គណបក្សនយោបាយជាច្រើនបានចាប់កំណើតឡើង ដើម្បីដឹកនាំការប្រយុទ្ធតស៊ូរបស់ប្រជាជនឥណ្ឌូនេស៊ី មានគណបក្សអ៊ីស្លាម ឆ្នាំ ១៩១១ គណបក្សកុម្មុយនិស្តឆ្នាំ ១៩២១ និងគណបក្សជាតិនិយមឥណ្ឌូនេស៊ី ។ ទាំងអស់គ្នា គេបានរួបរួមជាធ្លុងមួយតស៊ូដើម្បីឯករាជ្យជាតិ ។ ក្រោយមហាសង្គ្រាមលោកលើកទី២ ថ្វីបើមានជំនួយយ៉ាងស្កុកស្គម្ភពីចក្រពត្តិនិយមអាមេរិកាំង និងអង់គ្លេស ប្រទេសហូឡង់ពុំអាចទប់ទល់នឹងចលនាសេរីភាពជាតិឥណ្ឌូនេស៊ីបានឡើយ ។ ក្រោយពេលដែលកងទ័ពផាស៊ីសជប៉ុនទំលាក់អាវុធក្នុងឆ្នាំ ១៩៤៥ លោក*ស៊ូកាណូ* បានប្រកាសឯករាជ្យនៅថ្ងៃទី ១៧ សីហា ១៩៤៥ ។ ប៉ុន្តែ ដល់ឆ្នាំ១៩៤៩ ទើបឯករាជ្យពេញលេញត្រូវបានសំរេចជាស្ថាពរ ។ ក្រោយមក រដ្ឋាភិបាលឥណ្ឌូនេស៊ីបានប្រកាសផ្តាច់ចំណងប្រទេសរបស់ខ្លួនចេញពីសហភាពហូឡង់-ឥណ្ឌូនេស៊ី ក្នុងខែ សីហា ១៩៥៤ ។

### គ. ការរំដោះនៃប្រទេសភូមា

ប្រទេសភូមាត្រូវធ្លាក់ខ្លួនចូលក្នុងរបបអាណានិគមនិយមអង់គ្លេសក្នុងឆ្នាំ ១៨៨០ ។ នៅប្រទេសភូមាក៏ដូចជានៅបណ្តាប្រទេសដទៃ ដែលត្រូវគេជិះជាន់ដែរ ការតស៊ូដើម្បីសេរីភាពជាមគ្គានសន្ទុះខ្លាំងក្លា ពិសេសចាប់ពីក្រោយសង្គ្រាមលោកលើកទី២ ។ គេសង្កេតឃើញច្រើនតែបព្វជិត ដែលជាអ្នកដឹកនាំជាតិ ដោយព្រោះសង្ឃទាំងនេះឈឺចាប់នឹងការធ្លាក់ដុនដាប អាថ៌អានុភាពនៃវត្តអារាមរបស់ព្រះអង្គនេះម្យ៉ាង ម្យ៉ាងទៀត គឺឈឺចាប់នឹងការជិះជាន់នៃអាណិកជនភាគតិចឥណ្ឌា ដែលមានការគាំទ្រនិងការអនុគ្រោះពីអាណានិគមនិយមអង់គ្លេស ។ ក្នុងឆ្នាំ១៩៤២ មតិសាធារណៈបានអនុគ្រោះដល់ការលុកលុយរបស់ជប៉ុន ប៉ុន្តែមិនយូរប៉ុន្មានអ្នកដឹកនាំភូមាពុំមានជំនឿលើសេចក្តីសន្យារបស់ផាស៊ីសនិយមជប៉ុនឡើយ ដូចជាលោក *អ៊ូ នូ* និងលោក *នេវីន* ជាដើម ហើយក៏បានប្រយុទ្ធនឹងកងទ័ពជប៉ុនវិញយ៉ាងម៉ឺងម៉ាត់ ។ លុះសង្គ្រាមលោកលើកទី ២ ផុតរលត់ទៅ អាណានិគមនិយមអង់គ្លេសបានចូលមកជាថ្មីម្តងទៀត គេឈមមុខនឹងស្ថានភាពថ្មីនៃការតស៊ូរបស់ប្រជាជនភូមា ចក្រភពអង់គ្លេសក៏ត្រូវបង្ខំចិត្តប្រគល់ឯករាជ្យដល់ប្រទេសភូមាក្នុងឆ្នាំ ១៩៤៧ ។

ឃ. ការរំដោះនៃប្រជាជននៅឧបទ្វីបឥណ្ឌូចិន

ការតស៊ូដើម្បីសេរីភាពជាតិនៃប្រជាជនឥណ្ឌូចិន ប្រឆាំងនឹងការវិលត្រលប់មកវិញនៃអាណានិគមបារាំង ក្រោយពីកងទ័ពជប៉ុនទំលាក់អាវុធ សំរេចនូវការប្រកាស:

— ឯករាជ្យនៃប្រទេសកម្ពុជា ( វិច្ឆិកា ១៩៥៣ )

— ឯករាជ្យនៃប្រទេសវៀតណាម ( កក្កដា ១៩៥៤ សន្និសីទសឺណែវ )

— ឯករាជ្យនៃប្រទេសលាវ ( កក្កដា ១៩៥៤ សន្និសីទសឺណែវ ) ។

## ២. ការរំដោះនៃប្រជាជនទ្វីបអាព្រិច

នៅទ្វីបអាព្រិច ការរំដោះពីនឹមអាណានិគមនិយមត្រូវបានធ្វើក្រោយគេ គឺចាប់ពីឆ្នាំ ១៩៥៤ មក ។ ប៉ុន្តែ វិវត្តន៍ទៅរកឯករាជ្យមានល្បឿនឆាប់រហ័សក្រៃលែង ។ គេសន្និដ្ឋានបានថា ចាប់តាំងពីឆ្នាំ ១៩៦០ មក បណ្តាប្រទេសនៅទ្វីបអាព្រិចស្ទើរតែទាំងអស់ដណ្តើមយកបានមកវិញនូវឯករាជ្យរបស់ខ្លួន លើកលែងតែតំបន់ទាំងឡាយដែលនៅក្រោមនឹមអាណានិគមនិយម ពទុយគេ ដូចជា អង់គោឡា ម៉ូសំប៊ិចជាដើម ។

## ៣. ការរំដោះនៃប្រជាជននៅភូមិភាគដទៃទៀត

ក. នៅមជ្ឈិមបូព៌ា

ប្រទេសទាំងឡាយនៅមជ្ឈិមបូព៌ា ដែលធ្លាក់ខ្លួនចូលក្នុងនឹមដែកនៃអាណានិគមនិយមដែរនោះ មុនសង្គ្រាមគឺក្រោមនឹមអង់គ្លេស ហើយក្រោយសង្គ្រាមលោកលើកទី ២ ក្រោមនឹមអង់គ្លេសផង ក្រោមនឹមអាណានិគមបារាំងផង បានក្រោកឡើងប្រឆាំងនឹងការជិះជាន់យ៉ាងសាហាវនៃរបបត្រួតត្រាអាណានិគម ។ *ចលនាជាតិនិយមអេស៊ីប* ដឹកនាំដោយវរសេនីយឯក *ណាសេរ៍* បានត្រួសត្រាយផ្លូវតស៊ូប្រយុទ្ធយ៉ាងអង់អាច សំលាប់បំផុតពូជនូវរបបអាណានិគមនិយមប្រទេសអេស៊ីបក្នុងឆ្នាំ ១៩៥៦ ក្រោយពីសំរេចជាតិកម្មនៃព្រែកជីកស៊ុយអេ ។

រដ្ឋដទៃទៀតក៏តស៊ូដណ្តើមយកបានមកវិញ ជាបន្តបន្ទាប់គ្នានូវឯករាជ្យរបស់ខ្លួន : ប្រទេស *អ៊ីរ៉ង់* ប្រទេស *អ៊ីរ៉ាក់* ប្រទេស *ស៊ូដង់* ប្រទេស *លីប៊ី* ប្រទេស *លីបង់* ប្រទេស *ស៊ីរី* ។ល។

## ខ. ការរំដោះនៃប្រជាជននៅអាមេរិចឡាទីន

តាមផ្លូវច្បាប់ បណ្ដាប្រទេសនៅអាមេរិចឡាទីន សុទ្ធតែជាប្រទេសឯករាជ្យ ហើយមានសេរីភាពពេញលក្ខណៈ ។ តែតាមពិត ប្រទេសទាំងនោះសុទ្ធតែនៅក្រោមការគ្រប់គ្រងយ៉ាងខ្ចាំងជឹតនៃពួកមូលធនផ្ដាច់មុខរបស់សហរដ្ឋអាមេរិច ដែលបានជញ្ជក់ហុតឈាមប្រជាជនអាមេរិចឡាទីន ។ ដើម្បីបំរះចេញពីចំណងដែលកំពុងចងរឹតខ្វាំងឡើងៗនោះ ចលនាស្នេហាជាតិបានត្រូវបង្កបង្កើតឡើងនៅគ្រប់ប្រទេសដើម្បីតស៊ូនឹងការជិះជាន់យ៉ាងឃោរឃៅខាងលើ ។ *ការប្រកាសសាធារណរដ្ឋសង្គមនិយមគុយបា* នៅឆ្នាំ១៩៥៩ បានបើកផ្លូវមួយថ្មី ឆ្ពោះទៅរកការរំដោះប្រជាជនអាមេរិចឡាទីន ពីក្រញាំចក្រពត្តិនិយមអាមេរិកាំង ដែលបានស៊ីសាច់អង្គៀមឆ្អឹងប្រជាជន នៅក្នុងភូមិភាគនេះជាយូរណាស់មកហើយ ។

## សំណួរ

១. ស្ថានភាពទូទៅនៃបណ្ដាប្រទេសក្រោមនឹមអាណានិគមនិយមដូចម្ដេច ក្រោយសង្គ្រាមលោកលើកទី២ ?

២. ការរំដោះនៃ :

— ប្រទេសឥណ្ឌូនេស៊ី

— ប្រទេសឥណ្ឌា

— ប្រទេសភូមា

— ប្រទេសអេស៊ីប

— បណ្ដាប្រទេសនៅឥណ្ឌូចិន ។



13

# ២៤. បញ្ហានិងអង្គការអន្តរជាតិសំខាន់ៗ

ក្នុងមេរៀននេះ យើងលើកយកតែបញ្ហាសំខាន់ៗ ដែលមានលក្ខណៈទូទៅ ហើយដែលប៉ះពាល់មនុស្សជាតិទាំងមូល ពោលគឺយើងពុំលើកយកមកពិនិត្យនូវបញ្ហាណាដែលមានលក្ខណៈទាក់ទងតែបក្សសម្ព័ន្ធនេះឬពួកនោះ នោះឡើយ ។ ក្នុងចំណោមបញ្ហាសំខាន់ៗទាំងឡាយ ដែលទាក់ទងទៅនឹងមនុស្សជាតិទូទៅ ពោលគឺទាក់ទងទៅនឹងវាសនាអនាគតនៃលោកយើង មានបញ្ហាបួនជាធំ គឺបញ្ហាបំបាត់របបអាណានិគមនិយម បញ្ហាអត់ឃ្លាន បញ្ហាសន្តិភាពនិងសង្គ្រាម ហើយនិងបញ្ហាសហវិជ្ជមានដោយសន្តិភាព ។

## ១. បញ្ហាបំបាត់របបអាណានិគមនិយម

បញ្ហានេះបានទាក់អារម្មណ៍មនុស្សគ្រប់រូបដែលស្នេហាយុត្តិធម៌ ស្នេហាសេរីភាពនាបច្ចុប្បន្នសម័យ ។ យ៉ាងណាមិញ គេទាំងអស់គ្នាពុំអាចអត់ឱនឲ្យរបបអាណានិគមនិយមដ៏ជាទីគួរខ្មាស គួរខ្ពើមរអើមនេះ រស់រានមានជីវិតក្នុងសតវត្សទី ២០ នេះបានឡើយ ។ ប៉ុន្តែ ក្រោយពីសង្គ្រាមលោកលើកទី២ បានផុតរលត់ទៅ គេសង្កេតឃើញការរលាយបាត់បង់ជីវិតនៃរបបអាណានិគមនិយមគ្រប់តំបន់ទាំងអស់ ហើយក្នុងពេលសព្វថ្ងៃនេះ មានប្រទេសប្រមាណបួន-ដប់ប៉ុណ្ណោះទេ ដែលបំរះខ្លួនពុំទាន់រួចពីនឹមដែកនៃអាណានិគមនិយមបរទេស ។ ការគួរឲ្យប្រយ័ត្ន គឺថិតនៅលើការពង្រីកនៃបណ្ដាប្រទេសដែលទើបនឹងបានឯករាជ្យថ្មីៗ ក្នុងការការពាររាំងរាជ្ជអាណានិគមនិយមថ្មី-ចាស់ កុំឲ្យមកជ្រៀតជ្រែកចូលក្នុងជីវភាពជាតិបានទៀត ។

## ២. បញ្ហាអត់ឃ្លាន

លោកយើងនាបច្ចុប្បន្នសម័យបានស្គាល់ការចំរើន ដ៏ជាទីស្ញប់ស្ញែងនៃវិទ្យាសាស្ត្រនិងបច្ចេកទេស ។ ប៉ុន្តែ ការដែលគួរឲ្យចាប់អារម្មណ៍ គឺមានមនុស្សចំនួន ២/៣ ក្នុងលោក

យើងនេះដែលរស់នៅដោយគ្រដាបគ្រដួសវេទនា គួរឲ្យអាណិតមេត្តា ហើយនិងមនុស្ស ចំនួន២/៣ ទៀតដែលមានសុខភាពពុំពេញលេញ មានរាងកាយស្គាំងស្គម មានជំងឺរ៉ាំរ៉ៃប្រចាំខ្លួន ហើយដែលគួរឲ្យអាណោចអាធ័មទៅទៀតនោះ គឺរស់នៅដូចជាសត្វ ពុំមានចំណេះអ្វីបន្តិចបន្តួចសោះ គឺសុទ្ធសឹងតែជាអនក្ខរជន ។

បញ្ហានេះជាបញ្ហាធំ ដែលអាណានិគមនិយមទុកជាកេរដំណែល ហើយដែលគេត្រូវតែជួយដោះស្រាយដើម្បីបំបាត់អយុត្តិធម៌ ។ មហាអំណាចអាណានិគមនិយមបស្ចិមប្រទេសដែលជាអ្នកទទួលខុសត្រូវចំពោះស្ថានភាពគួរឲ្យខ្មាសនេះ អាចនឹងជួសជុលលុបលាងអយុត្តិធម៌របស់ខ្លួនបាន ដោយវិធីផ្តល់ជំនួយគ្រប់បែបយ៉ាង ដល់បណ្តាប្រទេសទន់ខ្សោយទាំងនោះ ។ ប៉ុន្តែ ផ្ទុយទៅវិញ គេសង្កេតឃើញប្រទេសដែលមានស្រាប់នោះរឹតតែមានឡើង ឯប្រទេសដែលទុនថយក្រស្រាប់នោះ រឹតតែធ្លាក់ចុះក្រថែមទៀត ហើយអណ្តូងដែលខណ្ឌលោកទាំងពីរនេះមានសភាពរឹតតែជ្រៅឡើងៗ ជាហេតុពុំអាចឲ្យគេសង្ឃឹមទៅលើជំនួយបរទេសបានឡើយ ។

## ៣. បញ្ហាសន្តិភាពនិងបញ្ហាសង្គ្រាម

នេះជាបញ្ហាដែលទាក់ទងទៅនឹងមនុស្សជាតិទូទៅ ហើយដែលគេត្រូវតែដោះស្រាយជាបន្ទាន់ ។ យ៉ាងណាមិញ មធ្យោបាយសំរាប់ប្រល័យជីវិត គ្រាប់បែកបរមាណូគ្រប់ធុន កាំជ្រួចចក្រវាឡ ។ល។ ដែលវិទ្យាសាស្ត្របានផ្តល់ហើយដែលមហាអំណាចបានផលិតយ៉ាងស្គុកស្គម្ភនោះ នឹងធ្វើឲ្យលោកយើងវិនាសសាបសូន្យទៅវិញបាន ប្រសិនបើសង្គ្រាមត្រូវផ្ទុះ ។

ដើម្បីចៀសវាងមហន្តរាយនេះ មាគ៌ាមានតែមួយគឺការរំលាយសព្វាវុធទូទៅ ( ពោលគឺការបំបាត់ចោលមធ្យោបាយសំរាប់សង្គ្រាម ) ក្រោមការត្រួតត្រាអន្តរជាតិមួយយ៉ាងម៉ឺងម៉ាត់តឹងរ៉ឹង ហើយប្រកបដោយប្រសិទ្ធិភាពផង ។ ការប៉ុនប៉ងដោះស្រាយបញ្ហានេះបានចាប់ប្រព្រឹត្តជាយូរណាស់មកហើយ ក្រោមការដឹកនាំនៃអង្គការសហប្រជាជាតិ ប៉ុន្តែជាង ១០ ឆ្នាំហើយ គេពុំឃើញបានលទ្ធផលអ្វីសោះ ។

## ៤. បញ្ហាសហវិវឌ្ឍមានដោយសន្តិភាព

ការបែងចែកលោកយើងនាបច្ចុប្បន្នសម័យ ជាប៉ុកពីរប្រឆាំងរឹងរូសរវាងគ្នានិងគ្នាទៅតាមមនោគមវិជ្ជា អាចមានគ្រោះថ្នាក់ដល់មនុស្សជាតិទូទៅ ។ គ្រោះថ្នាក់នេះមានសភាពរឹងរឹតតែធ្ងន់ណាស់ទៅទៀត ពីព្រោះប៉ុកនីមួយៗសុទ្ធតែមានមធ្យោបាយសំរាប់



វិមាននៃអង្គការសហប្រជាជាតិនៅក្រុងញូយ៉ក

ប្រល័យលោករៀងៗខ្លួន ។

ដូចនេះ ក្នុងទំនាក់ទំនងអន្តរជាតិ មាគ៌ាមានតែមួយគឺសហវិជ្ជមានដោយសន្តិភាព ។ តែគេអាចដណ្ដឹងសួរថា តើសហវិជ្ជមាននេះអាចអនុវត្តទៅបានឬទេ រវាងអ្នកសង្កត់សង្កិនគេនិងអ្នកត្រូវគេសង្កត់សង្កិន រវាងអ្នកជិះជាន់គេ និងអ្នកត្រូវគេជិះជាន់ ពោលគឺរវាងសេដ្ឋីនិងអ្នកអនាថា ។ សហវិជ្ជមានដោយសន្តិភាពជាមាគ៌ាល្អក៏ពិតមែនហើយ តែការរួមរស់ដោយសន្តិភាពពុំអាចឲ្យគេបិទមាត់បាន ចំពោះរបបគ្រប់គ្រងមួយដែលផ្អែកទៅលើ « មនុស្សជិះជាន់មនុស្ស » ។



*សាលប្រជុំនៃអង្គការសហប្រជាជាតិ*

អង្គការអន្តរជាតិ

ក្រោយសង្គ្រាមលោកលើកទី២ គេបានបង្កើតអង្គការអន្តរជាតិជាច្រើនដើម្បីដោះស្រាយបញ្ហាអន្តរជាតិជាច្រើន ដើម្បីដោះស្រាយបញ្ហាអន្តរជាតិទាំងឡាយ ដែលមានលក្ខណៈទាក់ទងនឹងមនុស្សជាតិទូទៅ ជាអាទិ មានអង្គការសហប្រជាជាតិ និងអង្គការឯកទេសដែលឋិតក្រោមឱវាទ :

*អង្គការសហប្រជាជាតិ* (ONU) ដែលគេបានស្ថាបនាក្នុងឆ្នាំ ១៩៤៥ ដើម្បីរក្សាសន្តិភាព លើកស្ទួយលក្ខណៈជីវភាពមនុស្សទូទៅ ដោយប្រយុទ្ធតស៊ូនឹងការអត់ឃ្លាន នឹងជំងឺតំកាត់ ហើយនឹងអនក្ខរភាព ។ ក្នុងផ្ទៃនៃអង្គការសហប្រជាជាតិ គេបានបង្កើតអង្គការជាច្រើនទៀត សំរាប់ដោះស្រាយបញ្ហាផ្សេងៗ ទៅតាមសមត្ថភាពដូចជា :

— *ក្រុមប្រឹក្សាសន្តិសុខ* អង្គការនេះមានភារៈថែរក្សាសន្តិសុខអន្តរជាតិ ។ សមាជិកនៃអង្គការនេះមានពីរប្រភេទ គឺសមាជិកអចិន្ត្រៃយ្យប្រាំ : សហរដ្ឋអាមេរិច សហភាពសូវៀត ចក្រភពអង់គ្លេស បារាំង និង ចិន ដែលជាប្រទេសមានសិទ្ធិពិសេស ហៅថា « សិទ្ធិវេតូ » និងសមាជិកធម្មតាពុំមែនអចិន្ត្រៃយ្យមួយចំនួនទៀត ដែលត្រូវមហាសន្និបាតជ្រើសរើសសំរាប់ពីរឆ្នាំម្តង ហើយដែលសំរាប់តាងភូមិភាគផ្សេងៗក្នុងលោកយើងនេះ ។

— *អគ្គលេខាធិការដ្ឋាន* គឺជាការិយាល័យប្រតិបត្តិ មានភារៈទទួលអនុវត្តគ្រប់សេចក្តីសំរេចនៃមហាសន្និបាត និងក្រុមប្រឹក្សាសន្តិសុខ ព្រមទាំងសេចក្តីសំរេចរបស់អង្គការសហប្រជាជាតិ ។ អគ្គលេខាធិការនៃអង្គការសហប្រជាជាតិមានមុខងារខាងនយោបាយយ៉ាងសំខាន់ ។

— *ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ច* មានភារៈជួយប្រទេសទន់ខ្សោយទាំងឡាយក្នុងវិស័យសេដ្ឋកិច្ចនិងសង្គមកិច្ច ។

— *តុលាការអន្តរជាតិ* មានភារៈរកយុត្តិធម៌ឲ្យប្រទេសជាសមាជិក ដែលមានទំនាស់រវាងគ្នានិងគ្នា ។

— *ក្រុមប្រឹក្សាត្រួតត្រា* មានភារៈជួយដឹកនាំបណ្តាប្រទេសទាំងឡាយដែលនៅក្រោមការកាន់កាប់នៃអង្គការសហប្រជាជាតិ ឆ្ពោះទៅរកឯករាជ្យរបស់ខ្លួន ។

ក្រៅពីអង្គការទាំងនេះ មានអង្គការច្រើនទៀតដូចជា :

អង្គការយូនេស្កូ ( UNESCO ) អង្គការផាវ ( FAO ) អង្គការសុខភាពពិភពលោក ( OMS) អង្គការអន្តរជាតិខាងការងារ ( OIT ) ភ្នាក់ងារអន្តរជាតិខាងថាមពលបរមាណូ ( AIEA ) អង្គការអន្តរជាតិខាងអាកាសចរស៊ីវិល ( OACI) សហភាពប្រៃសណីយ៍សកល ( UPU ) សហភាពអន្តរជាតិខាងទូរគមនាគមន៍ ( UIT ) អង្គការពិភពលោកខាងឧតុនិយម ( OMM) ដែលបានបំពេញបេសកកម្មរបស់ខ្លួន គួរឲ្យសន្មតថាបានការដែរ ថ្វីបើលទ្ធភាពខាងហិរញ្ញវត្ថុរបស់គេមានសភាពតិចតួចស្តួចស្តើងក៏ដោយ ។

អង្គការសហប្រជាជាតិ ដោយសារមធ្យោបាយខាងផ្លូវចិត្ត ខាងហិរញ្ញវត្ថុនិងខាងសំភារៈរបស់ខ្លួន បានបំពេញសកម្មភាពគួរជាទីគាប់ចិត្តខ្លះៗដែរ បើយើងនិយាយពីលទ្ធផលទូទៅ ។ ប៉ុន្តែ សម្ព័ន្ធភាពនៃអង្គការនេះ នាបច្ចុប្បន្នសម័យ ពុំស្រូវស្របនឹងស្ថានភាពបច្ចុប្បន្នឡើយ ។ ការឧបត្ថម្ភរបស់សហរដ្ឋអាមេរិច ទៅលើគ្រប់អង្គការទាំងឡាយនៃអង្គការសហប្រជាជាតិ វាច្បាស់ក្រៃលែង ។ ដូចនេះ ដើម្បីឲ្យអង្គការទាំងនេះបំពេញបេសកកម្មរបស់ខ្លួនដោយប្រសិទ្ធិភាពនោះ គេត្រូវតែគិតគូរទំរង់ការរៀបចំអង្គការទាំងនេះឡើងវិញ ដើម្បីឲ្យបានស្របទៅនឹងស្ថានភាពសព្វថ្ងៃ ។ កំណែទំរង់សម្ព័ន្ធភាពនេះ បើធ្វើបានឆាប់កាលណា រឹតតែប្រសើរកាលនោះ ។

## សំណួរ

១. បញ្ហាសំខាន់ៗមានអ្វីខ្លះ ?

២. ហេតុអ្វីបានជាគេទុកបញ្ហាអត់ឃ្លានជាបញ្ហាសំខាន់ ?

៣. និយាយដោយសង្ខេបអំពីបញ្ហាសន្តិភាព និងបញ្ហាសង្គ្រាម ។

៤. ក្រុមប្រឹក្សាសន្តិសុខមានភារៈអ្វីខ្លះ ?

៥. អង្គការយូនេស្កូតាំងនៅទីណា ?មានភារៈអ្វីខ្លះ ?

# ២៥. ប្រទេសខ្មែរ
# ក្រោមអាណាព្យាបាលប្រទេសបារាំង

ក្នុងពាក់កណ្ដាលទី ១ នៃសតវត្សទី ១៩ ប្រទេសខ្មែរនៅក្រោមអំណាចយួននិងសៀម ពីព្រោះតែស្ដេចខ្មែរហែកហួរ ដណ្ដើមរាជ្យគ្នា ។ ម្ល៉ោះហើយបានជាមកដល់រាជ្យព្រះបាទអង្គឌួងទៅហើយ (ឆ្នាំ ១៨៤៧ ដល់ ១៨៦០) ក៏មានសៀមនិងយួនមកនៅប្រចាំការអមស្ដេចខ្មែរ ដើម្បីសំរេចកិច្ចការរបស់ខ្មែរ ។ ចំពោះការជិះជាន់បែបនេះព្រះបាទអង្គឌួងទ្រង់ប្រឹងរិះរកមធ្យោបាយគ្រប់បែបយ៉ាងដើម្បីនឹងរំដោះខ្លួនពីបរទេសទាំង ២ នេះ ។ នៅឆ្នាំ ១៨៥៤ ស្ដេចអង្គឌួងនេះបានឲ្យរាជទូតខ្មែរម្នាក់ទៅទាក់ទងនឹងកុងស៊ុលបារាំងតាំងនៅសិង្ហបុរី ក្នុងគោលបំណងឲ្យប្រទេសបារាំងជួយការពារប្រទេសខ្មែរ ប៉ុន្តែ ពុំបានសំរេច ព្រោះសៀមបានដឹងកិច្ចការនេះដែរ ហើយសៀមក៏កំហែងព្រះបាទអង្គឌួងថា « បើព្រះអង្គព្រមចុះសន្ធិសញ្ញាសម្ពន្ធភាពជាមួយនឹងបារាំងដែលមានដឺម៉ុងទីញី (De Montigny) ជាតំណាងនោះ សៀមនឹងលើកទ័ពចូលមកកំទេចខ្មែរពុំខានឡើយ » ។ ចំពោះស្ថានការណ៍នេះ ព្រះបាទអង្គឌួងពុំហ៊ានឲ្យដឺម៉ុងទីញីចូលមកក្រាបបង្គំគាល់ទេ ។ ឃើញដូចនេះ បារាំងក៏ផ្អាកការចុះសន្ធិសញ្ញាសម្ពន្ធភាពបារាំង-ខ្មែរនេះទេ ។ នៅឆ្នាំ ១៨៦០ ព្រះបាទអង្គឌួងក៏ចូលទិវង្គត ឯបារាំងក៏បានចូលមកត្រួតត្រាលើយួនដែលតាំងនៅព្រៃនគរ ។

## ១. សន្ធិសញ្ញាឆ្នាំ ១៨៦៣

រាជបុត្រច្បងរបស់ព្រះបាទអង្គឌួងគឺព្រះបាទ *នរោត្ដម* បានគ្រងរាជសម្បត្តិស្នង ។ ឯរាជបុត្របន្ទាប់គឺ ស៊ីសុវត្ថិ និង ស៊ីវត្ថា ។ ព្រះបាទនរោត្ដម កាលដែលឡើងគ្រប់គ្រងប្រទេសខ្មែរហើយ និយមតែភាសាសៀមនិងទំនៀមទំលាប់សៀម ព្រមទាំងពឹងផ្អែកលើសៀមផងទៀត ប្រសិនបើមានការអ្វីម្ដងៗ ដោយឥរិយាបថបែបនេះ ព្រះអង្គក៏ចេះ

តែមានគំនិតខ្វាចអនុជទាំងពីរក្សត់ ហើយក៏ទំប្រើងវិះរកមធ្យោបាយធ្វើឲ្យសៀមចាប់អនុជយកទៅឃុំទុកនៅបាងកក ។ ក្នុងគំនិតខ្វាចអនុជជ្រែករាជ្យដដែលនេះ ព្រះបាទនរោត្តមបានភៀសខ្លួនទៅបាងកក ដោយយកទាំងបញ្ចក្កកុធភណ្ឌទៅជាមួយផងក្នុងឆ្នាំ ១៨៦១ ។ នៅឆ្នាំ ១៨៦២ សៀមក៏បាននាំព្រះអង្គមកស្រុកខ្មែរវិញ ដោយធ្វើដំណើរកាត់តាមខេត្តកំពត ។ នៅខែកញ្ញា ១៨៦២ ព្រះរាជាខ្មែរបានទទួលទស្សនកិច្ចរបស់លោកឧត្តមនាវី *បូណា* (Bonard) ជាតិបារាំងដែលត្រួតត្រាកម្ពុជាក្រោម ។ ជនបារាំងនេះបានសង្កេតឃើញថា សៀមមានឥទ្ធិពលលើខ្មែរខ្លាំងណាស់ ។ ដើម្បីបង្ហាញសៀមឲ្យឃើញថា បារាំងចង់ចូលមកត្រួតត្រាលើទឹកដីខ្មែរ គេក៏ពុំព្រមបញ្ជូនបក្សពួកស៊ីវត្ថា *(១)* ដែលគេចខ្លួនទៅនៅកម្ពុជាក្រោមមកឲ្យសៀមវិញទេ ។

បន្ទាប់មក ទេសាភិបាលបារាំងថ្មីនៅកូសាំងស៊ីន គឺលោកឧត្តមនាវី *ឡាក្រង់ឌៀ* (Lagrandière) បានបញ្ជូននាយទាហានជើងទឹកម្នាក់ឈ្មោះ *ឌូដា ដឺឡាក្រេ* ( Doudart de Lagrée ) មកក្រាបទូលព្រះបាទនរោត្តម បង្ខំព្រះអង្គឲ្យចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាពនិងមិត្តភាពរវាងបារាំងនិងខ្មែរ ចុះថ្ងៃទី *១១ សីហា ១៨៦៣* ។

អធិរាជបារាំងបានអះអាងថា នឹងការពារប្រទេសខ្មែរ ហើយនិងដាក់តំណាងម្នាក់នៅអមស្តេចខ្មែរ ។ ចំណែកខ្មែរវិញក៏អាចដាក់តំណាងម្នាក់នៅព្រៃនគរអមទេសាភិបាលបារាំងនៅកូសាំងស៊ីនដែរ ។ តាមមាត្រា ១ ២ និង ៣ នៃសន្ធិសញ្ញានេះ ព្រះចៅប្រទេសបារាំងត្រូវទទួលភារកិច្ចធ្វើប្រទេសខ្មែរ ឲ្យមានរបៀបរៀបរយ មានសន្តិភាពនិងការពារប្រទេសខ្មែរកុំឲ្យបរទេសលុកលុយថែមទៀត ។ ក្នុងគោលបំណងនេះ ព្រះរាជាខ្មែរបានប្រទានដីមួយកន្លែងនៅជ្រោយចង្វាទៅបារាំង ដើម្បីធ្វើឃ្លាំងដាក់ធ្យូងថ្ម និងគ្រឿងសំភារៈផ្សេងៗ ។ ម្យ៉ាងទៀត ស្តេចខ្មែរបើកសិទ្ធិឲ្យរាជការបារាំងកាប់ឈើដើម្បីយកទៅធ្វើកប៉ាល់របស់គេ ។ សន្ធិសញ្ញានេះត្រូវបានបញ្ជូនទៅក្រុងប៉ារី « ដើម្បីថ្វាយព្រះចៅណាប៉ូលេអុងទី ៣ » ចុះហត្ថលេខាអនុម័តថែមទៀត ។ ក្នុងចន្លោះពេលដែលបារាំងពុំទាន់អនុម័តលើសន្ធិសញ្ញានេះ សៀមក៏ចេះតែឲ្យតំណាងខ្លួនមកគំរាមកំហែង

---

*(១) បក្សពួកស៊ីវត្ថាបានបះបោរប្រឆាំងនឹងព្រះបាទនរោត្តម ហើយបានគេចខ្លួនទៅនៅកម្ពុជាក្រោមដែលពេលនោះធ្លាក់ទៅក្នុងអំណាចត្រួតត្រាបារាំងហើយ ។*

ព្រះបាទនរោត្តមជាញឹកញយ ។ ស្ដេចខ្មែរដោយចាំសន្ធិសញ្ញានេះយូរពេក ហើយដោយខ្លាចសៀមលើកទ័ពចូលមកទៀតក៏សុខចិត្តប្រគល់ដោយសំងាត់ទៅសៀម នូវខេត្តពោធិ៍សាត់ និងកំពង់ស្វាយថែមទៀត ក្នុងឆ្នាំ ១៨៦៣ ។ លុះដល់បានដឹងរឿងនេះ បារាំងមិនចង់ឲ្យខាតដីដែលត្រួតត្រា ក៏កំហែងយកពីសៀមមកវិញ ។

សន្ធិសញ្ញាខ្មែរ-បារាំងត្រូវបានផ្ញើត្រឡប់ពីក្រុងប៉ារីមកវិញនៅខែមីនា ១៨៦៤ ។ ដោយសំអាងលើសន្ធិសញ្ញានេះ បារាំងក៏សុំសៀមឲ្យបញ្ជូនបញ្ចកកុធភណ្ឌមកថ្វាយព្រះបាទនរោត្តមដែលបានទទួលរាជាភិសេកនៅថ្ងៃទី ៣ មិថុនា ១៨៦៤ ។

ចាប់តាំងពីពេលនោះមក សៀមក៏ថយចេញពីឧដុង្គ លែងមានអំណាចត្រួតត្រាលើខ្មែរទៀតហើយ ។ កម្ពុជាក៏ធ្លាក់ទៅក្នុងកណ្ដាប់ដៃបារាំងវិញ ។

## ២. សន្ធិសញ្ញាឆ្នាំ ១៨៦៧ និងការរៀបចំលើកទី ១

ក្រោយដែលបានទទួលរាជសម្បត្តិហើយ ព្រះបាទនរោត្តមបានបង្ក្រាបអង្គការតស៊ូដែលមានអាចារ្យស្វានិងពោកំបោរជាអ្នកដឹកនាំ ។

ក្នុងរជ្ជកាលព្រះបាទនរោត្តម ខេត្តលុងហោរ (វិញឡុង) មាត់ជ្រូក (ចូវដុក) និងពាមបន្ទាយមាស (ហាទៀង) ត្រូវបារាំងយកទៅដាក់ក្នុងដែនកម្ពុជាក្រោម ដែលនៅក្រោមអំណាចរបស់ខ្លួន ។ ដូចនេះ ដែនកម្ពុជាក្រោមទាំងមូលក៏ឋិតក្រោមការគ្រប់គ្រងរបស់បារាំងចាប់តាំងពីពេលនោះមក ។

នៅខែកក្កដា ១៨៦៧ ស្ដេចសៀមបានធ្វើសន្ធិសញ្ញាមួយជាមួយនឹងបារាំង ។ តាមសន្ធិសញ្ញានេះ សៀមត្រូវអស់សិទ្ធិត្រួតត្រាលើប្រទេសខ្មែរ តែបារាំងបានទទួលស្គាល់ថា ខេត្តសៀមរាប បាត់ដំបង និងស៊ីសោភ័ណជារបស់សៀម ។ ម្យ៉ាងទៀតបារាំងបានសន្យាថា មិនបញ្ចូលប្រទេសខ្មែរជាអាណានិគមដូចកម្ពុជាក្រោមឡើយ ។

នៅឆ្នាំ ១៨៦៧ ព្រះបាទនរោត្តមបានយាងចេញពីឧដុង្គមកគង់នៅរាជវាំងថ្មីឯភ្នំពេញ ដើម្បីឲ្យបានមកជិតបារាំងដែលតាំងនៅព្រៃនគរ ។ នៅឆ្នាំ ១៨៧៧ ព្រះបាទនរោត្តមបានពិភាក្សាជាមួយនឹងតំណាងបារាំងនៅប្រទេសកម្ពុជា ដើម្បីរៀបចំច្បាប់ទំលាប់ខ្លះក្នុងប្រទេស ។ ការរៀបចំជាថ្មីនេះមានចំណុចសំខាន់ៗដូចតទៅ :

— ប្រាក់ពន្ធដារក្នុងប្រទេសភាគច្រើន ត្រូវយកទៅធ្វើសមិទ្ធិសំរាប់ជាប្រយោជន៍សាធារណៈ

— គណៈរដ្ឋមន្ត្រីអាចសំរេចនិងពិនិត្យបញ្ហាសំខាន់ៗខ្លះ ពុំចាំបាច់សាកសួរយោបល់ព្រះរាជាឡើយ ឯតំណាងប្រទេសបារាំងមានសិទ្ធិពេញទីចូលរួមក្នុងការប្រជុំសំរេចកិច្ចការគ្រប់បែបយ៉ាង ហើយនិងមានសិទ្ធិបញ្ចេញយោបល់ទៀតផង ។ គេសំរេចឲ្យបន្ថយចំនួនខេត្តក្នុងប្រទេស ដើម្បីចៀសវាងចំណាយច្រើន ។ អ្នករាជការទាំងឡាយត្រូវបានទទួលប្រាក់ប្រចាំខែពីព្រះរាជាទៅតាមកិច្ចការរបស់ខ្លួន ហើយពុំអនុញ្ញាតអ្នករាជការទាំងនោះឲ្យដកយកពន្ធដារផ្ទាល់ពីរាស្ត្រមកធ្វើជាប្រាក់ប្រចាំខែរបស់ខ្លួនទៀតឡើយ ។

អនុវត្តន៍ច្បាប់ថ្មីនេះពុំមានប្រសិទ្ធិភាពទេ ដោយមានការជំទាស់ពីសំណាក់មន្ត្រីរាជការខ្លះ ។ នៅឆ្នាំ ១៨៨៤ បារាំងក៏បង្ខំព្រះបាទនរោត្តមឲ្យចុះសន្ធិសញ្ញាថ្មីមួយទៀត ដែលបើកអំណាចជាច្រើនដល់បារាំង ដើម្បីចាត់ចែងការលើប្រទេសខ្មែរទាំងមូល ។

## ៣. អនុសញ្ញាឆ្នាំ ១៨៨៤

នៅថ្ងៃទី ១៧ មិថុនា ១៨៨៤ វេលាម៉ោង ១០ យប់ ទេសាភិបាលនៅកូសាំងស៊ីនឈ្មោះ *សាល ថុំសុន* (Charles Thomson) ដោយមានបារាំងម្នាក់ទៀតជាតំណាងអាណានិគមនិយមបារាំងឈ្មោះ *ភូរ៉ែស* (Fourès) មកជាមួយផង បានចូលទៅបង្ខំព្រះបាទនរោត្តមឲ្យចុះហត្ថលេខាលើសន្ធិសញ្ញាថ្មីមួយទៀត ។ សន្ធិសញ្ញានេះបានដកសិទ្ធិរបស់ស្តេច ដើម្បីឲ្យបារាំងធ្វើជាអាណាព្យាបាលលើប្រទេសខ្មែរទាំងមូល ។ ឯសេចក្តីនៃសន្ធិសញ្ញានោះមានខ្លះៗដូចតទៅ :

— ស្តេចត្រូវតែទទួលកំណែប្រែផ្នែករដ្ឋបាល តុលាការ ហិរញ្ញវត្ថុ សេដ្ឋកិច្ចដែលគណៈរដ្ឋមន្ត្រីសាធារណរដ្ឋបារាំងបានសំរេចថានឹងធ្វើ

— ត្រូវឋិតនៅក្រោមការត្រួតត្រារបស់បារាំង ភ្នាក់ងាររាជការខ្មែរ មានចៅហ្វាយខេត្តនិងមេក្រសួងជាដើម ។ ក្រសួងគយ សាធារណការនិងក្រសួងឯទៀតៗដែលត្រូវការរិស្វករឲ្យឋិតនៅក្រោមការចាត់ចែងរបស់បារាំងផ្ទាល់ដែរ

— ស្តេចត្រូវតែទទួលតំណាងបារាំងតាមសេចក្តីស្នើសុំ

— ចំណាយសំរាប់រាជការក្នុងរាជាណាចក្រនិងសំរាប់អាណានិគមនិយមបារាំង ជា

បន្ទុករបស់ប្រទេសខ្មែរ ។ល។

ការដកអំណាចពីព្រះមហាក្សត្រខ្មែរ ការយកប្រទេសខ្មែរមកដាក់ក្នុងអំណាចអភិបាលបារាំងបានបណ្ដាលឲ្យមានចលនាប្រឆាំងនឹងបារាំង ក្នុងអំឡុង ១៨ ខែ (១៨៨៥-១៨៨៧) ទ័ពបារាំងបានបង្ក្រាបក្រុមអ្នកតស៊ូជានិច្ច ។ របះបោរទាំងនេះកើតឡើងដោយព្រះតំរិះរបស់ព្រះបាទនរោត្តម ដើម្បីប្រឆាំងនឹងបារាំង ប៉ុន្តែដោយទ័ពទាំងនោះខ្វះសំភារៈ ខ្វះស្បៀងអាហារទើបព្រះបាទនរោត្តមបញ្ឈប់ទៅវិញ *(១)* ។ ឯពួកមេដឹកនាំចលនាទាំងនេះត្រូវបារាំងប្រើកលល្បិចផ្សេងៗ យកទៅសំលាប់ចោលអស់ជាច្រើន ដោយវិធីព្រៃផ្សៃបំផុត ។ ខ្លះត្រូវគេលួចសំលាប់ ខ្លះទៀតត្រូវគេចាប់យកទៅចងផ្ដាបនឹងបំពង់ផ្សែងកប៉ាល់ ដូចជាលោកឧកញ៉ាក្រឡាហោមគង់ជាដើម ។

នៅសតវត្សទី ១៩ ប្រទេសខ្មែរបានធ្លាក់ទៅក្នុងកណ្ដាប់ដៃរបស់ជនបរទេសមួយទៀតគឺបារាំងសេស ។ ការតាំងអំណាចនេះ ជាបន្ទុកធ្ងន់មួយចំពោះរាស្ត្រខ្មែរក្នុងអំឡុង ៩០ ឆ្នាំ (១៨៦៣-១៩៥៣) ។ អាណានិគមនិយមបារាំងធ្វើឲ្យរាស្ត្រខ្មែរបាត់បង់អរិយធម៌និងវប្បធម៌របស់ខ្លួន បំផ្លាញសេដ្ឋកិច្ចខ្មែរ បំណងទុកខ្មែរឲ្យនៅក្រោមអំណាចគេជាដរាប ។ ឯការដែលបារាំងបានទាមទារយកខេត្តខ្លះមកឲ្យខ្មែរវិញ ដូចជា បាត់ដំបង សៀមរាប ស៊ីសោភ័ណ ជាករណីយកិច្ចរបស់បារាំងក្នុងឋានៈជាអ្នកការពារទឹកដីខ្មែរ បើបារាំងពុំបានធ្វើដូច្នោះទេ នោះពិតជាខុសនឹងសន្ធិសញ្ញាឆ្នាំ ១៨៦៣ ។ ម្យ៉ាងទៀត បារាំងបានសំរេចកាត់ខេត្តខ្លះនៅកម្ពុជាក្រោម ឲ្យយួនឥតបានសួរយោបល់ពីរាជរដ្ឋាភិបាលខ្មែរឡើយ នេះជាកំហុសមួយយ៉ាងធំរបស់បារាំងជំនាន់អាណានិគម ដែលធ្លាក់មកលើប្រជារាស្ត្រខ្មែរ ទីបំផុត ដោយការភ្ញាក់រលឹកនិងសាមគ្គីរវាងរាស្ត្រខ្មែរទាំងអស់ ខ្មែរក៏បានបង្កើតចលនាផ្សេងៗទាមទារយកឯករាជ្យពីបារាំងបានមកវិញ នៅថ្ងៃទី ៩ វិច្ឆិកា ១៩៥៣ ។

---

*(១) ព្រះបាទនរោត្តមឲ្យឈប់ធ្វើបះបោរ មកពីមានការគំហែងគំរាមពីបារាំងថា បើមិនឈប់ទេ នឹងចាប់ស្ដេចខ្មែរយកទៅស្រុកបារាំង ឬទៅស្រុកអាព្រិច ។*

# សំណួរ

១. សៀមនៅមានអំណាចត្រួតត្រាលើខ្មែររហូតដល់ឆ្នាំណា ?

២. សន្ធិសញ្ញាបារាំង - ខ្មែរឆ្នាំ ១៨៦៣ មានន័យយ៉ាងដូចម្ដេច ? ចុះសន្ធិសញ្ញាខ្មែរ - បារាំង នៅឆ្នាំ ១៨៩៤ វិញ ?

៣. ព្រះបាទនរោត្តមមានចរិយាយ៉ាងដូចម្ដេចខ្លះ ដែលគួរឲ្យកត់សំគាលបាន ?

៤. បើតាមការរៀបចំក្នុងផ្នែកសង្គមកិច្ចលើកទី ១ ឆ្នាំ ១៩៦៧ តើអ្នកអាចយល់ពីសង្គមខ្មែរក្នុងសម័យមុន ( ឆ្នាំ ១៨៦៧ ) *(១)* បានយ៉ាងដូចម្ដេចខ្លះ ?

---

*(១) ឆ្នាំ ១៨៦៧ បារាំងឲ្យទៅយួននូវខេត្តលុងហោរ ( វិញឡុង ) មាត់ជ្រូក ( ចូវដុក ) និងពាមបន្ទាយមាស ( ហាទៀង ) ។*

# ពាក្យខុសត្រូវ

( មុនអានសូមមេត្តាកែសិន )

| ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ |
|---|---|---|---|
| 1 | 9 | *បដិវត្តិន៍* | *បដិវត្តន៍* |
| 4 | 10 | *( ១៨៤៩ - ១៩៥៤ )* | *( ១៥៤៩ - ១៨៥៥ )* |
| 6 | 21 | *ជីទិត* | *ជីវិត* |
| 61 | 10-15 | *ចលនាបដិវត្តន៍* | *ចលនាបដិវត្ត* |
| 80 | 3 | *ម្យាងទៀត* | *ម៉្យាងទៀត* |
| 112 | 10-18 | *រស៊ី* | *រូស៊ី* |
| 150 | 22 | *កម* | *មក* |
| 161 | 10 | *គ្រោះថ្នាក* | *គ្រោះថ្នាក់* |
| 174 | 17 | *ឯកភាព* | *ឯករាជ្យ* |
| 177 | 2 | *លីក* | *លើក* |
| 179 | 1 | *បសិម* | *បស្ចិម* |
| 191 | 16 | *ផាមតិាន* | *ផាតិមាន* |

តំកល់ទុកតាមច្បាប់លេខ ១ ២៨២
ចុះថ្ងៃទី ២៧-៣-៧៣
បោះពុម្ពលើកទី ២ ចំនួន ១០ ០០០ ក្បាល

តំលៃ ១៣០៛

រោងពុម្ព ពេជ្រនីល
លេខ ៣៨៣ វិថីកម្ពុជាក្រោម